ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និង សាលាបណ្ដាញលើផ្នែកអប់រំវិទ្យាសាស្ត្រ នៅខេត្តតាកែវ

“SITUATION OF RESOURCE AND NETWORK SCHOOLS MANAGEMENT ON SCIENCE EDUCATION IN TAKEO PROVINCE”

**ស៊ុំ សុខឿន**

**SUM SOKHOEUN**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ**

**ជំនាន់ទី៨**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២១**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និង សាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅ ខេត្តតាកែវ

# "SITUATION OF RESOURCE AND NETWORK SCHOOLS MANAGEMENT ON SCIENCE EDUCATION IN TAKEO PROVINCE"


**ស៊ុំ សុខឿន/SUM SOKHOEUN**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ**

**ជំនាន់ទី៨**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២១**

**សាស្ត្រាចារ្យដឹកនាំ ៖ លោក លឹម វ៉ាន់**

**សាស្ត្រាចារ្យដឹកនាំរង៖ បណ្ឌិត នួន វីរ៉ា**

# សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា"**ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាននិងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានអប់រំគឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយឡើយទេ។ គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។និក្ខេបបទស្រាវជ្រាវនេះពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឆ្លូវ ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ វិច្ឆិកា ឆ្នាំ២០២១

**ហត្ថលេខាបេក្ខជន**

**ស៊ុំ សុខឿន**

# លិខិតបញ្ជាក់

**លោក លឹម វ៉ាន់** ជាសាស្ត្រាចារ្យដឹកនាំ
**លោកបណ្ឌិត នួច វីរ៉ា** ជាសាស្ត្រាចារ្យដឹកនាំរង

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

**លោក ស៊ុំ សុខឿន** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ "**ស្ថានភាពនៃការការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ**"ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឆ្លូវ ព.ស២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១

| | |
|---|---|
| ....................................... | ..................................... |
| **លោក លឹម វ៉ាន់** | **លោកបណ្ឌិត នួច វីរ៉ា** |
| អនុប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ | នាយករង |
| វិទ្យាស្ថានជាតិអប់រំ | វិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣២០៥ អយក. [illegible]

(ការសម្គាល់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ុប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។/

ថ្ងៃ ពុធ ៦កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

"ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ដែលបានរៀបចំ និងផ្ដល់អាហារូបករណ៍ដល់ខ្ញុំបាទបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេសខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់លោកសាស្ត្រាចារ្យដឹកនាំ **លឹម វ៉ាន់** ដែលតែងតែចំណាយពេលវេលាមកពន្យល់ខ្ញុំបាទគ្រប់ជំហានទើបធ្វើឲ្យការស្រាវជ្រាវរបស់ខ្ញុំនាពេលនេះទទួលបានជោគជ័យនិងភាពរលូន។ជាមួយគ្នានេះដែរខ្ញុំក៏សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យដឹកនាំរង **បណ្ឌិត នួច ទីវ៉ា** និងមិត្តរួមជំនាន់ទី ៨ ទាំងអស់ដែលតែងតែផ្ដល់ជាគំនិតល្អៗ និងកម្លាំងចិត្តតាមរយៈការចែករំលែក ចំណេះដឹង បទពិសោធន៍ ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទ ដើម្បីឲ្យការស្រាវជ្រាវនេះមានភាពងាយស្រួល

បន្ថែមពីនេះទៀតខ្ញុំសូមថ្លែងអំណរគុណដល់ លោកឪពុក អ្នកម្ដាយ បងប្អូន និងភរិយារបស់ខ្ញុំ ដែលបានផ្ដល់នូវពេលវេលា ប្រាក់កាស និងតែងតែជំរុញ និងលើកទឹកចិត្តដើម្បីឲ្យខ្ញុំបន្តការសិក្សារហូតបានបញ្ចប់នូវថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។ ខ្ញុំក៏សូមឧទ្ទិសនូវស្នាដៃនៃការសិក្សាស្រាវជ្រាវនេះជូនចំពោះលោកតា ជូ ស៊ុំ ដែលបានបែកកាយទៅកាន់លោកខាងមុខហើយក្ដីសុខ សូមឲ្យលោកតាទទួលបាននូវអ្វីដែលជាការខិតខំបណ្ដុះបណ្ដាលចៅឲ្យមានថ្ងៃនេះផងចុះ។

ជាទីបញ្ចប់ខ្ញុំសូមប្រសិទ្ធពរជូនចំពោះ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងក្រុមគ្រួសារ និងភរិយាខ្ញុំបាទឲ្យជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មាតិកា

**ខ្លឹមសារ** **ទំព័រ**

**សេចក្តីអះអាងរបស់បេក្ខជន** ... i

**លិខិតបញ្ជាក់** ... ii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការពារនិក្ខេបបទ** ... iii

**សេចក្តីថ្លែងអំណរគុណ** ... vi

**មាតិកា** ... vii

**បញ្ជីតារាង** ... xii

**បញ្ជីរូបភាព** ... xiii

**មូលន័យសង្ខេប** ... xiv

Abstract ... xvi

**ជំពូកទី១៖ សេចក្តីផ្តើម** ... 1

១.១. សាវតារ ... 1

១.២.ចំណោតបញ្ហានៃការស្រាវជ្រាវ ... 4

១.៣. គោលបំណងនៃការស្រាវជ្រាវ ... 5

១.៤.សំណួរស្រាវជ្រាវ ... 5

១.៥.សារៈសំខាន់នៃការស្រាវជ្រាវ ... 7

១.៦.ដែនកំណត់នៃការស្រាវជ្រាវ ... 8

១.៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ... 8

**ជំពូកទី២៖ រំលឹកទ្រឹស្តី** .......... 10

២.១. និយមន័យ .......... 10

២.២. ការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍ .......... 11

២.៣. ការគ្រប់គ្រង និងាការប្រើប្រាស់សម្ភារបច្ចេកវិទ្យា(ICT) .......... 12

២.៤. ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណល័យ .......... 13

២.៤.១.សារៈសំខាន់បណ្ណាល័យ .......... 13

២.៤.២.ការគ្រប់បណ្ណាល័យ .......... 14

២.៥. ការគ្រប់គ្រងសៀវភៅសិក្សាគោល .......... 16

២.៥.១. គោលបំណង និងវត្ថុបំណងនៃការផ្តល់សៀវភៅសិក្សាគោល .......... 18

២.៥.២.លទ្ធភាពដើម្បីទទួលបានសៀវភៅអប់រំ .......... 19

២.៥.៣. គុណភាពនៃសៀវភៅអប់រំ .......... 21

២.៥.៤.ការគាំទ្រសៀវភៅសិក្សា .......... 23

២.៦.គោលបំណងរបស់សាលាមធ្យមសិក្សាធនជាន .......... 24

២.៧.ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនជាន .......... 27

២.៧.១. ចំពោះសិស្ស .......... 27

២.៧.២.ចំពោះបុគ្គលិកអប់រំ .......... 27

២.៧.៣. ចំពោះមាតាបិតា និងអាណាព្យាបាលសិស្ស .......... 28

២.៧.៤. ចំពោះសាលារៀន .......... 28

២.៧.៥. ចំពោះសាលារៀនក្នុងបណ្តាញ .......... 29

២.៨.លក្ខណៈវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាន ....................................................................29

២.៩.បណ្ដាញសាលាមធ្យមសិក្សាធនធាន....................................................................................30

២.១០.ការគ្រប់គ្រង និងដំណើរការសាលាមធ្យមសិក្សាធនធាន ..................................................33

២.១០.១. ធនធានមនុស្សរបស់សាលាមធ្យមសិក្សាធនធាន ...............................................36

២.១០.២. ការគាំទ្រសាលាមធ្យមសិក្សាធនធានចំពោះសាលាមធ្យមសិក្សាបណ្ដាញ................36

២.១១. ភារៈកិច្ចរបស់សាលាមធ្យមសិក្សាធនធាន ...................................................................38

២.១១.១. គោលបំណងរបស់សាលាមធ្យមសិក្សាធនធាន..................................................39

២.១១.២. ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវ័ន្ត ..........................................................................40

២.១១. ៣.ការគាំទ្រ និងទទួលស្គាល់............................................................................................ 41

២.១១.៤. ធនធានរបស់សាលាមធ្យមសិក្សាធនធាន.......................................................................42

២.១១.៥. បរិស្ថាន........................................................................................................................47

២.១១.៦. ការបណ្ដុះបណ្ដាល និងការសិក្សារបស់សិស្ស...................................................................50

២.១១.៧. គណៈកម្មការ និងក្រុមប្រឹក្សានានា ................................................................................52

២.១១.៨. តារាងរចនាសម្ព័ន្ធរបស់សាលាធនធាន ..........................................................................63

**ជំពូកទី៣៖វិធីសាស្ត្រនៃការស្រាវជ្រាវ**.....................................................................................66

៣.១. ព័ត៌មានទូទៅនៃការស្រាវជ្រាវ..............................................................................................66

៣.២.ទីកន្លែងសិក្សាស្រាវជ្រាវ ......................................................................................................66

៣.៣. ក្រុមគោលដៅ .......................................................................................................................67

៣.៤.ទំហំសំណាក..........................................................................................................................68

៣.៥.វិធីសាស្ត្រនៃការស្រាវជ្រាវ ........ 69

៣.៦.ការជ្រើសរើសសំណាក ........ 70

៣.៧.ឧបករណ៍ស្រាវជ្រាវ ........ 71

៣.៨.កម្រងសំណួរ និងគោលបំណង ........ 72

**ជំពូកទី៤៖លទ្ធផល និងការពិភាក្សា** ........ 75

៤.១. ការវិភាគលើទិន្នន័យសម្រាប់គ្រូបង្រៀន ........ 75

៤.២.សំណួរស្រាវជ្រាវទី១(ការចង្អុលបង្ហាញរបស់គ្រូ) ........ 76

៤.២.១. ការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍ ........ 76

៤.២.២.ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សា ........ 77

៤.២.៣.ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារបច្ចេកវិទ្យា ........ 79

៤.២.៤. ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោល ........ 80

៤.២.៥.ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស ........ 81

៤.២.៦.ការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកា ........ 84

៤.៣.ការវិភាគកម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀន ........ 86

៤.៤.សំណួរស្រាវជ្រាវទី១ ........ 87

៤.៤.១. វត្ថុបំណងគោលនយោបាយអប់រំសាលារៀន ........ 88

៤.៤.២.ការគ្រប់គ្រងបន្ទប់ពិសោធន៍ ........ 89

៤.៤.៣. ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ ........ 90

៤.៤.៤.ការគ្រប់គ្រងបណ្ណាល័យ ........ 91

៤.៤.៥.កិច្ចគាំទ្រការបង្រៀន និងបង្រៀន ....................................................................92

៤.៤.៦.កិច្ចសហប្រតិបត្តិការ....................................................................................93

៤.៤.៧.ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍...............................................................94

៤.៥.លទ្ធផលនៃការពិភាក្សាលើកម្រងសំណួរទី១.............................................................96

៤.៥.១.ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញនៅខេត្តតាកែវ................96

៤.៦.បញ្ហាលំបាក និងបញ្ហាប្រឈមរបស់គណៈគ្រប់គ្រងសាលារៀន.........................................99

**ជំពូកទី៥៖សេចក្តីសន្និដ្ឋាន និងសំណូមពរ**.................................................................102

៥.១. សេចក្តីសន្និដ្ឋាន..................................................................................102

៥.១.១សេចក្តីសន្និដ្ឋានលើសំណួរស្រាវជ្រាវទី១ ...............................................................102

៥.២. សេចក្តីសន្និដ្ឋានលើសំណួរស្រាវជ្រាវទី២..................................................................105

៥.៣.សំណូមពរ ..........................................................................................108

ឯកសារយោង ..........................................................................................109

ឧបសម្ព័ន្ធ ..............................................................................................111

ឧបសម្ព័ន្ធទី១៖ កម្រងសំណួរស្រាវជ្រាវសម្រាប់គ្រូបង្រៀន ..................................................111

ឧបសម្ព័ន្ធ២៖កម្រងសំណួរស្រាវជ្រាវសម្រាប់គ្រូគណៈគ្រប់គ្រងសាលារៀន..................................119

ឧបសម្ព័ន្ធ៣៖លិខិតឧទ្ទេសនាមបំណែងចែកគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរង ............................125

ឧបសម្ព័ន្ធ៤៖លិខិតជូនដំណឹងទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ...............................128

ឧបសម្ព័ន្ធ៥៖ឧបសម្ព័ន្ធទី៥៖ លិខិតឧទ្ទេសនាមគណៈមេប្រយោគសម្រាប់ការពារនិក្ខេបបទ............ 129

# បញ្ជីតារាង

តារាងទី៣.៣.១៖ក្រុមគោលដៅ និងអ្នកចូលរួម ........ 67

តារាងទី៣.៣.២៖កម្រិតវប្បធម៌គ្រូបង្រៀន ........ 68

តារាងទី៣.៣.៣៖បទពិសោធន៍ការងារ ........ 68

តារាងទី៤.២.១៖ ការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍ ........ 76

តារាងទី៤.២.២៖ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សា ........ 77

តារាងទី៤.២.៣៖ ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា ........ 79

តារាងទី៤.២.៤.៖ ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោល ........ 80

តារាងទី៤.២.៥៖ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស ........ 81

តារាងទី៤.២.៦៖ការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកា ........ 84

តារាងទី៤.៤.១៖ វត្ថុបំណងគោលនយោបាយសាលារៀន ........ 88

តារាងទី៤.៤.២៖ ការគ្រប់គ្រងបន្ទប់ពិសោធន៍ ........ 89

តារាងទី៤.៤.៣៖ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ ........ 90

តារាងទី៤.៤.៤៖ការគ្រប់គ្រងបណ្ណាល័យ ........ 91

តារាងទី៤.៤.៥៖កិច្ចគាំទ្រការបង្រៀន និងរៀន ........ 92

តារាងទី៤.៤.៦.៖ កិច្ចសហប្រតិបត្តិការ ........ 93

តារាងទី៤.៤.៧៖ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ ........ 94

តារាងទី៥.៥.១៖ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញ ........ 96

# បញ្ជីរូបភាព


រូបភាពទី១៖គន្លួសតាងបណ្តាញសាលាមធ្យមសិក្សាធនធាន ....................................................32

តារាងទី២៖នាក់នងរវាងគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញ ................35

# មូលន័យសង្ខេប

ប្រព័ន្ធអប់រំមួយរីកចម្រើនទៅបានអាស្រ័យទៅដោយការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងនោះដែរគណៈគ្រប់គ្រងសាលារៀនគឺជាចំណែកមួយដ៏ចាំបាច់បំផុតដែលមិនអាចខ្វះបាន និងមានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងគ្រប់គ្រង ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពអប់រំ។ សាលាធនធាន និងសាលាបណ្តាញ គឺជាសាលាដៃគូដែលមានការសហការជាមួយគ្នានឹងគ្នាយ៉ាងខ្ជាប់ខ្ជួនក្នុងការពង្រឹងសមត្ថភាពចំណេះដឹងក៏ដូចជាការចូលរួមចែករំលែកបទពិសោធន៍ក្នុងតួនាទីជាអ្នកដឹកនាំ និងគ្រប់គ្រង ដើម្បីឲ្យសាលារៀននីមួយៗនៅក្នុងបណ្តាញអាចដំណើរការបានទៅមុខយ៉ាងរលូន និងមានភាពល្អប្រសើរដើម្បីលើកកម្ពស់គុណភាពអប់រំ និងផ្តល់ចំណេះដឹងដល់សិស្សានុសិស្សគ្រប់ៗគ្នា និងការទំនាក់ទំនងរវាងសាលាធនធាន និងសាលាបណ្តាញគឺមានគោលបំណងផ្តោតយ៉ាងសំខាន់ទៅលើការដំណើរការអគារធនធាន ជាពិសេសលើផ្នែកអប់រំវិទ្យាសាស្ត្រ។ វិទ្យាល័យដែលមានអគារធនធានស្ថិតនៅ គឺជាសាលាមធ្យមសិក្សាធនធាន ហើយមានចក្ខុវិស័យគឺកសាង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ដ៏ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ការសិក្សាស្រាវជ្រាវនេះមានបំណងស្វែងយល់ពី៉ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាននិងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ។ គោលបំណងនៃការសិក្សាស្រាវជ្រាវនេះគឺ ដើម្បីស្វែងយល់ពីការបំពេញការរបស់គណៈគ្រប់គ្រងសាលាមធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រ និងសិក្សាពីបញ្ហាប្រឈមរបស់គណៈគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញ។ ការសិក្សាស្រាវជ្រាវនេះពិតជាមានសារៈសំខាន់ណាស់ ក្នុងការធ្វើ ឱ្យប្រសើរឡើងនូវការបំពេញការងាររបស់គណៈគ្រប់គ្រងសាលាដើម្បីចូលរួមចំណែកក្នុងកំណែទម្រង់វិស័យអប់រំ ជាពិសេសផ្នែកអប់រំវិទ្យាសាស្ត្រ ក៏ដូចជាកំណែទម្រង់គុណភាពនាយក គ្រូបង្រៀន ដែលធ្វើឱ្យសិស្សទទួលបាននូវលទ្ធផលនៃការសិក្សាល្អប្រសើរ ឆ្លើយតបទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវ ក៏ដូចជាឆ្លើយតបតាមតម្រូវការរបស់សង្គមជាតិ ដែលបានបង្កើតឱ្យមានប្រព័ន្ធអប់រំពលរដ្ឋពេញលេញ។ លើសពីនេះទៀត ការសិក្សាស្រាវជ្រាវនេះ ក៏មានសារៈសំខាន់សម្រាប់អ្នកស្រាវជ្រាវនាពេលអនាគត ដែលពាក់ព័ន្ធនឹងប្រធាន

បទខាងលើ និងពាក់ព័ន្ធនឹងស្ថានភាពអប់រំក្នុងពេលបច្ចុប្បន្ន។ លទ្ធផលនៃការស្រាវជ្រាវក៏នឹងជូនដំណឹងដល់អ្នកអប់រំ ជាពិសេសគណៈគ្រប់គ្រង ដើម្បីបន្តពង្រឹងនិង ចូលរួមក្នុងការបំពេញការងារ ដើម្បីភាពប្រសើរឡើងជាបន្តបន្ទាប់ក្នុងបរិបទបច្ចុប្បន្ន របស់កំណែទម្រង់ការអប់រំ និងការផ្លាស់ប្តូរឥរិយាបថរបស់នាយកសាលាចំពោះការបំពេញការងារ ក៏ដូចជាគ្រូបង្រៀន ត្រូវមានការផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមកដើម្បីជំរុញឱ្យប្រសើរឡើងនៃលទ្ធផលសិក្សារបស់សិស្ស។ ការសិក្សាលើប្រធានបទ «ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ។ វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ការប្រមូលទិន្នន័យគឺបានចុះទៅជួបផ្ទាល់ដើម្បីស្នើរសុំក្នុងការបពេញកម្រងសំណួរ ក៏ដូចជាសម្ភាសន៍ផ្ទាល់នៅសាលាធនធានទាំង២ និងសាលាបណ្តាញចំនួន៦ក្នុងចំណោមសាលាបណ្តាញទាំង១១ក្នុងខេត្តតាកែវ ដែលមានចំនួនសំណាកសរុប ៨៤នាក់ រួមមានគ្រូបង្រៀនថ្នាក់វិទ្យាសាស្ត្រចំនួន៦០នាក់ គណៈគ្រប់គ្រងសាលារៀននិងបរិច្ចការីបន្ទប់ពិសោធន៍ចំនួន២៤នាក់។ ការវិភាគទិន្នន័យផ្អែកលើការកចង្អុលបង្ហាញ និងកម្រិតបង្ហាញចំនួន ៥កម្រិត ដែលត្រូវបានគណនាជាមួយ រូបមន្តជាក់លាក់។

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្ររបស់នាយកសាលាមិនទាន់បានល្អគ្រប់គ្រាន់នោះទេ ក៏តម្រូវឱ្យលោកគ្រូ-អ្នកគ្រូ យកចិត្តទុកដាក់នៅលើការបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ក៏ដូចជាមុខវិជ្ជាផ្សេងៗទៀត ដើម្បីធ្វើឱ្យអង្គភាពមួយមានភាពរលូនទៅមុខ ហើយម្យ៉ាងទៀតលទ្ធផលសិក្សារបស់សិស្សទទួលបានភាពវិជ្ជមាន ឬអវិជ្ជមានអាស្រ័យលើការចូលរួមពីដំណើរការសិក្សារបស់សិស្សគ្រប់រូបផងដែរ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញពីបញ្ហាប្រឈមមួយចំនួនទាក់ទងទៅនឹង ចំណេះដឹងគ្រូក្នុងការប្រើប្រាស់បច្ចេកវិទ្យានៅមានកម្រិត គ្រូបង្រៀនថ្នាក់វិទ្យាសាស្ត្រមិនសហការគ្នាឲ្យបានល្អប្រសើរជាមួយអ្នកទទួលបន្ទុកបន្ទប់ពិសោធន៍ និងអ្នកទទួលបន្ទុកបន្ទប់ពិសោធន៍មិនមានជំនាញច្បាស់លាស់ក្នុងការធ្វើពិសោធផងដែរ។

**Abstract**

The development of an education system depends on the participation of all stakeholders in which the school management is one of the most indispensable and important part of leadership and management to improve quality and educational effectiveness Resource School an Network School are partner school work closely with each other to strengthen their knowledge and skills as well as to share experiences in leadership and management for each other in the network going smoothly and well to improve the quality of education and provide knowledge to all students and the relationship between the resource school and the network school is aimed at focusing on the operation of the resource building, especially in the field of science education. The high schools where the resource building is located is a secondary school and the vision is to build and develop human resources with the best quality and virtues in all areas to build this research arms to understand the status of the management of resource school and network schools on science education in Takeo province. The purpose of this study was to understand the performance of resource and network schools' management in field of science education and to study the challenges of resource and networks schools' management. This research is very important to improve the performance school's management to contribute to education reform, especially in the field of science education, and as well as the reform of the quality of teachers which enables students to achieve better academic results, respond to research problems as well as meet the needs of society. A nation that has established a complete civic education system. In addition, this research is al so important for further researchers related to that above topic and related to the current education situation. The result of the research will also inform educators, especially management, continue to strengthen and participate in performance for continuous improvement in the current context of education reform and change attitude of principals towards performance. For example, teachers need to exchange ideas with each other to improve students' achievement. Study on the topic'' Status of resource and network schools' management on science education in Takeo province. Quantitative and qualitative research methods. Data were collected in person to request a questionnaire as well as face-to- face interviews at two resource school and six of the 11 network school in Takeo province with a total sample of 84 people, including 60 science teachers, school management and laboratory stall 2. Data analysis was based on five indicators and levels calculated with specific formulas.

According to the results of the study the situation of the management of resource and network schools on science education of the principal is not good enough, also requires science teachers to pay attention to teaching science subjects as well. Other subjects to make a unit run smoothly and on the other hand, students 'learning outcomes are positive or negative depending on the participation of every student in the learning process. The results of the research show that

some of the challenges related to the knowledge of teachers in the use of technology still limited, science teachers do not cooperate well with those in charge of the laboratory and those in charge of the laboratory are not very clear in the experiment as well.

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១- សាវតារ

សង្គមជាតិមួយមានការរីកចម្រើនឿនលឿនទៅមុខបាន គឺដោយសារសង្គមជាតិនោះ ពោពេញទៅដោយពលរដ្ឋមានចំណេះដឹង ចំណេះធ្វើ ពោលគឺពលរដ្ឋរបស់ពួកគេបានចូលរួមមកទទួលការអប់រំនៅក្រោមដំបូលសាលារៀនរួមជាមួយលោកគ្រូ/អ្នកគ្រូ ដែលប៉ិនប្រសព្វក្នុងការផ្ទេរពុទ្ធិ បានផ្លាស់ប្តូអកប្បកិរិយា ឬឥរិយាបថរបស់អ្នកសិក្សា ជាវិជ្ជមានហើយជាអចិន្ត្រៃ។ ទស្សនវិស័យនៃការអភិវឌ្ឍរបស់កម្ពុជាគឺក្លាយជាប្រជាជាតិដែលមានចំណូលមធ្យមកម្រិតខ្ពស់ ប្រកបដោយវិបុលភាពត្រឹមឆ្នាំ២០៣០។ ដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលកមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៥០ និងប្រែក្លាយប្រទេសនេះទៅជាសង្គមពុទ្ធិ ប្រកបដោយសុខសន្តិភាពនិងលិទ្ធិប្រជាធិបតេយ្យ ដែលកាន់តែមានសមត្ថភាពប្រកួតប្រជែងនៅថ្នាក់តំបន់ និងអន្តរជាតិ (ផែនទី២០១៩)។ ក្នុងន័យនេះ គឺរដ្ឋត្រូវការអ្នកដឹកនាំដែលមានឧត្តមគតិខ្ពស់ និងមានចំណេះដឹង ជំនាញវិជ្ជាជីវៈក្នុងការដឹកនាំ និងមានមនៈសិកាស្នេហាជាតិ ដើម្បីក្លាយជាអ្នកដឹកនាំគម្រូដែលមានស្មារតី និងមានទំនួលខុសត្រូវខ្ពស់ក្នុងការដឹកនាំ និងកសាងប្រទេសជាតិឲ្យមានភាពរីកចម្រើនរុងរឿងសម្រាប់ជាតិសាស្ត្រយើងទាំងមូល ក៏ដូចជានៅថ្នាក់តំបន់ និងអន្តរជាតិផងដែរ។ ក្រៅពីនេះរដ្ឋក៏ត្រូវការសាលារៀន ត្រូវការអគារ ដើម្បីបង្កើតឱកាសក្នុការសិក្សាគ្រប់បរិបទ និងគ្រប់ទំរង់ ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការសម្រាប់ប្រជាពលរដ្ឋគ្រប់វិស័យទាំងអស់។ ចក្ខុវិស័យរបស់សាលារៀនកម្ពុជាឆ្នាំ២០៣០ គឺជាគ្រឹះស្ថានសិក្សា ដែលធានាបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា(ផែនទី២០១៩)។ សាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាល នឹងហិរញ្ញវត្ថុ និងមានគណនេយ្យភាពក្នុងការសម្រេចបាននូវលទ្ធផលសិក្សាប្រកបដោយគុណភាពខ្ពស់ទាំងអស់គ្នា។ សាលារៀននឹងទទួលបានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ និងការលើកទឹកចិត្ត ហើយមានអ្នកដឹកនាំការងារបង្រៀនប្រកបដោយចក្ខុវិស័យ និងផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាព អនាម័យ ឆ្លើយតបចំពោះយេនឌ័រ បរិយាបន្ន និងការ

រៀននិងបង្រៀនប្រកបដោយគុណភាពខ្ពស់ ដោយប្រើប្រាស់បច្ចេកវិទ្យាជំនួយ។ ដូចគ្នានេះដែរ ចក្ខុវិស័យសម្រាប់បន្ទប់រៀនកម្ពុជាឆ្នាំ២០៣០គឺជាបន្ទប់រៀនវៃឆ្លាតដែលផ្តល់ឲ្យសិស្សនូវឱកាសល្អផុតសម្រាប់ការរៀនសូត្រ(ផែនទី២០១៩)។ បន្ទប់រៀនកម្ពុជាត្រូវប្រែក្លាយជាបណ្តើរៗទៅជាបន្ទប់រៀនវៃឆ្លាត ដោយបំពាក់ធនធានអប់រំ និងបច្ចេកវិទ្យា ដើម្បីផ្តល់នូវបរិយាកាសសិក្សាដែលមានការរៀបចំដោយប្រយ័ត្នប្រយែង មានសុវត្ថិភាព និងមានលក្ខណៈអំណោយផលសម្រាប់ការសិក្សាសម្រាប់ទាំងអស់គ្នា។ គ្រូបង្រៀននឹងប្តូរតួនាទីទៅជាអ្នកសម្របសម្រួលការរៀនសូត្រ ដោយបំពេញតួនាទីជាអ្នកបង្កើតឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នា តាមការប្រើប្រាស់វិធីសាស្រ្តបង្រៀនបែបអន្តរកម្ម និងបែបសហការ និងវិធីសាស្រ្តចម្រុះ។

ប្រទេសកម្ពុជាបាននិងកំពុងឆ្លងកាត់សម័យកាលសកលភាវូនីយកម្ម និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍អាស៊ាន ជាកត្តាចាំបាច់កម្ពុជាត្រូវធានាឲ្យបាននូវការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមភាព។ ប្រការនេះទាមទារឲ្យប្រទេសកម្ពុជាមានសមត្ថភាពក្នុងការទទួលយកបាននិងប្រើប្រាស់ចំណេះដឹងនិងនវានុវត្តន៍ដែលផ្អែកលើវិទ្យាសាស្រ្ត និងបច្ចេកវិទ្យា។ វិទ្យាសាស្រ្តផ្តល់ដល់យើងនូវលទ្ធភាពក្នុងការបង្កើតនូវកាលានុវត្តភាពនិងវេទិកាថ្មីៗសម្រាប់បច្ចេវិទ្យាថ្មីៗ និងកាន់តែជឿនលឿនជាងមុន។ ដោយហេតុនេះហើយ កម្ពុជាត្រូវការបណ្តុះបណ្តាលអ្នកជំនាញវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាជាច្រើនបន្ថែមទៀត។អគារធនធានគឺជាអគារសិក្សាមួយដែលគាំទ្រដល់កម្មវិធីស្ទែម(STEM) ពីព្រោះក្នុងអគារធនធានមានបន្ទប់ពិសោធន៍វិទ្យាសាស្រ្តសម្រាប់បួនមុខវិជ្ជាគឺ(១)បន្ទប់ពិសោធន៍រូបវិទ្យា (២)បន្ទប់ពិសោធន៍គីមីវិទ្យា (៣) បន្ទប់ពិសោធន៍ជីវវិទ្យា (៤) បន្ទប់ពិសោធន៍ផែនដីវិទ្យា រួមទាំងមានបន្ទប់កុំព្យូទ័រចំនួនពីរ និងបណ្ណាល័យចំនួនមួយ។ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឲ្យអនុវត្តន៍គោលនយោបាយស្តីពីកាអប់រំវិទ្យាសាស្រ្ត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពសិស្ស និស្សិត និងអភិវឌ្ឍន៍ធនធានមនុស្សដែលមានសមត្ថភាព និងការទទួលខុសត្រូវ ក្នុងផ្នែកវិទ្យាសាស្រ្តបច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា សម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយបរិយាបន្ន និងចីរភាព(ក្រសួងអប់រំ២០១៨)។

សាលាមធ្យមសិក្សាធនធាន គឺជាសាលាមធ្យមសិក្សាមួយនៅស្រុក/ខណ្ឌឬខេត្ត/ក្រុង ដែលត្រូវបានជ្រើសរើសឡើង ដើម្បីនាំមុខក្នុងការធ្វើឲ្យសាលារៀនមានការរីកចម្រើនគ្រប់ផ្នែក ជាពិសេសការអនុវត្តកម្មវិធីសិក្សា និងលទ្ធផលសិក្សា។ សាលាមធ្យមសិក្សាធនធាន នឹងក្លាយជាសាលារៀននាំមុខក្នុងបណ្តាញសាលាមធ្យមសិក្សាដែលមានក្នុងមូលដ្ឋាន។

សាលាមធ្យមសិក្សាដែលកំណត់ជាសាលាមធ្យមសិក្សាធនធាន គឺជាសាលាដែលបានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារបរិក្ខារ (អគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្តាញទឹកបណ្តាញភ្លើង...) និងបណ្តុះបណ្តាលការប្រើប្រាស់សម្ភារបរិក្ខារទាំងនេះ។ សាលាបធ្យមសិក្សាធនធាននឹងចែករំលែកបទពិសោធ ក្នុងការប្រើប្រាស់ធនធានទាំងនោះចំពោះសាលារៀនក្នុងបណ្តាញរបស់ខ្លួន។ សាលាមធ្យមសិក្សាធនធាននឹងលើកកម្ពស់វិជ្ជាជីវៈគ្រូ ចែករំលែកបទពិសោធន៍ក្នុងការបង្រៀន និងរៀន ការងារគ្រប់គ្រង ណែនាំកសាង និងអនុវត្តន៍ផែនការអភិវឌ្ឍសាលារៀន និងអភិវឌ្ឍន៍សមត្ថភាពគ្រូ។

សាលាមធ្យមសិក្សាធនធាននឹងក្លាយជាសមសភាគដ៏រឹងមាំមួយនៃយុទ្ធសាស្ត្រគន្លឹះរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឲ្យសាលាមធ្យមសិក្សាអភិវឌ្ឍន៍តាមរយៈភាពជាអ្នកដឹកនាំ នៃសាលាមធ្យមសិក្សាក្នុងបណ្តាញ។ ការគ្រប់គ្រង គឺជាដំណើរការនៃអង្គការចាត់តាំងមួយដែលមានប្រសិទ្ធិភាព។ ការគ្រប់គ្រង គឺជាការទទួលខុសត្រូវមួយដ៏លំបាក ដែលវាទាមទារឲ្យអ្នកគ្រប់គ្រងចាំបាច់ត្រូវមានសមត្ថភាពយល់ដឹងខ្ពស់ រហ័សរហួនប្រកបដយភាពប៉ិនប្រសព្វ និងមានចំណេះដឹងទូលំទូលាយ។ បើទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅមានអ្នកគ្រប់គ្រងខ្លះទទួលបានជោគជ័យ ហើយអ្នកគ្រប់គ្រងខ្លះបរាជ័យផងដែរ។ អ្នកគ្រប់គ្រងគឺជាអ្នកដែលធ្វើឲ្យកិច្ចការត្រូវបានគេដាក់ឲ្យធ្វើ និងកិច្ចការដែលដាក់ដោយខ្លួនឯង សម្រេចតាមរយៈមនុស្សផ្សេងទៀត។ ពួកគេបង្កើតការសម្រេចចិត្ត បែងចែកធនធាន និងដឹកនាំសកម្មភាពរបស់អ្នកដ៏ទៃឲ្យចូលរួមសម្រេចគោលដៅមួយ។អ្នកគ្រប់គ្រងធ្វើការនៅក្នុងអង្គភាពមួយដែលធ្វើការយ៉ាងស្និតជាមួយសង្គមរាប់ចាប់ពីមនុស្សពីរនាក់ ឬច្រើននាក់ រួមគ្នាធ្វើការប្រទាក់ក្រឡាគ្នាដើម្បីបន្តសម្រេចគោលដៅរួមមួយ ឬគោលដៅច្រើនទៀត។ អ្នកដែលឃ្លាំមើលសកម្មភាពទាំងអស់របស់អ្នកដ៏ទៃ និងអ្នកដែល

ទទួលខុសត្រូវក្នុងការសម្រេចគោលដៅនៅក្នុងអង្គភាពគឺជាអ្នកគ្រប់គ្រង (ពេលខ្លះគេហៅថា អ្នកចាត់ការ ឬអភិបាល ដែលភាគច្រើនប្រើក្នុងអង្គភាពមិនស្វែងរកប្រាក់ចំណេញ។ មូលហេតុដែលអ្នកគ្រប់គ្រងធ្វើការគ្រប់គ្រងនៅស្ថាប័នការងារ មានការអន់ថយ ព្រោះអ្នកគ្រប់គ្រងមានការខ្វះខាតក្នុងការគ្រប់គ្រង គ្មានការរៀបចំរចនាសម្ព័ន្ធនៃការចាត់តាំងនៅក្នុងស្ថាប័ន តួនាទីរបស់បុគ្គលិក ខ្វះទំនាក់ទំនងរវាងបុគ្គលិក និងអ្នកគ្រប់គ្រងរបៀបរបបពីថ្នាក់លើមកថ្នាក់ក្រោមគ្មានភាពច្បាស់លាស់ ការធ្វើផែនការគ្មានការចូលរួមពីបុគ្គលិក ធ្វើការសម្រេចចិត្តដោយឯកឯង គ្មានការសម្រេចចិត្ត គ្មានភាពស្និតស្នាល គ្មានការលើកទឹកចិត្ត ឬគ្មានការកោតសរសើរបុគ្គលោកឲ្យខិខំប្រឹងប្រែងធ្វើការ ធ្វើឲ្យគោលដៅមិនបានសម្រេច...។ ការគ្រប់គ្រងដែលល្អមិនត្រូវធ្វើអ្វីដោយអត្តនោម័ត្តតាមការយល់ឃើញរបស់ខ្លួននោះទេ ត្រូវចេះស្តាប់យោបល់របស់សមាជិក ត្រួតពិនិត្យរាល់របាយការជាប្រចាំ និងត្រូវពិនិត្យរាល់របាយការចំណាយ ចណូលរបស់ស្ថាប័ន។ មូលហេតុដែលអ្នកគ្រប់គ្រងធ្វើការគ្រប់គ្រងបានល្អនៅកន្លែងការងារព្រោះអ្នកគ្រប់គ្រងបានរៀបចំធ្វើរចនាសម្ព័ន្ធនៃការចាត់តាំងតួនាទីច្បាស់លាស់ពីថ្នាក់លើមកដល់ថ្នាក់ក្រោម មានការប្រជុំយ៉ាងទៀងទាត់ មានការចូលរួមពីសំណាក់បុគ្គលិកដោយរួមគ្នាធ្វើផែនការរួម និងសម្រេចការងាររួមគ្នាបង្កើតឲ្យមានភាពស្និតស្នាល និងមានរង្វាន់លើកទឹកចិត្តដល់បុគ្គលិកឆ្នើម កោតសរសើរចំពោះបុគ្គលិកដ៏ទៃទៀតជាបុគ្គលិកគម្រូមិនឆ្នើម ទទួលយលរាល់ការរិះគន់ ដើម្បីស្ថាបនា និងសម្រេចគោលដៅរបស់ស្ថាប័នដោយជោគជ័យ។

## ១.២- ចំណោទបញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃក្រសួងអប់រំ យុវជន និងកីឡាកំពុងយកចិត្តទុកដាក់ធ្វើកំណែទម្រង់វិស័យអប់រំដើម្បីធ្វើឲ្យវិស័យអប់រំនៅកម្ពុជា មានការរីចម្រើននិងមានសក្តានុពលភាពទាំងនៅក្នុងតំបន់និងនៅលើសកលលោក។ មិនត្រឹមតែប៉ុណ្ណោះ យើងឃើញថា ក្រសួងអប់រំ យុវជន និងកីឡា សម័យបច្ចុប្បន្នបានបង្កើតសាលាមធ្យមសិក្សាធនធាន ដែលមានអគាធនធាននៅក្នុងនោះ ដើម្បីគាំទ្រកម្មវិធីស្ទែម(Stem)។ សាលាមធ្យមសិក្សាធនធាន គឺជាសាលាមធ្យមសិក្សាមួយនៅក្នុងក្រុង ស្រុក ខណ្ឌ ឬរាជធានី ខេត្ត ដែលត្រូវបានជ្រើរើស ដើម្បីនាំមុខដើម្បីធ្វើឲ្យសាលារៀនមានការរីកចម្រើនគ្រប់ផ្នែក ដូចជាការអនុវត្តកម្មវិធីសិក្សា លទ្ធផលសិក្សាចែករំលែកបទពិសោធន៍ (ការបង្រៀន រៀន ការដឹកនាំ និងការគ្រប់គ្រងគ្រប់ផ្នែកទាំងអស់ដែលមាននៅ

ក្នុងសាលាមធ្យមសិក្សាធនធាន ការប្រើប្រាស់...) ។ សាលាមធ្យមសិក្សាធនធាននឹងក្លាយជា សលាមធ្យមសិក្សានាំមុខក្នុងចំណោមសាលាមធ្យមសិក្សាបណ្តាញដែលមានក្នុងមូលដ្ឋាន (ក្រសួងអបរំ២០១១)។

ជាការពិតណាស់គ្រប់បណ្តាប្រទេសទាំងអស់នៅលើសកលលោកត្រូវការ ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំជាចាំបាច់ដើម្បីធ្វើឲ្យប្រទេសជាតិទាំងមូលមានការរីកចម្រើនរុងរឿងគ្រប់វិស័យ និងមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការអភិវឌ្ឍប្រទេសជាតិ រួមទាំងក្នុងការផលិតបាននូវធនធានមនុស្សប្រកបដោយគុណភាព ប្រសិទ្ធិភាព និងក្របសីលធម៌នោះគេត្រូវពឹងផ្អែកការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំតែមួយគត់។ យ៉ាងណាមិញដើម្បីឲ្យការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញនៅក្នុងប្រទេសកម្ពុជាយើងមានការរីកចម្រើន និងទទួលជោគជ័យប្រកបដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់ទាមទារឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធនានា ដូចជាគណៈគ្រប់គ្រងសាលាតាមលំដាប់ថ្នាក់រួមមាននាយកឬនាយិកាសាលា នាយករងឬនាយិការង ហិរញ្ញឹក បេឡា គណនេយ្យករ ប្រធានក្រុមបច្ចេកទេសតាមមុខវិជ្ជា និងមានការចូលរួមយ៉ាងសកម្មពីលោកគ្រូ អ្នកគ្រូគ្រប់មុខវិជ្ជាទាំងអស់។ នៅក្នុងនោះដែរកត្តាការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងការប្រើប្រាស់ធនធានសិក្សានៅក្នុងអគារធនធានបានត្រឹមត្រូវជាចលករដ៏សំខាន់ក្នុងការចូលរួមយ៉ាងសំខាន់ក្នុងការចូលរួមយ៉ាងសកម្ម ដែលធ្វើឲ្យការគ្រប់មានការរីកចម្រើនប្រកបប្រសិទ្ធភាព។

ក្រៅពីនេះនៅមានចំណុចអសកម្មនៃការគ្រប់គ្រង និងការប្រើប្រាស់ធនធានសិក្សានៅក្នុងអគារធនធានហាក់ដូចជាមិនទាន់ល្អប្រសើរនៅឡើយ ជាក់ស្តែងសាលាមធ្យមសិក្សាធនធាន និងបណ្តាញសាលាមិនទាន់មានការទំនាក់ទំនងគ្នាយ៉ាងរលូន ជាពិសេសនៅក្នុងវិទ្យាល័យមួយចំនួនមានបន្ទប់កុំព្យូទ័រឬកុំព្យូទ័រតិចតួចណាស់ សម្រាប់តម្រូវការសិស្សនិងគ្រូប្រើប្រាស់។ មិនតែប៉ុណ្ណោះទៀតសោតចំណេះដឹងផ្នែកបច្ចេកវិទ្យា ឬព័ត៌វិទ្យារបស់លោកគ្រូ អ្នកគ្រូនៅមានកម្រិតមិនទាន់ឆ្លើយតបបានទៅនឹងការវិវត្តថ្មីៗនៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ននៅឡើយ។ រីឯដំណើរការនៃការប្រើប្រាស់ធនធានសិក្សានៅក្នុងអគារធនធាននៅមានកម្រិតនិងមានបញ្ហាមួយចំនួនដែលទាក់ទងទៅនឹងការធ្វើពិសោធ និងសម្ភារៈសម្រាប់ពិសោធផងដែរ។

ដោយការសង្កេតឃើញនូវតម្រូវការចាំបាច់នៃការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាបណ្ដាញ និងចំនុចអសកម្មមួយចំនួនដែលធ្វើឲ្យមានការរាំងស្ទះដល់ដំណើរការគ្រប់គ្រង ជាហេតុធ្វើឲ្យអ្នកសិក្សាស្រាវជ្រាវសម្រេចចិត្តក្នុងការជ្រើសរើសយកប្រធានបទ ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញលើផ្នែកអប់រំវិទ្យាសាស្ត្រ ដើម្បីយកមកសិក្សាស្រាវជ្រាវនូវស្ថានភាព និងបញ្ហាប្រឈមនានាដែលកើតមានចំពោះសាលាធនធាន និងសាលាបណ្ដាញ ដើម្បីរកចំណុចខ្លាំងនិងចំណុចខ្សោយ ដែលជាចំណុចរសើបរបស់គណៈគ្រប់គ្រង ដើម្បីធ្វើការកែលម្អឲ្យមានគុណភាពក្នុងការដឹកនាំ និងគ្រប់គ្រងឲ្យកាន់តែប្រសើរឡើងដើម្បីជាការប្រកួតប្រជែងរវាងសាលាមធ្យមសិក្សាធនធាននិងសាលាមណ្ឌាញនានានៅក្នុងប្រទេសកម្ពុជាយើង។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដូចខាងក្រោម៖

១. សិក្សានិងឈ្វេងយល់ពីស្ថានភាពនៃការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្ដាញលើការរៀននិងបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រនៅខេត្តតាកែវ។

២. កណាត់បញ្ហាលំបាកនិងបញ្ហាប្រឈមក្នុងការគ្រប់គ្រងសាសាធនធាន និងសាលាបណ្ដាញ

នៅខេត្តតាកែវ។

## ១.៤- សំណួរស្រាវជ្រាវ

សំណួរស្រាវជ្រាវនៃការសិក្សានេះមានដូចខាងក្រោម៖

១-តើស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញផ្នែការរៀន និងបង្រៀនមុខវិជ្ជាថ្នាក់វិទ្យាសាស្ត្រនៅខេត្តតាកែវយ៉ាងដូចម្ដេច?

២-តើការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញនៅខេត្តតាកែវជួបប្រទះនូវបញ្ហាលំបាកនិងបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីប្រធានបទ ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រ គឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍសាលារៀន ស្តង់ដាសាលារៀន សមត្ថភាពរបស់អ្នកគ្រប់គ្រង ដំណើរការនៃការគ្រប់គ្រង សមត្ថភាពរបស់អ្នកសិក្សា និងពង្រឹងវិស័យអប់រំនៅកម្ពុជាតាមរយៈការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញនៅទូទាំងប្រទេសកម្ពុជាប្រកបដោយ គុណភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់ ដើម្បីឲ្យការការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញ និងដើម្បីធ្វើឲ្យការអប់រំមានគុណភាព មានការប្រកួតប្រជែងគ្នានៅទូទាំងប្រទេសកម្ពុជា។

ម្យ៉ាងទៀតការលើកយកលើកយកប្រធានបទខាងលើមកសិក្សាស្រាវជ្រាវ មានគោលបំណងក្នុងការកំណត់នូវរាល់បញ្ហាប្រឈមចំពោះស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញ និងចំណុចវិជ្ជមាន និងអវិជ្ជមានដែលកើតមានចំពោះការគ្រប់គ្រងធនធានអប់រំ និងចំណុចខ្វះខាតក្នុងវិស័យអប់រំដើម្បីជាការផ្តល់នូវព័ត៌មានដល់ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ និងការិយាល័យអប់រំស្រុក ដើម្បីធ្វើឲ្យមានភាពងាយស្រួលក្នុងកំណត់គោលនយោបាយអប់រំ។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវនេះជាជំនួយសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយៗ ក្នុងការបន្តសិក្សាស្រាវជ្រាវលើបញ្ហាប្រឈម និងរាល់ដំណោះស្រាយនានាក្នុងការគ្រប់គ្រងសាធនធាន និងសាលាបណ្តាញនៅក្នុងវិស័យអប់រំនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ ប្រធានបទនេះនៅមានសារៈសំខាន់មួយទៀត គឺលទ្ធផលនៃការស្រាវជ្រាវនេះនឹងជួយតម្រង់ទិស ក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានអប់នៅសាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញ។ មួយចំណែកទៀត លទ្ធផលនៃការស្រាវជ្រាវនេះ នឹងជួយជម្រុញនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានអប់រំ ជាពិសេសការប្រើប្រាស់បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ ដែលមាននៅក្នុងអគារធនធាន នៃសាលាមធ្យមសិក្សាធនធានឲ្យអស់លទ្ធភាព និងជាចុងក្រោយ គឺជាចុងក្រោយ គឺជាឯកសារសម្រាប់ជំនួយស្មារតីដល់អ្នកសិក្សាក្នុងការសិក្សារៀនសូត្រ និងការសិក្សាស្រាវជ្រាវផ្សេងៗផងដែរ។

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

ខ្លឹសារក្នុងការសិក្សាស្រាវជ្រាវនៃប្រធានបទ"ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញផ្តោតលើផ្នែកការអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ" អ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាមធ្យមសិក្សាធនធានទាំងពីរ និងសាលាមធ្យមសិក្សាបណ្តាញចំនួន៦ក្នុងចំណោមសាលាណ្តាញទាំ១១ទូទាំងខេត្ត។ក្នុងនោះជាតុសំណាកគឺអ្នកស្រាវជ្រាវរើសយកតែ លោកនាយក/លោកស្រីនាយិកា លោកនាយក/លោកស្រីនាយិការងទទួលបន្ទុកផ្នែកបច្ចេកទេស បរិច្ចការីបន្ទប់ពិសោធន៍ និងលោកគ្រូ-អ្នកគ្រូដែលបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ហើយជាតុសំណាកទាំងអស់សរុបចំនួន៨៤ នាក់ ។

ការសិក្សាស្រាវជ្រាវមួយដែលទទួលបានជោគជ័យ និងលទ្ធផលល្អ គឺត្រូវមានកត្តារួមផ្សំជាច្រើននៅក្នុននោះផងដែរ ការកំណត់ពីដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវជាចំណុចដ៏សំខាន់ដើម្បីជៀសវាងការសិក្សាស្រាវជ្រាវប្រាសចាកពីប្រធានបទ ឬមិនចំគោលដៅ ហើយវិសាលភាពនៃការសិក្សាស្រាវជ្រាវគឺផ្តោតលើតែស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រ។ ខ្លឹមសារសិក្សាស្រាវជ្រាវនៃប្រធានបទ ការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញ អ្នកសិក្សាស្រាវជ្រាវកំណត់យកដែនកំណត់ ត្រឹមតែដំណើរការស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញផ្តោតលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវរួមមាន៖ (១).ការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍ (២).ការគ្រប់គ្រងនិងការប្រើប្រាស់បណ្ណាល័យសិក្សា (៣).ការគ្រប់គ្រប់ និងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា(ICT) (4).ការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល(៥). ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស (៦). ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា(៧). ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សា។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូកដូចខាងក្រោម៖

**ជំពូកទី១៖** សេចក្តីផ្តើមមានលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោតបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណាតនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។

**ជំពូកទី២៖** រំឭកទ្រឹស្តី ពិនិត្យមើលឯកសារ និងការសិក្សាស្រាវជ្រាវពីមុនៗ ដើម្បីជាពុទ្ធិក្នុងការស្វែងយល់ពីភាពខុសគ្នារវាងការសិក្សាដែលកំពុងធ្វើការសិក្សាស្រាវជ្រាវនិងការសិក្សាពីមុន។

**ជំពូកទី៣៖** រៀបរាប់អំពីវិធីសាស្ត្រស្រាវជ្រាវ ដែលអ្នកសិក្សាស្រាវជ្រាវបានយកមកប្រើប្រាស់ក្នុងសិក្សាស្រាវជ្រាវនេះ។ នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវបង្ហាញពីរបៀបនៃការសិក្សា ការប្រមូលសំណាក ការប្រមូលព័ត៌មាន ការវិភាគទិន្នន័យ ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើប្រាស់រូបមន្តក្នុងការគណនា និងការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ។

**ជំពូកទី៤៖** លទ្ធផលនិងការបកស្រាយក្នុងផ្នែកនេះ អ្នកស្រាវជ្រាវលើកឡើងពីលក្ខណៈជាក់ស្តែងដែលសខ្លួនបានធ្វើការសិក្សាស្រាវជ្រាវរួចហើយគឺត្រូវឆ្លើយតបទៅនឹងចំណុចដែលបានចោទសួរនៅក្នុងចំណោតបញ្ហា។ ការបកស្រាយយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវ និងអ្នកសិក្សាស្រាវជ្រាវនឹងយកទិន្នន័យដែលប្រមូលបានមកវិភាគ និងបកស្រាយយ៉ាងក្បោះក្បាយ ដើម្បីរកឲ្យឃើញនូវបញ្ហាប្រឈម និងដំណោះស្រាយផ្សេងៗដែលតែងតែកើតឡើងជំពោះការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញ។

**ជំពូកទី៥៖** សេចក្តីសន្និដ្ឋាន ការពិភាក្សា និងសំណូមពរ ជំពូកនេះអ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសង្ខេបការសិក្សាស្រាវជ្រាវរួចទាញជាសេចក្តីសន្និដ្ឋានទៅលើចំណុចទាំងអស់ដែលបានយកមកវិភាគ ព្រមទាំងផ្តល់ជាសំណូមពរមួយចំនួនក្នុងបំណងចូលរួមចំណែកទៅលើចំណុចដែលត្រូវធ្វើការកែលម្អ ដើម្បីធ្វើឲ្យស្ថានភាពនៃការគ្រប់គ្រងសាលាធនធាននិសាលាបណ្តាញលើផ្នែកមុខវិជ្ជាវិទ្យាសាស្ត្រមានភាពល្អប្រសើរឡើងថែមទៀត។

# ជំពូកទី២

# រំឭកទ្រឹស្តី

នៅក្នុងជំពូកនេះអ្នកសិក្សាផ្តោតខ្លាំងទៅលើនិយមន័យពាក្យគន្លឹះដែលទាក់ទងទៅនឹងការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញនៅខេត្តតាកែវ។ពាក្យគន្លឹះសំខាន់ៗដែលអ្នកសិក្សានឹងយកមកពន្យល់បកស្រាយនោះរួមមានៈការគ្រប់គ្រង និងសាលាមធ្យមសិក្សាធនធាន។

## ២.១- និយមន័យ

ការគ្រប់គ្រង គឺដំណើរការផែនការ ចាត់តាំង ដឹងនាំនិងត្រួតពិនិត្យ ទៅលើការប្រើប្រាស់ធនធានមនុស្ស និងធនធានដ៏ទៃទៀតដើម្បីសម្រេចគោលដៅអង្គភាពមួយ។ ការគ្រប់គ្រង សំដៅដល់ការធ្វើផែនការ ការរៀបចំចាត់ចែង ការដឹកនាំ ការត្រួតពិនិត្យ ធនធានមនុស្ស និងធនធានដ៏ទៃទៀត ដើម្បីសម្រេចគោលដៅរបស់អង្គភាព ឬស្ថាប័ន ប្រកបដោយប្រសិទ្ធភាព (ក្រសួងអប់រំ យុវជន និងកីឡា ២០១៦។

សាលាមធ្យមសិក្សាធនធាន គឺជាសាលាមធ្យមសិក្សាមួយនៅស្រុក/ខណ្ឌ ឬខេត្ត/ក្រុងដែលត្រូវបានជ្រើសរើសឡើង ដើម្បីនាំមុខក្នុងការធ្វើឲ្យសាលារៀនមានការរីកចម្រើនគ្រប់ផ្នែក ដូចជាការអនុវត្តកម្មវិធីសិក្សា និងលទ្ធផលសិក្សា ចែករំលែកបទពិសោធន៍(ការបង្រៀន ការរៀន ការគ្រប់គ្រង) ការអភិវឌ្ឍផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការអភិវឌ្ឍសាលារៀន និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ សាលាមធ្យមសិក្សាធនធាននឹងក្លាយជាសាលាមធ្យមសិក្សានាំមុខក្នុងចំណោមសាលាមធ្យមសិក្សាបណ្តាញ ដែលមានក្នុងមូលដ្ឋាន។

## ២.២. ការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍

សាលាមធ្យមសិក្សាធនធាន ត្រូវរៀបចំកាលវិភាគដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ កុំព្យូទ័រ និងបណ្ណាល័យសម្រាប់សិស្ស សម្រាប់គ្រប់កម្រិតថ្នាក់ទាំងសាលាបធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញបានច្បាស់លាស់ និងអនុវត្តន៍ឲ្យបានជាប្រចាំតាមកាលវិភាគក្នុងបន្ទប់នោះ៖

- កត់ត្រាបញ្ចូលក្នុងរបាយការណ៍អំពីការប្រជុំ ការបណ្តុះបណ្តាល និងការណែនាំផ្សេងៗដែលបានរៀបចំធ្វើនៅក្នុងបន្ទប់ប្រជុំ បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រនៃអគាធនធាន

- រៀបចំប្រជុំពិភាក្សាជាមួយនាយកសាលាបធ្យមសិក្សបណ្តាញរៀងរាល់ឆ្នាំ មុនបើកបវេសនកាលដើម្បីរៀបចំកាលវិភាគដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ កុំព្យូទ័រ បណ្ណាល័យ និងបន្ទប់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សនៃសាលាមធ្យមសិក្សាបណ្តាញក្នុងតំបន់របស់ខ្លួន

- ផ្សព្វផ្សាយឯកសារមូលដ្ឋានគ្រឹះនៃព័ត៌មាវិទ្យាដល់លោកគ្រូ អ្នកគ្រូវិជ្ជាផ្សេងៗ ឲ្យចេះប្រើប្រាស់កុំព្យូទ័រដើម្បីអភិវឌ្ឍន៍មេរៀនជំនាញរបស់ខ្លួន

- ផ្សព្វផ្សាយឯកសារការគ្រប់គ្រង និងដឹកនាំក្រុមបច្ចេកទេសដល់ប្រធានក្រុមបច្ចេកទេសនៃសាលាមធ្យមសិក្សាបណ្តាញ

- រៀបចំថ្នាក់និទស្សន៍មុខវិជ្ជាផ្សេងៗ ដោយអញ្ជើញប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូសាលាមធ្យមសិក្សាបណ្តាញឲ្យចូលរួមចែករំលែកបទពិសោធន៍

- ត្រូវមានសន្តិសុខយាមប្រចាំការទាំងពេលថ្ងៃ និងពេលយប់

- ធ្វើអនាម័យជាប្រចាំ ដូចជា បោសសម្អាតបន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រជាប្រចាំ លាងទុកដាក់សម្ភារៈពិសោធន៍ដែលបានប្រើរួច ព្រមទាំទុកដាក់ឲ្យមានរបៀប និងតាមទីកន្លែង

- បិទស្លាកឈ្មោះលើឧបករណ៍ សម្ភារៈដែលត្រូវប្រើ និងសម្ភារៈផ្សេងៗទៀតដែលមាន

- ថែទាំ និងជួលជុលឧបករណ៍សម្ភារៈតូចតាចជាប្រចាំ។

- ការគ្រប់គ្រងឧបករណ៍ពិសោធន៍ សម្ភារៈបរិក្ខារ និងសារធាតុគីមី ដែលមាននៅក្នុងបន្ទប់ពិសោធន៍

- សហការណ៍ជាមួយគ្រូមុខវិជ្ជាឯកទេស ដើម្បីរៀបចំកម្មវិធីធ្វើសកម្មភាពប្រតិបត្តិ និងលើកគម្រោងតម្រូវការសម្ភារៈក្នុងបន្ទប់ពិសោធន៍

- ធ្វើជាជំនួយការគ្រូមុខវិជ្ជាឯកទេស ក្នុងដំណើរការធ្វើសកម្មភាពពិសោធន៍

- ស្រាវជ្រាវ និងផ្សព្វផ្សាយរបកគំហើញថ្មីៗ

**២.៣. ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារបច្ចេកវិទ្យា** (ICT)

ចំពោះការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់កុំព្យូទ័រចាំបាច់ត្រូវមានបុគ្គលិកដែលទទួលបន្ទុកគ្រប់គ្រងកុំព្យូទ័រ និងមានតួនាទីដូចខាងក្រោម៖

- គ្រប់គ្រងសម្ភារៈបរិក្ខារ និងឧបករណ៍អេឡិចត្រូនិចនៅក្នុងបន្ទប់កុំព្យូទ័រ

- សហការណ៍ជាប្រចាំជាមួយមុខវិជ្ជាឯកទេស ពេលដំណើរការបង្រៀន និងរៀន

- ដំណើរការបន្ទប់កុំព្យូទ័រ សម្រាប់ការបង្រៀនព័ត៌មានវិទ្យា និងស្រាវជ្រាវ

- លើកគម្រោងតម្រូវការសម្ភារៈចាំបាច់ដូចជា ទឹកខ្មៅ ម៉ាស៊ីនបោះពុម្ព ទឹកខ្មៅម៉ាស៊ីនថតចម្លង និងគ្រឿងបន្លាស់តូចតាច....

- ជួសជុសឬស្វែងរកសេវាជួសជុលកុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិកតាមសមត្ថភាពដែលអាចធ្វើបាន

- ស្រាវនិងផ្សព្វផ្សាយរបកគំហើញថ្មីៗ។

- ចូលរួមប្រជុំជាមួយក្រុមបច្ចេកទេសវិទ្យាសាស្ត្រតាមឯកទេសរបស់ខ្លួន។

## ២.៤. ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យ

បណ្ណាល័យ ជាមជ្ឈមណ្ឌលសិក្សាអស់មួយជីវិត និងជាគ្រឹះស្ថានអប់រំសម្រាប់ជនគ្រប់រូបដែលធានាលើការការពារសិទ្ធិនៃការអប់រំ (ទួត វាសនា ២០១៦)។ បណ្ណាល័យ ជាកន្លែងសម្រាប់ផ្ទុកសៀវភៅសិក្សាគោលដ៏មានសុវត្ថិភាពបំផុត ដែលធានាឲ្យជៀសផុតពីភាពអន្តរាយនានា ដូចជាពន្លឺ ភ្លៀង ធូលី... ដែលនាំឲ្យខូចខាត ឬបាត់បង់។(ក្រសួងអប់រំ យុវជន និងកីឡា ២០១៥)។បណ្ណាល័យ ជាកន្លែងអភិវឌ្ឍវិស័យអំណាន និងផ្សព្វផ្សាយការអាន គឺអភិវឌ្ឍចំណេះដឹង អាកប្បកិរិយា និងតម្លៃរបស់កុមារដោយភ្ជាប់ជាមួយសេចក្តីត្រូវការជាមុនចំពោះសិទ្ធិកុមារដើម្បីទទួលបានការអប់រំ និងវប្បធម៌របស់ពួកគេ (ក្រសួងអប់រំ យុវជន និងកីឡា ២០០៨) ។ នៅតាមសាលារៀនតាមរយៈការអានក្នុងបណ្ណាល័យ ជាកត្តាសំខាន់មួយក្នុងការជំរុញគុណភាពបង្រៀន និងរៀន។ ដើម្បីពង្រីកវិសាលភាពការងារបណ្ណាល័យនៅតាមសាលាមធ្យមសិក្សាធនធាន ឲ្យទទួលបានគុណភាពខ្ពស់ចាំបាច់ត្រូវមានស្តង់ដារបណ្ណាល័យជាក់លាក់ ដែលសំដៅចូលរួមលើកកម្ពស់ការអាន នៅប្រទេសកម្ពុជាយើងឲ្យមានការរីចម្រើនជាលំដាប់។

### ២.៤.១. សារៈសំខាន់នៃបណ្ណាល័យ

ការពង្រីកបណ្ណាល័យជាមធ្យោបាយជួយកាត់បន្ថយអត្រាអនក្ខរភាព និងរួមចំណែកកសាងធនធានមនុស្សតាមគោលដៅអប់រំជាតិ ក៏ជួយសម្រេចផែនការអប់រំជាតិទាំងអស់គ្នាផងដែរ។ ហេតុនេះភាពជាដៃគូដ៏ស្អិតល្មួតរវាងស្ថាប័នពាក់ព័ន្ធ ម្ចាស់ជំនួយ អង្គការជាតិ អន្តរជាតិ អាជ្ញាធរមូលដ្ឋាន ក្រុមប្រឹក្សាឃុំ វត្តអារាម និងប្រជាជនជាការចាំបាច់បំផុតដែលមិនអាចខ្វះបាន ក្នុងការធ្វើឲ្យបណ្ណាល័យមានស្ថេរភាព (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០០៧)។បើតាមក្រសួងអប់រំ យុវជន និងកីឡាឆ្នាំ២០១៤ បណ្ណាល័យមានសារៈសំខាន់ជាច្រើនដូចជា៖

- បណ្ណាល័យ ជាកន្លែងផ្តល់ការឯកភាពក្នុងការអភិវឌ្ឍការងារបណ្ណាល័យ

- បណ្ណាល័យ ជាកន្លែងផ្តល់ចំណេះដឹងមូលដ្ឋាន ផ្នែកបណ្ណាល័យដល់បណ្ណារក្ស

- បណ្ណាល័យ ជាកន្លែងជុំរុញ និងលើទឹកចិត្តបណ្ណារក្ស

- បណ្ណាល័យជាកន្លែងលើកកម្ពស់ក្នុងការអាន និងការស្រាវជ្រាវសម្រាប់សាធារណៈជនទូទៅ

- បណ្ណាល័យ ជាកន្លែងបណ្តុះទម្លាប់អាន និងការសិក្សាស្រាវជ្រាវដល់សិស្សានុសិស្ស

- រួមចំណែកគាំទ្រគោលនយោបាយស្តីពីសាលាកុមារមេត្រី

### ២.៤.២. ការគ្រប់គ្រងបណ្ណាល័យ

តាមឯកសារបស់លោក Michael Scott ឆ្នាំ២០១៦ បានបង្ហាញថា ដើម្បីគ្រប់គ្រងបណ្ណាល័យមួយឱ្យមានលក្ខណៈរឹងមាំត្រូវ៖

- ជួយអ្នកគ្រប់គ្រងបណ្ណាល័យ និងធ្វើការវាយតម្លៃអ្នកគ្រប់គ្រងនោះជាប្រចាំ
- កំណត់ប្រាក់ខែដល់ អ្នកគ្រប់គ្រង និងបុគ្គលិកបណ្ណាល័យ
- រៀបចំថវិកាសម្រាប់ទ្រទ្រង់បណ្ណាល័យដែលកំណត់ដោយក្រុមប្រឹក្សា
- ត្រួតពិនិត្យការចំណាយ និតអនុម័តនៃការចំណាយលើបណ្ណាល័យ
- រៀបចំនិងអនុម័តគោលនយោបាយប្រតិបត្តិការបណ្ណាល័យ
- អនុវត្តន៍ និតត្រួតពិនិត្យតាមដានលើដំណើរការបណ្ណាល័យ
- ធ្វើផែនការរយៈពេលខ្លី និងរយៈពេលវែងសម្រាប់អនាគតបណ្ណាល័យ

តាមស្តង់ដារបណ្ណាល័យមធ្យមសិក្សាក្រសួងអប់រំ យុវជន និងកីឡាចុះផ្សាយនាឆ្នាំ២០១៤ បណ្ណាល័យត្រូវមានសាមាសភាគសំខាន់ៗបីគឺ៖

ធនធានបណ្ណារក្ស ការប្រជុំ ការចុះពនិត្យតាមដាន បណ្ណារក្សត្រូវមានចំណេះដឹង ភាសាអង់គ្លេស កុំព្យូទ័រខ្លះៗ ដែលអាចជួយសម្រួលការងារ បច្ចេកទេស រដ្ឋបាល។ លើលពីនេះបណ្ណារក្សត្រូវមានសុខភាព

ល្អ និងមិនមានអាយុមិនលើលពី៥០ឆ្នាំ។ នាយកសាលាត្រូវធ្វើការប្រជុំប្រចាំខែដោយបញ្ចូលរបៀបវារបណ្ណាល័យក្នុងអង្គប្រជុំ ចំណែកថ្នាក់ក្រសួងអប់រំ មន្ទីរអប់រំ ការិយាល័យអប់រំត្រូវចុះពិនិត្យតាមដានការកំណត់។

ស្ថានភាពបណ្ណាល័យធនធានសម្ភារបរិក្ខារ ធនធានឯកសារ បន្ទប់បណ្ណាល័យត្រូវមានលក្ខណៈស្អាត និងមានផាសុកភាព បំពាក់សម្ភារបរិក្ខារ និតឯកសារអានសម្បូរបែប។

- ការងារបច្ចេកទេស រដ្ឋបាល បណ្ណារក្សត្រូវចេះការងារបច្ចេកទេស រដ្ឋបាលច្បាស់លាស់ ដូចជាការធ្វើរបាយការណ៍ ការធ្វើផែនការ ការថែទាំឯកសារ និងការផ្តល់សេវាកម្មបណ្ណាល័យបានល្អ។ តាមឯកសារក្រសួងអប់រំ យុវជន និងកីឡា ស្តីពិបណ្ណាល័យមធ្យមសិក្សា ឆ្នាំ២០១០ ដើម្បីបានបណ្ណាល័យមួយមានលក្ខណៈល្អទាក់ទងនឹងចំណុចជាច្រើនដូចជា៖

* ការបង្កើតបណ្ណាល័យ ត្រូវពិនិត្យមើលលើស្ថានភាពទីតាំងការគាំទ្រពីសាលា និងស្ថាប័នពាក់ព័ន្ធការស្វែងរកឯកសារសម្រាប់បណ្ណាល័យ និងការជ្រើសរើសបណ្ណារក្ស។

* សេវាកម្មបណ្ណាល័យ ដើម្បីធានាបានការអានមានប្រសិទ្ធភាពទាមទារសេវាកម្មបណ្ណាល័យល្អ គឺបណ្ណាល័យបើកទ្វាគ្រប់ពេល និងមានបណ្ណារក្សនៅរងចាំផ្តល់ប្រឹក្សាដល់ អ្នកអានគ្រប់ពេល។

* ការងាររដ្ឋបាលបណ្ណល័យរួមមានការចាត់ចែងបុគ្គលិក ការពិនិត្យតាមដាននិងការវាយតម្លៃបុគ្គលិក ការទិញការធ្វើអំណោយដោះដូរ។

ការងារទំនាក់ទំនងក្នុងសាលារៀន និងការទំនាក់ទំនងក្រៅសាលារៀន

តាមឯកសារក្រសួងអប់រំ យុវជន និងកីឡា ស្តីពីបណ្ណាល័យ និងសៀវភៅសម្រាប់កុមារចេញផ្សាយនាឆ្នាំ២០០៧ បណ្ណាល័យជាកន្លែងសម្រាប់អ្នកទូទៅប្រើប្រាស់ ដែលមានបណ្ណារក្សជាអ្នកទទួលខុលត្រូវក្នុងការធ្វើឲ្យបណ្ណាល័យមានគុណភាព និរន្តរភាពតាមរយៈការគ្រប់គ្រងល្អ អំពីទីកន្លែង សង្ហារឹម សម្ភារៈសៀវភៅ និងអ្នកអាន។ បណ្ណារក្សត្រូវមានជំនាញក្នុងការរៀបចំសម្ភារបរិក្ខារក្នុងបណ្ណាល័យឲ្យមានរបៀប

រៀបរយ ការធ្វើសម្អាតក្នុងបន្ទប់ និងក្រៅបន្ទប់បណ្ណាល័យឲ្យបានស្អាត ការជួសជុលថែទាំសៀវភៅ ការរៀបចំបញ្ជីសារពើភ័ណ្ឌ ការចុះលេខកូដសៀវភៅ ការរៀបចំសៀវភៅចូលធ្នើ ការធ្វើបញ្ជីខ្ចី សង ការប្រមូលសៀវភៅ ការរៀបចុះឧបករណ៍សម្រង់ស្ថិតិសិស្សចូលអាន ការធ្វើកាលវិភាគប្រចាំសប្តាហ៍ ការលើកទឹកចិត្តសិស្សដែលស្ម័គ្រចិត្តជួយធ្វើការងារបណ្ណាល័យ ការធ្វើផែនការប្រចាំខែ ការធ្វើរបាយការណ៍ ការធ្វើសំណើរសុំសម្ភារៈការធ្វើទំនាក់ទនងល្អ។

## ២.៥. ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោល

ការអប់រំនៅកម្ពុជាមានភាពខ្វះខាតគ្រូបង្រៀន ដែលទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់លើវិធីសាស្ត្របង្រៀនថ្មីដែលសង្កត់ធ្ងន់លើការបង្រៀនបែបសកម្ម។ គ្រូបង្រៀនច្រើនតែមានទំនោរផ្តោតការសង្កត់ធ្ងន់លើការទន្ទេញចាំមាត់ ហើយជាលទ្ធផលសិក្សារបស់សិស្សានុសិស្សច្រើនតែគ្មានសមត្ថភាពអាចផ្សារភ្ជាប់អ្វីដែលខ្លួនបានសិក្សាទៅនឹងការដោះស្រាយបញ្ហាប្រចាំថ្ងៃរបស់ខ្លួនបានឡើយ។ កុមារប្រហែលជាដឹងអពីព័ត៌មានផ្សេងៗ ប៉ុន្តែពួកគេមិនយល់អំពីព័ត៌មានទាំងអស់នោះ ឬមិនដឹងពីរបៀបប្រើប្រាស់ព័ត៌ទាំងអស់នោះយ៉ាងដូចម្តេចនោះទេ។ ការផ្លាស់ប្តូរស្ថានភាពនេះគឺជាបញ្ហាប្រឈមរយៈពេលវែងដែលទាមទារការកែលម្អឡើងវិញនូវកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្រៀន និងបុគ្គលិកនៅក្នុងស្ថាប័នបណ្តុះបណ្តាលនិងវិក្រិតការនាពេលបច្ចុប្បន្ន។ អន្តរាគមន៍ដែលអាចនាំមកនូវការផ្លាស់ប្តូរដ៏ធំធេងគួរឲ្យកត់សម្គាល់ដោយប្រើប្រាស់ពេលវេលាខ្លីសមគួរនោះគឺសាលារៀនត្រូវមានសៀវភៅសិក្សាគោលដែលលើកកម្ពស់វិធីសាស្ត្របង្រៀន និងវិធីរៀនថ្មី។ ប្រសិនបើអាចមានសៀវភៅសិក្សាបែបនេះយ៉ាងទូលំទូលាយនោះសៀវភៅទាំងនេះនឹងអាចជួយសម្រួលគ្រូបង្រៀនតាមរយៈការផ្តល់ឧទាហរណ៍ស្តីពីវិធីសាស្ត្របង្រៀនថ្មី ព្រមទាំអនុញ្ញាតឲ្យសិស្សានុសិស្សធ្វើអន្តរកម្មជាមួយព័ត៌មានបាន បើទោះជាគុណភាពនៃការបង្រៀននៅមានកម្រិតក៏ដោយ។ បញ្ហាប្រឈមសម្រាប់ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាគឺការធ្វើយ៉ាងណាដើម្បីផលិត និងចែកចាយសៀវភៅសិក្សាគោលដែលមានគុណភាពខ្ពស់ក្នុងចំនួនគ្រប់គ្រាន់ដែលឆ្លុះបញ្ចាំងនូវវិធីសាស្ត្របង្រៀន និងវីធីសាស្ត្ររៀនបែបថ្មីៗ បញ្ហាប្រឈមនេះត្រូវបានគ្រប់គ្រងយ៉ាងល្អបំផុតនៅក្នុងនាយកដ្ឋាន

អភិវឌ្ឍកម្មវិធីសិក្សា ដែលធ្វើការក្នុងកិច្ចសហការជាមួយផ្នែកស្តង់ដារនិងការប្រឡង( Standard Examination Division)។ ការគាំទ្រផ្នែកថវិកាសម្រាប់កណើនចំនួនសៀវភៅសិក្សាពិតជាត្រូវការចាំបាច់។

បច្ចុប្បន្នសៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូគឺជាមធ្យោបាយដ៏ចម្បងសម្រាប់គាំទ្រដល់ការបង្រៀន និងរៀននៅតាមសាលារៀនក្នុងប្រទេសកម្ពុជា។ នៅពេលអនាគតអាចនឹងមានមធ្យោបាយផ្តល់ការគាំទ្រផ្សេងទៀត ដូចជាការបញ្ចូលព័ត៌មានតាមរយៈប្រព័ន្ធអ៊ីនធើណិតជាដើម។ ប៉ុន្តែសម្រាប់រយៈពេលមធ្យមយើងគួរតែផ្តោតលើការយកចិត្តទុកដាក់ជាសំខាន់ក្នុងការធ្វើយ៉ាងណាអាចសម្រេចឲ្យបាននូវអត្រា១.១គឺសៀវភៅសិក្សាគោលមួយក្បាលគ្រប់មុខវិជ្ជាសម្រាប់សិស្សម្នាក់ ចាប់ពីថ្នាក់ទីដល់ថ្នាក់ទី១២។ ជាជំហានដំបូងគួរផោតការយកចិត្តទុកដាក់លើការធ្វើយ៉ាងណាដើម្បីសម្រេចឲ្យបាននូវអត្រា១.១នៅថ្នាក់ទី១ ដល់ថ្នាក់ទី៩ និងក្រោយមកនៅពេលដែលមានមូលនិធិយើងនឹងធ្វើសម្រាប់ថ្នាក់ទី១០ ដល់ថ្នាក់ទី១២ទៀត។ សម្រាប់រយៈពេលវែង និងនៅពេលដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងមានថវិកាគ្រប់គ្រាន់ក្រសួងអប់រំ យុវជន និងកីឡាគួរតែធ្វើឲ្យមានសម្ភារឧបទេសផ្សេងៗទៀត។

បច្ចុប្បន្ននេះសៀវភៅសិក្សាគោលទាំងអស់ត្រូវបានអភិវឌ្ឍ ដោយគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយដែលជាសហគ្រាសស្វយ័តរបស់រដ្ឋនៅឡើយ។ នៅពេលអនាគតយើងរំពឹងថា និងមានការប្រកួតប្រជែងសៀវភៅសិក្សាគោលដោយសហគ្រាសបោះពុម្ព និងចែកផ្សាយផ្សេងៗទៀតនឹងធ្វើឲ្យមានសៀវភៅសិក្សាគោលកាន់តែច្រើន និងសម្បូរបែបសម្រាប់ការជ្រើសរើសរបស់សាលារៀន គ្រូបង្រៀន និងមាតាបិតាសិស្ស។

សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសៀវសិក្សាគោលសម្រាប់គ្រូ ព្រមទាំងប្រព័ន្ធប្រឡងគួរតែឆ្លុះបញ្ចាំង និងគាំទ្រចំពោះរបស់វត្ថុបំណងរបស់កម្មវិធីសិក្សានាពេលបច្ចុប្បន្ន។ ហេតុនេះការសំខាន់អ្នកអភិវឌ្ឍសៀវភៅសិក្សាគោល អ្នកអភិវឌ្ឍកម្មវិធីសិក្សា និងមន្ត្រីទទួលបន្ទុកការប្រឡងត្រូវមានទំនាក់ទំនង

យ៉ាងជិតស្និតជាមួយគ្នាក្រោមរចនាសម្ព័ន្ធគ្រប់គ្រងដែលស៊ីសង្វាក់និងប្រាកដនិយមនៅក្រោមនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ ដើម្បីសម្រេចនូវភាពស៊ីសង្វាក់គ្នារវាងកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការប្រឡងដំណើរការនៃការអភិវឌ្ឍទាំងមូល រួមទាំងការអនុម័តឲ្យប្រើប្រាស់នៅក្នុងសាលារៀនផងដែរចាំបាច់នត្រូវតែស្ថិតក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមួយ។ សៀវភៅសិក្សា ឯកសារសិក្សាស្ថិតនៅក្នុងគណៈកម្មាធិការដែលនៅខាងក្រៅ ដូចអ្វីដែលកំពុងធ្វើបច្ចុប្បន្ននេះ មានតម្លៃតិចតួចណាស់។ ការតម្រូវឲ្យអ្នកខាងក្រៅជាអ្នកអនុវត្តនាំឲ្យមានការពន្យាពេលដែលមិនសមស្រប ក្នុងដំណើរការនាំយកសៀវភៅទៅកាន់សាលារៀន។

សៀវភៅសិក្សាគោលសម្រាប់គ្រូ និងសៀវភៅសិក្សាគោលសម្រាប់សិស្ស គប្បីឆ្លុះបញ្ចាំងនូវគោលបំណងរបស់កម្មវិធីសិក្សាក្នុងការលើកទឹកចិត្តការរៀនបែបសកម្ម ដើម្បីគាំទ្រដល់សលទ្ធផលការសិក្សាឲ្យកាន់តែប្រសើរឡើង។ ស្ថាប័នអភិវឌ្ឍកម្មវិធីសិក្សា ស្ថាប័នអភិវឌ្ឍសៀវភៅសិក្សា និងស្ថាប័នបណ្ដុះបណ្ដាលគ្រូគួរតែផ្ដល់ការជ្រោមជ្រែងដល់គ្រូបង្រៀន ដើម្បីឲ្យពួកគាត់អាចកែប្រែការអនុវត្តនៅក្នុងថ្នាក់រៀនរបស់ពួកគាត់ឆ្ពោះទៅធ្វើឲ្យសិស្សានុសិស្សរៀនសូត្រដោយសកម្ម។ ស្ដង់ការការបង្រៀន និងការវាយតម្លៃត្រូវបានបង្កើតឡើងរួចហើយ ហើយត្រូវបានយកមកអនុវត្តជាបណ្ដើរៗនៅក្នុងវិស័យទាំងមូល។ សៀវភៅសិក្សាគោល និងសម្ភារឧបទេសសម្រាប់ការបង្រៀន ការរៀន ក៏ត្រូវតែគោរពយ៉ាងខ្ជាប់ខ្ជួនតាមស្ដង់ដារថ្មីនេះដែរ។

### ២.៥.១. គោលបំណង និងវត្ថុបំណងនៃការផ្ដល់សៀវភៅសិក្សាគោល

ការផ្ដល់សៀវភៅសិក្សាគោលជាការគាំទ្រចំពោះគោលដៅទូទៅរបស់ការអប់រំ ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំកម្រិតមូលដ្ឋាននិងមធ្យមសិក្សាតាមរយៈការផ្ដល់សៀវភៅសិក្សាគោលសម្រាប់សិស្ស និងសម្រាប់គ្រូ សៀវភៅអំណានបន្ថែម និងសម្ភារឧបទេស ដែលគាំទ្រដល់កម្មវិធីសិក្សា។

**១. លទ្ធភាពទទួលបាន៖** សិស្សានុសិស្សទាំងអស់នៅកម្រិតសិក្សា ទាំងកម្រិតមូលដ្ឋាន និងកម្រិតមធ្យមសិក្សាមានលទ្ធភាពទទួលបានសៀវភៅសិក្សាគោលគ្រប់គ្រាន់ ឬមានលទ្ធភាពទិញសៀវភៅសិក្សាផ្សេងៗទៀតដែលបានអនុម័តឲ្យប្រើដោយក្រសួងអប់រំ។

**២. គុណភាព៖** សៀវភៅសិក្សាគោលដែលអនុម័តឲ្យប្រើត្រូវមានគុណភាពខ្ពស់ និងគាំទ្រដល់កម្មវិធីសិក្សាសម្រាប់មុខវិជ្ជានីមួយៗ និងគ្រប់កម្រិតថ្នាក់។

**៣. ការគាំទ្រ៖** រាល់សៀវភៅសិក្សាគោលទាំងអស់ត្រូវមានការគាំទ្រពីសៀវភៅសិក្សាគោលសម្រាប់គ្រូ និងសម្ភារឧបទេសបន្ថែមសម្រាប់ការរៀន និងការបង្រៀនឲ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបានតាមលទ្ធភាពហិរញ្ញវត្ថុដែលមាន។

## ២.៥.២. លទ្ធភាពដើម្បីទទួលបានសៀវភៅអប់រំ

ការផ្តល់មូលនិធិ គឺបានតាមរយៈកញ្ចប់ថវិកាពីក្រសួងអប់រំ ដែលអនុម័តដោយក្រសួងអប់រំ ដែលអនុម័តដោយក្រសួងហិរញ្ញវត្ថុ ហេតុនេះ ការស្នើសុំថវិកាសម្រាប់សៀវភៅសិក្សាគោលទៅស្ថាប័នទាំងពីរនេះត្រូវមានអំណះអំណាងទិន្នន័យ ច្បាស់លាស់ដើម្បីឲ្យមានការផ្តល់មូលនិធិគ្រប់គ្រាន់សម្រាប់គាំទ្រចំពោះអទិភាពនេះ។ ការផ្តល់សៀវភៅសិក្សាគោលគ្រប់មុខវិជ្ជាទាំងអស់នៅគ្រប់កម្រិតថ្នាក់ជាអាទិភាពមួយដ៏ខ្ពង់ខ្ពស់បំផុត។ ចាំបាច់ត្រូវផ្តល់មូលនិធិគ្រាប់គ្រាន់ដើម្បីអភិវឌ្ឍបោះពុម្ព និងចែកផ្សាយសៀវភៅសិក្សាគោលទាំងនេះដែលជាកត្តាគាំទ្រដល់អាទិភាពនេះ។ បច្ចុប្បន្នសៀវភៅសិក្សាគោលត្រូវបានអភិវឌ្ឍឡើងដោយផ្អែកលើមូលដ្ឋានមូលនិធិដែលមាន ដែលបានបង្កឲ្យមានការខ្វះខាតសៀវភៅទាំងនេះ។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមានតួនាទីពិនិត្យតាមដានជាការអនុវត្តកម្មវិធីសិក្សាថ្មី និងប្រព័ន្ធនៃការប្រឡងផងដែរ។ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមានភារកិច្ចទទួលខុសត្រូវលើដំណើរការនៃការអភិវឌ្ឍសៀវភៅសិក្សាគោល។ ដោយហេតុថាសៀវភៅសិក្សាគោលមានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងកម្មវិធីសិក្សា ហេតុនេះការផ្គត់ផ្គង់សៀវភៅសិក្សាគោលត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋាន

អភិវឌ្ឍកម្មវិធីសិក្សា។ បច្ចុប្បន្ននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមិនមែនជាអ្នកអនុម័តលើការដាក់ឲ្យប្រាស់សៀវភៅសិក្សាគោលទេ។ ការអនុម័តនេះជាការងាររបស់ក្រុមប្រឹក្សាអនុម័តសម្ភារសិក្សាដែលនៅដាច់ពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ ការដកភារកិច្ចពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាដែលមានបេសកកម្មអនុម័តសម្ភារសិក្សាប្រគល់ឲ្យស្ថាប័នខាងក្រៅដូចជាក្រុមប្រឹក្សាអនុម័តសម្ភារសិក្សានាំឲ្យមានការពន្យាពេលដែលមិនចាំបាច់ និងមិនមានមូលហេតុសមស្របបើគិតទៅលើប្រសិទ្ធភាព។

បច្ចុប្បន្នទោះបីមានផ្សព្វផ្សាយដើម្បីដាក់ឲ្យមានការដេញថ្លៃ អភិវឌ្ឍន៍ និងបោះពុម្ពសៀវភៅសិក្សាគោលក្តី ប៉ុន្តែលទ្ធផលមានអ្នកដេញថ្លៃតែមួយគត់ ដែលមានសមត្ថភាពគឺគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ។ បន្ទាប់មកគ្រឹះស្ថានបោះពុម្ព និងចែកផ្សាយរកអ្នកនិពន្ធក្នុងចំណោមមន្ត្រីនៃនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ ការបំប៉នសមត្ថភាពជំនាញដល់មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាក្នុងការរៀបចំសៀវភៅបន្ទុកដែលសមស្របសម្រាប់ដាក់បញ្ចូលនៅក្នុងឯកសារដេញថ្លៃ គឺជាចំណុចអាទិភាព។ តួនាទីរបស់មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានៅក្នុងការងារផ្គត់ផ្គង់សៀវភៅសិក្សាគោល គឺត្រូវរៀបចំយន្តការសម្រាប់ក្រុមអ្នករៀបរៀង។ អ្នករៀបរៀង និងទទួលខុសត្រូវក្នុងការសរសេរណែនាំពីតម្រូវការដែលទាមទារនៅក្នុងការអភិវឌ្ឍសៀវភៅសិក្សាដើម្បីបង្កើតជាលក្ខណៈវិនិច្ឆ័យដែលនឹងយកទៅវាយតម្លៃសមត្ថភាពរបស់គូរប្រជែងដែលជាអ្នកបោះពុម្ពផ្សាយក្នុងគោលដៅដើម្បីទទួលយក ឬបដិសេធស្នាដៃដែលពួកគេបានអភិវឌ្ឍថាតើសៀវភៅទាំងនេះឆ្លើយតបនឹងតម្រូវការឬអត់ និងអាចអនុម័តឲ្យប្រើប្រាស់នៅតាមសាលារៀនបានឬទេ។

ដើម្បីលើកកម្ពស់វិស័យបោះពុម្ពផ្សាយឯកជន ដំណើរការដែលបានរៀបរាប់ខាងលើនឹងចាំបាច់ត្រូវតែមានតម្លាភាព នឹងផ្សព្វផ្សាយជាសាធារណៈឲ្យបានទូលំទូលាយសហគ្រាសបោះពុម្ពផ្សាយដែលមានសក្តានុពលនឹងទទួលបានការណែនាំយ៉ាងច្បាស់លាស់អំពីអ្វីដែលត្រូវធ្វើ ព្រមទាំងលក្ខណៈវិនិច្ឆ័យប្រកបដោយតម្លាភាពសម្រាប់វិនិច្ឆ័យលើស្នាដៃ។ វត្ថុបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា គឺធ្វើយ៉ាងណាបង្កើតឲ្យមានសហគ្រាសបោះពុម្ពផ្សាយឯកជនច្រើននៅក្នុងប្រទេស។ ឆ្លើយតបវត្ថុបំណងនេះគ្រឹះស្ថាន

បោះពុម្ព និងចែកផ្សាយដែលកាលពីមុនគឺជាផ្នែកមួយរបស់ក្រសួងអប់រំយុវជន និងកីឡា ត្រូវបានប្រែក្លាយទៅជាគ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ប៉ុន្តែនៅតែជាកម្មសិទ្ធរបស់រដ្ឋនិងស្ថិតនៅក្រោមការគ្រប់គ្រងដឹកនាំរបស់រដ្ឋនៅឡើយ។ដំណើរការអភិវឌ្ឍសៀវភៅសិក្សាគោលដែលរៀបចំយ៉ាងច្បាស់លាស់តាមរយៈនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបូករួមជាមួយការដេញថ្លៃ ដែលមានតម្លាភាពនឹងជួយពន្លឿនការចូលរួមអភិវឌ្ឍសៀវភៅសិក្សាពីវិស័យបោះពុម្ពផ្សាយឯកជននានាជាក់ជាមិនខាន។

គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ ឬសហគ្រាសឯកជនដែលទទួលបានសេវាក្នុងការផ្គត់ផ្គង់សៀវភៅសិក្សានឹងដឹកជញ្ជូនសៀវភៅសិក្សាទៅដល់សាលារៀនទូទាំងប្រទេសប្រកបដោយប្រសិទ្ធភាព។ គុណសម្បត្តិនៃការដាក់ដេញថ្លៃការផ្គត់ផ្គង់ និងបោះពុម្ពផ្សាយសៀវភៅសិក្សាគោលដល់វិស័យឯកជន គឺយើងអាចដាក់តម្រូវការក្នុងការចែកចាយសៀវភៅទៅដល់សាលារៀនបញ្ចូលទៅក្នុងដំណើរការដេញថ្លៃ ដោយការបង់ប្រាក់នឹងត្រូវធ្វើឡើងនៅពេលមានការចុះហត្ថលេខាទទួលទំនិញជោគជ័យ។

បច្ចុប្បន្នអត្រានៃការបាត់បង់សៀវភៅសិក្សាមានកម្រិតខ្ពស់ព្រោះសមត្ថភាពការគ្រប់គ្រងដែលរក្សាសៀវភៅរបស់មន្ត្រីគ្រប់គ្រងសៀវភៅសិក្សាគោលនៅមានកម្រិត រួមនិងសាលារៀនមួយចំនួនគ្មានបណ្ណាល័យ។ ដើម្បីបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសៀវភៅ សាលារៀនចាំបាច់ត្រូវមានបណ្ណាល័យប្រកបដោយស្តង់ដារ (មានបរិក្ខារក្សាទុកសៀវភៅ ទូដាក់ឯកសារ....) និងបំប៉នសមត្ថភាពមន្ត្រីគ្រប់គ្រងនិងប្រើប្រាស់សៀវភៅសិក្សាគោល។

### ២.៥.៣. គុណភាពនៃសៀវភៅអប់រំ

នាយកដ្ឋានអភវឌ្ឍកម្មវិធីសិក្សាបានធ្វើផែនការជាដំណាក់កាលៗ ដើម្បីអភិវឌ្ឍកម្មវិធីសិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ ក្នុងពេលមធ្យម។ផែនការនេះរងនូវភាពរឹតត្បិតដោយសារតែថវិការមានកម្រិតកំណត់ ជាហេតុធ្វើឲ្យការអនុវត្តមានភាពយឺតយ៉ាវជាងអ្វីដែលយើងប្រាថ្នាចង់បានជាខ្លាំង។ ផែនការរបស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានាពេលបច្ចុប្បន្ន មានវិសាលភាពយ៉ាងទូលំទូលាយ និងផ្តល់នូវមូលដ្ឋានគ្រឹះដ៏ល្អដើម្បីអាចសម្រេចបាននូវវត្ថុបំណងនៃអត្រា១.១គឺសៀវភៅមួយ

ក្បាលគ្រប់មុខវិជ្ជាសម្រាប់សិស្សម្នាក់នៅគ្រប់ថ្នាក់ទាំងអស់។ ការងារនេះក្រសួងអប់រំ យុវជន និងកីឡា ចាំបាច់ត្រូវពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធានាឲ្យបានថាមានមូលនិធិគ្រប់គ្រាប់ដើម្បីសម្រេចបាននូវផែនការអភិវឌ្ឍសៀវភៅសិក្សាគោល។

នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានចាប់ផ្តើមបណ្តុះបណ្តាលដល់មន្ត្រីរបស់ខ្លួន ដើម្បីត្រៀមខ្លួនបង្កើតសេចក្តីណែនាំនៅការបញ្ជាធ្វើសៀវភៅសិក្សាគោល ប៉ុន្តែយើងនូវតែត្រូវការការបណ្តុះបណ្តាល និងការអភិវឌ្ឍជំនាញបន្ថែមទៀតដើម្បីបង្កើនគុណភាពការអភិវឌ្ឍសៀវភៅសិក្សាគោល និងសម្ភារឧបទេសឲ្យមានគុណភាពខ្ពស់។ កម្មវិធីបណ្តុះបណ្តាលវែង និងទូលំទូលាយដែលធ្វើឡើងដោយមន្ត្រីជាន់ខ្ពស់នៅក្នុងនាយកដ្ឋាននឹងត្រូវធ្វើឡើងដើម្បីធានាឲ្យបានថា អ្នកអភិវឌ្ឍសេចក្តីណែនាំក្នុងការបញ្ជាធ្វើសៀវភៅសិក្សា និងអ្នកអភិវឌ្ឍសៀវភៅសិក្សាគោល បន្តអភិវឌ្ឍ និងផ្តល់ជូននូវសម្ភារៈដែលមានគុណភាពខ្ពស់ៗ កម្មវិធីបណ្តុះបណ្តាលនឹងត្រូវពិនិត្យឡើងវិញនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ។

បច្ចុប្បន្នក្រុមប្រឹក្សាអនុម័តសម្ភារសិក្សាមិនស្ថិតក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាទេ។ ចំណុចនេះ ធ្វើឲ្យមានការងារមិនមានប្រសិទ្ធភាពទេ ប្រសិនបើយើងគិតអំពីបញ្ហាពេលវេលា និងការដកហូតដំណើរការនៃការអនុម័តចេញពីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ព្រោះមន្ត្រីនាយកដ្ឋានកម្មវិធីសិក្សាជាអ្នកមានសមត្ថភាពខ្ពស់បំផុតក្នុងការវិនិច្ឆ័យលើគុណភាពសៀវភៅសិក្សាគោល និងសម្ភារឲ្យសមស្របទៅតាមកម្មវិធីសិក្សា ក្រុមប្រឹក្សាអនុម័តសម្ភារសិក្សាត្រូវនៅក្នុងនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ មន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមានភារកិច្ចយ៉ាងខ្លាំងលើការអភិវឌ្ឍកម្មវិធីសិក្សា សៀវភៅសិក្សារួមដំណើរការនៃការប្រឡង ការអនុម័តលើសៀវភៅសិក្សា ព្រោះថាមន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាមានចំណេះដឹងយ៉ាងជិតស្និតបំផុតនឹងខ្លឹមសារ និងទិសដៅរបស់កម្មវិធីសិក្សា។

សៀវភៅសិក្សា និងសម្ភារឧបទេសទាំងអស់ ដែលប្រើប្រាស់ក្នុងសាលារៀនត្រូវតែបញ្ជ្រាបផ្នែកយេនឌ័រ និងធ្វើយ៉ាងណាកំឲ្យមានការបង្ហាញចេញនូវគំនិតរើសអើង។ កម្មវិធីសិក្សា សៀវភៅសិក្សា និងការប្រឡងត្រូវវាយតម្លៃជាប្រចាំដើម្បីធានាឲ្យបានតួនាទីផ្នែកយេនឌ័រ។ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានឹង

ពិនិត្យឡើងវិញទៅលើសៀវភៅសិក្សា និងការប្រឡងត្រួងបានវាយតម្លៃជាប្រចាំ ដើម្បីធានាឲ្យបាននូវភាពសមស្របជាមួយស្ថានភាពអភិវឌ្ឍរបស់ប្រទេស។ ការពិនិត្យឡើងវិញជាប្រចាំលើកម្មវិធីសិក្សានឹងអាចកំណត់តម្រូវការថ្មីៗដែលត្រូវកែសម្រួលកម្មវិធីសិក្សា និងសៀវភៅសិក្សាផងដែរដើម្បីឲ្យសៀវភៅសិក្សាអាចឆ្លុះបញ្ចាំងកម្មវិធីសិក្សា។ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សានឹងមានការវិភាគក្នុងផែនការរយៈពេលមធ្យមរបស់ខ្លួនដើម្បីពនិត្យទៅលើកម្មវិធីសិក្សាឡើងវិញ។

### ២.៥.៤ ការគាំទ្រសៀវភៅសិក្សា

គ្រូបង្រៀនភាគច្រើនមិនមានគុណវុឌ្ឍិគ្រប់គ្រាន់ក្នុងការផ្លាស់ប្តូរការអនុវត្តក្នុងថ្នាក់រៀន ពីការសង្កត់ធ្ងន់លើការបង្រៀន រៀនដោយវិធីសាស្ត្រទន្ទេញចាំមាត់ (គ្រូមជ្ឈមណ្ឌល)ជំនួសដោយការបង្រៀននិងរៀនដោយវិធីសាស្ត្របែបសកម្ម (សិស្សមជ្ឈមណ្ឌល)។ ដូចនេះតម្រូវឲ្យមានការគាំទ្រ និងបំប៉នសមត្ថភាពដល់គ្រូបង្រៀនដើម្បីឲ្យពួកគាត់អាចមានសមត្ថភាពអនុវត្តវិធីសាស្ត្របែបសកម្ម( សិស្សមជ្ឈមណ្ឌល) នៅក្នុងថ្នាក់រៀន។ សៀវភៅសិក្សាសម្រាប់គ្រូគឺជាមគ្គុទ្ទេសក៍ណែនាំវិធីសាស្ត្របង្រៀន និងរៀនបែបថ្មី (បែបសកម្ម) មានសារៈសំខាន់ណាស់ក្នុងការគាំទ្រដល់គ្រូបង្រៀនដូចដែលបានលើកឡើង។ ការគាំទ្របន្ថែមត្រូវផ្តល់ឲ្យតាមរយៈយន្តការបណ្តុះបណ្តាលក្នុងអំឡុងពេលកំពុងបម្រើការងារ(វិក្រិតការ។

កម្មវិធីវិក្រិតការនឹងជួយដល់គ្រូបង្រៀនក្នុងការបង្កើតសម្ភារៈបានដោយខ្លួនឯង ដូចជាសៀវភៅកិច្ចតែងការបង្រៀនជាដើម។ ការផ្លាស់អាកប្បកិរិយាគ្រូបង្រៀន គឺជាការងារមួយដ៏លំបាក ហេតុនេះហើយត្រូវការគាំទ្រដ៏ធំធេងដើម្បីធានាឲ្យបានថា គ្រូបង្រៀនមានសម្ភារឧបទេសល្អៗនិងគ្រប់គ្រាន់ដែលនឹងជួយពួកគាត់ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបសកម្ម។

សម្ភារឧទេសបន្ថែម រួមមានសៀវភៅអំណាន សៀវភៅជំនួយស្មារតីផ្នែកគណិតវិទ្យាវិទ្យាសាស្ត្រងាយៗ និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀត ដូចជា ក្រដាស ខ្មៅដៃ ស្កុតបិទ។ល។ គួរផ្តល់ជូនគ្រូបង្រៀនក្នុងក្របខណ្ឌថវិកាដែលមានដើម្បីជួយសម្រួលដល់គ្រូបង្រៀន ឲ្យអាចបង្កើតឧបករណ៍ជំនួយក្នុងការបង្រៀនដោយខ្លួនឯង និងដើម្បីលើកម្ពស់ការសិក្សាបែបសកម្ម ពិសេសសម្រាប់កុមារថ្នាក់ដំបូង។ ការផ្តល់សៀវភៅ

សិក្សាគោលសម្រាប់សិស្ស និងសៀវភៅសិក្សាគោលសម្រាប់គ្រូ គឺជាអាទិភាពបំផុតសម្រាប់ការបង្រៀន និងរៀនប៉ុន្តែសម្ភារឧបទេសជាពិសេសគឺអំណានសម្រាប់កុមារថ្នាក់ដំបូង គឺមានសារៈសំខាន់ក្នុងការជួយជំរុញឲ្យកុមារមានទម្លាប់ក្នុងការអាន។

គោលដៅវែងសម្រាប់សាលាទាំងអស់នៅក្នុងប្រទេសកម្ពុជាគឺការបង្កើតបណ្ណាល័យមួយប្រកបដោយស្តង់ដារដែលបំពាក់ទៅដោយសៀវភៅសិក្សា និងឯកសារគ្រប់គ្រាន់ដើម្បីជំរុញឲ្យមានទម្លាប់នៃការអាននិងការសិក្សាស្រាវជ្រាវដែលជាជំនាញដ៏ចាំបាច់មួយសម្រាប់ការរៀនអស់មួយជីវិត។ ការបណ្តុះបណ្តាលគ្រូបង្រៀនមុនពេលចូលបម្រើការងារ និងក្នុងពេលបម្រើការងារនឹងជួយឲ្យគ្រូបង្រៀនមានសមត្ថភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោលបានល្អក្នុងសាលារៀន។ ការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោលបានល្អមានសារៈសំខាន់ណាស់ ដើម្បីរួមកាត់បន្ថយការបាត់បង់សៀវភៅសិក្សា និងជួយសម្រេចបានគោលដៅក្នុងការផ្តល់សៀវភៅសិក្សាគោល តាមអត្រាសៀវភៅមួយក្បាលសម្រាប់សិស្សម្នាក់គ្រប់មុខវិជ្ជាដល់សិស្សគ្រប់ៗរូប។ ការកាត់បន្ថយការបាត់បង់សៀវភៅសិក្សាគោលមានន័យថា យើងអាចផ្ទេរធនធានសម្រាប់យកទៅអភិវឌ្ឍបណ្ណាល័យ។

## ២.៦. គោលបំណងរបស់សាលាមធ្យមសិក្សាធនធាន

សាលាមធ្យមសិក្សាធនធាននឹងផ្តល់ដល់ក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាលនូវឱកាសធ្វើការជាមួយគ្នា ដើម្បីបង្កើតហេដ្ឋារចនាសម្ព័ន្ធមួយ ដែលផ្តល់ជាផែនការលម្អិតសម្រាប់ភាពល្អប្រសើរក្នុងការងារអប់រំ ដោយផ្តោតជាពិសេសលើការអនុវត្តគោលនយោបាយកម្មវិធីសិក្សាថ្មី។

សាលាមធ្យមសិក្សាធនានជានិមិត្តរូបនៃគម្រូប្រតិបត្តិ និងកម្មវិធីសកម្មភាពល្អប្រសើរសម្រាប់សាលាមធ្យមសិក្សាដ៏ទៃទៀតយកទៅអនុវត្តន៍ ដើម្បីបានលទ្ធផលសម្រេចអប់រំ។

សាលាមធ្យមសិក្សាធនធានប្តេជ្ញាចែករំលែកបទពិសោធន៍ ដែលពួកគេមាន ព្រមទាំងធ្វើការជាមួយនឹងសហគមន៍អប់រំទូលំទូលាយ ដើម្បីអភិវឌ្ឍការបង្រៀន និងរៀន ធ្វើឲ្យសាលារៀនមានការអភិវឌ្ឍជាបន្តបន្ទាប់។

**សាលាមធ្យមសិក្សាធនធានអាចជា៖**

-សាលារៀនមានស្រាប់ដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់

-សាលារៀនមានស្រាប់តែពុំទាន់មានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ហើយត្រូវបានគាំទ្រដើម្បីអភិវឌ្ឍសាលារៀននោះ ឲ្យបំពេញបានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ (រយៈពេលប៉ាន់ស្មាន ប្រហែលជាបីឆ្នាំ)លក្ខណៈវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាននឹងមាននៅក្នុងការណែនាំមួយ។

**សាលាមធ្យមសិក្សាធនធាននឹង៖**

-ផ្តល់ការដឹកនាំនិងតម្រង់ទិសក្នុងការជួយគាំទ្រដល់ការអនុវត្តកម្មវិធីសិក្សាថ្មីនៅមធ្យមសិក្សាទុតិយភូមិ។

-ប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនដែលល្អ ដើម្បីគាំទ្រគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាថ្មី។

-ក្លាយជា (ឬក្នុងកំឡុងពេលជាក់លាក់ណាមួយនឹងក្លាយជា) មជ្ឈមណ្ឌលឧត្តមភាពនៃការបង្រៀន និងរៀន។ក្លាយជា (ឬក្នុងអំឡុងពេលជាក់លាក់ណាមួយនឹងក្លាយជា) មជ្ឈមណ្ឌលឧត្តភាពមួយនៃការប្រតិបត្តិអប់រំ និងគម្រូនៃលទ្ធផលសិក្សាដែលអាចផ្សព្វផ្សាយបន្តទៅសាលារៀនដ៏ទៃទៀត។

-បង្ហាញថាគ្រប់ផ្នែកទាំងអស់នៃដំណើរការសាលរៀន និងទំនាក់ទំនងសាលារៀន សហគមន៍មានការអភិវឌ្ឍទៅមុខ ដោយយការអភិវឌ្ឍគុណភាពសាលារៀនធ្វើជាមូលដ្ឋាន។

-សរសេរចងក្រងឯកសារ ចែករំលែកឯកសារ និងបង្ហាញបទពិសោធន៍ពួកគេ ដែលមានក្នុងការចាប់ផ្តើមគំនិតអនុវត្តន៍កម្មវិធីសិក្សាថ្មី ព្រមទាំងជួយសាលារៀនដ៏ទៃទៀតឲ្យចេះតាក់តែង និងអនុវត្តន៍ការផ្លាស់ប្តូរ ក្នុងបរិបទផ្ទាល់ខ្លួនរបស់ពួកគេ។

-ចែករំលែកបទពិសោធន៍នៃការអភិវឌ្ឍធនធានមនុស្សនិងធនធានសម្ភារៈជាមួយសាលរៀនដ៏ទៃទៀត។

-ខិតខំឲ្យស្មើនឹងសាលារៀនដែលមានប្រតិបត្តិ និងលទ្ធផលលេចធ្លោរបស់ប្រទេសមួយចំនួនក្នុងតំបន់។

-ត្រូវបានសាងសង់ថ្មីនិង/ឬជួសជុលដោយផ្អែកទៅតាមលក្ខណ្ឌមូលដ្ឋាន និងផ្តល់នូវសម្ភារៈរូបវន្តពិសេស ដូចជាបណ្ណាល័យ បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT)។

-ទទួលមូលនិធិគ្រប់គ្រាន់ពីគ្រប់អ្នកពាក់ព័ន្ធ និងពីគ្រប់មជ្ឈដ្ឋាន។

-ទទួលមូលនិធិគ្រប់គ្រាន់ ដើម្បីឲ្យសាលារៀនអានមានមរិក្ខាសំខាន់ៗ ដូចជាសៀវភៅសិក្សា បរិក្ខាបន្ទប់ពិសោធន៍ កញ្ចប់សម្ភារៈ (Kit) និងកុំព្យូទ័រដែលមានកម្មវិធីផ្នែកទន់ថ្មីៗ និងកម្មវិធីប្រឆាំងនឹងមេពោគដែលមនាអាជ្ញាប័ណ្ណអាចធ្វើឲ្យការប្រើប្រាស់មានប្រសិទ្ធភាពនិងធ្វើឲ្យមានបច្ចុប្បន្នភាពនូវកម្មវិធីមួយចំនួន។

-ត្រូវបានផ្តល់អាហាររូបករណ៍ដើម្បីជួយសិស្សឲ្យសម្រេចបានការសិក្សាតាមរយៈអាហាររូបករណ៍ ២ប្រភេទគឺ៖

១. អាហាររូបករណ៍ចំពោះសិស្សពូកែ

២. អាហាររូបករណ៍ចំពោះសិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច។

## ២.៧. ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនធាន

ផលប្រយោជន៍របស់សាលាមធ្យមសិក្សាធនធានគឺៈ

### ២.៧.១.ចំពោះសិស្ស

- មានឱកាសទទួលបានការបង្រៀន និងរៀនដោយមានគុណភាពខ្ពស់

- មានឱកាសសម្រេចបានលទ្ធផលសិក្សាល្អប្រសើរសម្រាប់សិស្សពូកែភាគច្រើន

- ទទួលបានគោលនយោបាយជួយសិស្សក្រីក្រ និងផ្តល់អាហារូបករណ៍ ចំពោះសិស្សពូកែ សិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច។

### ២.៧.២.ចំពោះបុគ្គលិកអប់រំ

- មាននាយក នាយករងសាលារៀនដឹកនាំប្រកបដោយគុណភាពល្អ និងមានទេពកោសល្យខ្ពស់ក្នុងមុខវិជ្ជាជីវៈ។

- ទទួលបានរបៀបរៀន និងបន្តរៀនពេញមួយជីវិតជាគម្រូសម្រាប់សិស្សយកទៅប្រតិបត្តិតាម។

-ទទួលបានការអភិវឌ្ឍវិជ្ជាជីវៈនិងមានឱកាសបង្កើនបំណិនបង្រៀនតាមមុខវិជ្ជាឯកទេសប្រកបដោយភាពល្អប្រសើរ។

- ទទួលបានការពណ៌នាពីមុខតំណែង (លក្ខណៈបទពិសោធនន៍ គុណសម្បត្តិបុគ្គល និងលក្ខណៈដ៏ទៃទៀត) ច្បាស់លាសសម្រាប់តួនាទីបង្រៀនទាំងអស់ព្រមទាំងតម្រូវការបំពេញការងារដ៏ទៃទៀតឲ្យស័ក្តិសមជាសាលាមួយដែលមានបុគ្គលិកអប់រំប្រកបដោយស្តង់ដារខ្ពស់។

-ចូលរួមអភិវឌ្ឍន៍កម្មវិធីវាយតម្លៃការបំពេញការងារមួយដោយប្រើអាំងឌីកាទ័រស្វ័យវាយតម្លៃការប្រតិបត្តិផ្នែកខ្លះដូចជាៈ ខ្លឹមសារមុខវិជ្ជា និងវិធីសាស្រ្តបង្រៀន និងរៀន។

### ២.៧.៣.ចំពោះមាតាបិតា និងអាណាព្យាបាលសិស្ស

- មានមោទនភាពដោយសារកូនចៅគាត់ទទួលបានឱកាសអប់រំដ៏ល្អបផុត មានការគ្រប់គ្រងសាលារៀន និងគ្រប់គ្រងហិរញ្ញវត្ថុមានតម្លាភាព ដោយមានការចូលរួមពីមាតាបិតា អាណាព្យាបាលសិស្ស និងសហគមន៍។

- ទទួលបានព័ត៌មានត្រលប់ជាប្រចាំ ពីការអភិវឌ្ឍរបស់កូនចៅគាត់។

-ត្រូវបានគាត់មើលឃើញថាសាលារៀនជាមជ្ឈមណ្ឌលមួយនៃ សហគមន៍សិក្សា (ការសិក្សាទៅវិញទៅមក រវាងសិស្ស គ្រូ និងសហគមន៍។

### ២.៧.៤.ចំពោះសាលារៀន

-ទទួលយក និងគាំទ្រការផ្តួចផ្តើមកម្មវិធីសិក្សាដែលបង្កើតឡើងដោយសិស្ស និងគ្រូបង្រៀន ព្រមគោលវិធីសិស្សមជ្ឈមណ្ឌល សំដៅទៅរកការសិក្សាពេញមួយជីវិត និងការសិក្សាប្រកបដោយភាពបត់បែន ទន់ភ្លន់រស់រវើក។

-ត្រូវបានទទួលស្គាល់ជាសាលារៀនមួយឈានមុខ(ក្នុងការដឹកនាំអនុវត្តគ្រប់ផ្នែក) ដែលផ្តល់ការបង្រៀន និងរៀនប្រកបដោយគុណភាពក្នុងស្រុក/ខណ្ឌ ខេត្ត/ក្រុង និងក្នុងប្រទេស។

- ត្រូវបានបំពាក់សម្ភារៈរូបវន្ត ប្រកបដោយគុណភាព និងបំប៉នបុគ្គលិកឲ្យមានសមត្ថភាពពេញលេញ ដើម្បីសម្រេចវត្ថុបំណងសាលាមធ្យមសិក្សាធនធាន។

- ក្លាយជា (ក្នុងរយៈពេលជាក់លាក់ណាមួយ) មជ្ឈមណ្ឌលមានលទ្ធផលសិក្សាល្អប្រសើរ និងមានការទទួលស្គាល់ដោយផ្អែកលើគោលការណ៍សាលារៀនមានប្រសិទ្ធភាព។

- កំណត់គោលដៅជាក់លាក់ (ផ្តែកលើលក្ខខណ្ឌមូលដ្ឋាន) ដើម្បីបង្កើតភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិប្រចាំឆ្នាំសិក្សា រួមទាំងសិស្សស្រី សិស្សមកពីតំបន់ជួបការលំបាក តំបន់ដាច់ស្រយាល សិស្សក្រីក្រ និងសិស្សជនជាតិភាគតិច។

## ២.៧.៥.ចំពោះសាលារៀនក្នុងបណ្តាញ

- មានការប្រតិបត្តិបង្រៀន និងរៀនល្អបំផុតដែលបង្ហាញឡើងតាមរយៈការអនុវត្តកម្មវិធីសិក្សាថ្មី។

- អាចរៀនសូត្រធ្វើជាគម្រូក្នុងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការរៀន ការដឹកនាំគ្រប់គ្រងសាលារៀន។

- អនុវត្តន៍ការងារតាមបែបសហប្រតិបត្តិការមួយសមស្របតាមចក្ខុវិស័យ និងបេសកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា គោលនយោបាយធំទាំង៣គឺៈសមធម៌ក្នុការចូលរៀន គុណភាព និងប្រសិទ្ធភាពសេវាអប់រំ និងការកសាងសមត្ថភាពដើម្បីឈានទៅរករបបការងារបែបវមជ្ឈការ។

- អភិវឌ្ឍន៍សាលារៀនឲ្យក្លាយជាមជ្ឈមណ្ឌលនៃឧត្តមភាពអប់រំ ដោយយកការបង្រៀន និងរៀនជាមូលដ្ឋាន។

- អភិវឌ្ឍសាលារៀនឲ្យក្លាយជាមជ្ឈមណ្ឌល នៃការប្រតិបត្តិគម្រូសម្រេចលទ្ធផលខ្ពស់ អាចផ្សព្វផ្សាយបទពិសោធន៍ទៅសាលារៀនដ៏ទៃទៀត។

- ផ្តល់ឱកាសសម្រាប់ការទទួលស្គាល់ការរៀនពូកែ និងមានគោលនយោបាយគាំទ្រចំពោះសិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច។

## ២.៨. លក្ខណៈវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាន

១. សាលារៀនមានទីតាំងក្នុងទីប្រជុំជនខេត្ត/ក្រុង ស្រុក/ខណ្ឌ

២. សាលាមានការគ្រប់គ្រង និងសហការល្អជាមួយសហគមន៍

៣. សាលារៀនមានទីតាំងធំទូលាយ ងាយស្រួលក្នុងការសាងសង់អគារបន្ថែមនៅពេលអនាគត

៤. សាលារៀនមានសុវត្ថិភាព និងសន្តិសុខ ជានាការពារបានរាល់វត្ថុមានតម្លៃក្នុងសាលា

៥. សាលារៀនមានប្រភពថាមពលអគ្គិសនី និងទឹកស្អាតសម្រាប់ប្រើឲ្យបន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ

## ២.៩. បណ្ដាញសាលាមធ្យមសិក្សាធនធាន

**• បណ្ដាញសាលាមធ្យមសិក្សាធនធាន**

យុទ្ធសាស្ត្របណ្ដាញសាលាមធ្យមសិក្សាធនធានរួមមានការបណ្ដុះបណ្ដាលវប្បធម៌ធ្វើការងារជាមួយគ្នា ដកពិសោធនការងារជាមួយគ្នាទៅវិញទៅមក ការសាមគ្គីសហការគ្នា រវាងសាលារៀននានា និងសាលារៀនក្នុងបណ្ដាញព្រមទាំងសហគមន៍ទូលំទូលាយ។

សាលាមធ្យមសិក្សាទាំងអស់នឹងស្ថិតក្នុងបណ្ដាញនៃសាលាមធ្យមសិក្សាធនធានដែលមានកិច្ចសហការជាមួយយ៉ាងជិតស្និទ្ធ។ សាលាមធ្យមសិក្សាធនធានជាស្នូលរបស់បណ្ដាញ។ សាលាមធ្យមសិក្សាបណ្ដាញនឹងត្រូវបានផ្ដល់អគារ និងសម្ភារៈរូបវន្តបន្ថែម ដើម្បីជំរុញសហប្រតិបត្តិរវាងសាលារៀននៅក្នុងបណ្ដាញ និងផ្ដល់ភាពជាអ្នកដឹកនាំក្នុងផ្នែកអភិវឌ្ឍកម្មវិធីសិក្សា។

**• វត្ថុបំណងរបស់បណ្ដាញសាលាមធ្យមសិក្សាធនធាន**

- បង្កើនឱកាស និងលទ្ធផលអប់រំ ចំពោះសិស្សនៅក្នុងតំបន់របស់បណ្ដាញ
- ជំរុញការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន
- លើកកម្ពស់ស្មារតីចែករំលែកបទពិសោធន៍នៃការបង្រៀន និងរៀន
- ពង្រឹងការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំរបស់សាលារៀន

- ណែនាំកសាងផែនការដែលនាំឲ្យសាលារៀនមានការរីចម្រើន
- អភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀន តាមរយៈការណែនាំផ្ទាល់ និងការអភិវឌ្ឍវិជ្ជាជីវៈ
- ប្រែក្លាយសាលាមធ្យមសិក្សាធនធានទៅជាសមាសភាគដ៏រឹងមាំមួយ របស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការធ្វើឲ្យមានការអភិវឌ្ឍនៅមធ្យមសិក្សា។

- **មណ្ឌលមធ្យមសិក្សាធនធាននឹង៖**

- ប្រើធនធានសម្រាប់បណ្តាញដើម្បីលើកទឹកចិត្ត និងជួយគាំទ្រដល់ការបង្កើតថ្មី
- កសាងទំនុកចិត្តដល់នាយកសាលារៀន និងគ្រូបង្រៀនក្នុងការគាំទ្រដល់ការធ្វើឲ្យមានការផ្លាស់ប្តូរនិងការបង្កើតថ្មី
- ស្វែងរកភាពជឿនលឿនបំផុតដើម្បីឈានដល់ឧត្តមភាព គាំទ្រយ៉ាងសកម្មដល់ការបង្រៀន ការដឹកនាំក្រុមសិក្សា ការងារពិភាក្សា និងការស្រាវជ្រាវគម្រោង
- ធ្វើឲ្យលទ្ធផលការអប់រំរបស់សិស្សកើនឡើង
- កំណត់អាទិភាពគោលដៅបណ្តាញរបស់ខេត្ត/ក្រុង ស្រុក/ខណ្ឌដើរស្របគ្នា
- ប្រើទិន្នន័យរបស់បណ្តាញ ដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្វះខាតដែលត្រូវកែលម្អ
- រាយការណ៍ពីប្រសិទ្ធភាព នៃការប្រើប្រាស់ធនធាន
- ប្រើធនធានរបស់បណ្តាញ ដើម្បីលើកទឹកចិត្តនិងជួយគាំទ្រដល់ការបង្កើតថ្មី តាមរយៈសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ
- សម្របសម្រួល និងផ្សព្វផ្សាយភាពជោគជ័យរបស់បណ្តាញ
- កសាងជាដៃគូដ៏ទូលាយជាមួយសហគមន៍ ដើម្បីជំរុញការសិក្សារបស់សិស្ស និតស្វែងរកមាគ៌ាសម្រាប់ការសិក្សា និងបម្រើការងារនៅថ្ងៃអនាគត។
- រៀបចំពេលវេលាទៀងទាត់ក្នុងប្រព័ន្ធ ដើម្បីចែករំលែកបទពិសោធន៍ល្អៗ

- ទទួលស្គាល់សក្តានុពលនៃគំនិតផ្តួចផ្តើម កម្មវិធីគម្រូនានាដោយជំរុញនិងគាំទ្រដល់ទង្វើទាំងនោះ
- កំណត់កន្លែងដែលមានតម្រូវការដូចគ្នា ដែលអាចជាចំណុចដៅរួមនៃការប្រឹងប្រែងសម្រាប់ការរីកចម្រើន
- ជំរុញសាលារៀន ឲ្យសហការគ្នាចែករំលែកគំនិត និងផែនការ
- ប្រើប្រាស់ទិន្នន័យពីបណ្តាញ ដើម្បីកំណត់តម្រូវការអភិវឌ្ឍវិជ្ជាជីវៈនាយកសាលារៀន និងគ្រូបង្រៀន

- រូបភាពទី១៖គន្លូសតាងបណ្តាញសាលាមធ្យមសិក្សាធនធាន



## ២.១០. ការគ្រប់គ្រង និងដំណើរការសាលាមធ្យមសិក្សាធនធាន

ដើម្បីពង្រឹង និងការគាំទ្រដល់ដំណើរការសាលារៀន រួមទាំងអគារធនធាន និងសាលាមធ្យមសិក្សាបណ្តាញ ពិសេសក្នុងដំណាក់កាលដំបូង ការបង្កើតគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធានត្រូវធ្វើជាចាំ

បាច់ និងបន្ទាន់ បន្ទាប់ពីទទួលបានប្រកាសស្តីពីការបង្កើតអគាធនធាន និងប្រកាសទទួលស្គាល់សាលាមធ្យមសិក្សាបណ្តាញជាផ្លូវការពីក្រសួងអប់រំ យុវជន និងកីឡា។

*១. គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញ*

គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញត្រូវបង្កើតឡើងដើម្បីជួយគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន អគារធនធាន និងសាលាមធ្យមសិក្សាបណ្តាញ។ សមាលភាពភារកិច្ច

និងរចនាសម្ព័ន្ធរបស់គណៈកម្មការនេះមានដូចខាងក្រោម៖

*ក. សមាសភាព*

១. នាយកសាលាមធ្យមសិក្សាធនធាន (ដែលមានអគាធនធានស្ថិតនៅ) ជាប្រធាន

២. នាយកសាលាមធ្យមសិក្សា (សាលាមធ្យមសិក្សាបណ្តាញទាំងអស់) ជាសមាជិក

គណៈកម្មការនេះត្រូវបានចាត់តាំងតាមលិខិតឧទេសនាមរបស់បន្ទីអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។

*ខ. ភារកិច្ច*

- ជួយសម្រួលលក្ខខណ្ឌចាំបាច់ទាំងផ្នែកបច្ចេកទេស និងរដ្ឋបាលរបស់សាលាមធ្យមសិក្សាធនធាន និងបណ្តាញឲ្យដំណើរការ និងទទួលបានលទ្ធផលល្អ ពិសេសក្នុងការអនុវត្ត គោលនយោបាយសាលាមធ្យមសិក្សាធនធានរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

- ប្រើប្រាស់ឲ្យអស់លទ្ធភាព និងដោះស្រាយនិរន្តរភាពដំណើរការរបស់អគារធនធាន រួមមានរៀបចំលក្ខខណ្ឌដើម្បីប្រើប្រាស់សម្ភាររូបវន្ត ព្រមទាំងស្វែងរក និងប្រើប្រាស់ថវិការបស់អគារធនធាន។

- ធ្វើការប្រាស្រ័យទាក់ទងជាមួយសហគមន៍សិក្សា និងអ្នកពាក់ព័ន្ធដើម្បីបញ្ជ្រាបបញ្ញត្តិថ្មី (សាលាមធ្យមសិក្សាធនធាន អគារធនធាន និងសាលាមធ្យមសិក្សាបណ្តាញ)។

- ធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន និងណ្តាញផ្អែកលើការវិភាគទិន្នន័យនិងអទិភាពរបស់មូលដ្ឋាន ដូចជាកំណត់មណ្ឌាកន្លែងដែលមានត្រូវការដូចគ្នា ធ្វើជាចំណុចរួមនៃការប្រឹងប្រែងសម្រាប់ការរីកចម្រើន ហើយផ្ញើទៅក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ/ គម្រោងលើកម្ពស់គុណភាពអប់រំ)។

- ផ្សព្វផ្សាយអនុវត្ត និងវាយតម្លៃ (ការអនុវត្តការងារ)ផែនការអនុវត្តសាលាមធ្យមសិក្សាធនធាន។

- បង្កលក្ខណៈងាយស្រួលដល់សិស្សានុសិស្សក្នុងសាលាមធ្យមសិក្សាបណ្តាញ ឲ្យទទួលបានការប្រើប្រាស់អគាធនធាន។

- អភិវឌ្ឍន៍វិជ្ជាជីវៈបុគ្គលិកអប់រំទាំងចំណេះដឹងសមត្ថភាព (Competencies) និងឥរិយាបថ (វិធីសាស្ត្របង្រៀន ស្រាវជ្រាវ ភាសាអង់គ្លេស និង ITC....) ឲ្យដល់កម្រិតស្តង់ដារក្នុងតំបន់ ឬអន្តរជាតិ ទាំងនៅសាលាមធ្យមសិក្សាធនធាន ទាំងសាលាមធ្យមសិក្សាមណ្ឌាញ និងអនុវត្តវប្បធម៌ចែករំលែក។

- ចាត់ទាំងបុគ្គលិកដែលមានស្រាប់នៅក្នុងវិទ្យាល័យ ឬសាលាមធ្យមសិក្សាបណ្តាញតាមស្មារតីសេចក្តីណែនាំលេខ០៧អយក.សណន ចុះថ្ងៃទី១៤ខែមករាឆ្នាំ ២០១០។

• ធ្វើរបាយការលទ្ធផលការងារតាមកាលកំណត់ (ខែ ត្រីមាស និងឆ្នាំ) ជូនក្រសួងអប់រំ យុវជន និងកីឡា (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ/ គម្រោងលើកកម្ពស់គុណភាពអប់រំ)។

• ពង្រឹងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ លើការងារគ្រប់គ្រង ការប្រើប្រាស់ធនធាន (មនុស្សសមភារៈ ថវិកា) របស់សាលារៀន។

• ធ្វើសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ ស្ថាប័ននានា និងសហគមន៍ដើម្បីធានានិរន្តរភាពដំណើរការសាលាមធ្យមសិក្សាធនធាន សំដៅផ្តល់ឱកាសឲ្យអ្នកពាក់ព័ន្ធចូលរួមទទួលខុសត្រូវក្នុងការគ្រប់គ្រងថវិកា ធ្វើផែនការអភិវឌ្ឍ អនុវត្តន៍ផែនការ និងវាយតម្លៃ។

### *គ. ទំនាក់នងគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញ*

គណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញត្រូវមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញតាមរចនាម្ព័ន្ធខាងក្រោម៖

*រូបទី២.ទំនាក់នងរវាងគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញ*



## ២.១០.១. ធនធានមនុស្សរបស់សាលាមធ្យមសិក្សាធនធាន

**ក. គណៈគ្រប់គ្រងសាលាមធ្យសិក្សាធនធាន**

នាយក/នាយិកា នាយករង/នាយិការងត្រូវរក្សាតាមរចនាសម្ព័ន្ធដែលមានស្រាប់របស់វិទ្យាល័យស្របតាមសេចក្ដីណែនាំលេខ២៥៦អយក.សណនចុះថ្ងៃទី២៩ខែមករាឆ្នាំ២០០២។

ខ. គណៈគ្រប់គ្រងអគាធនធាន (មើលរូបភាពទី២)

គ. បុគ្គលិកបង្រៀន មិនបង្រៀន និងបុគ្គលិកផ្សេងទៀត

ការប្រើប្រាស់បុគ្គលិកបង្រៀន មិនបង្រៀន និងបុគ្គលិកផ្សេងទៀត ត្រូវអនុវត្តន៍តាមសេចក្ដីណែនាំលេខ២៥៦អយក.សណនចុះថ្ងៃទី២៩ខែមករាឆ្នាំ២០០២ ស្ដីពីការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសាលាមតេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងគរុកោសល្យ។

**ឃ. ធនធានមនុស្សសម្រាប់បន្តវេន និងជានានិរន្តរភាព**

ដើម្បីទាញយកផលប្រយោជន៍អតិបរិមាពីក្រុមការងារថ្នាក់ជាតិ (គ្រូឧទេសដែលមកពីក្រសួងអយ.ក)នៃគម្រោងលើកកម្ពស់គុណភាពអប់រំ ពិសេសក្នុងដំណាក់កាលដំបូង សាលាមធ្យមសិក្សាធនធានគួរជ្រើសរើសបុគ្គលិកអប់រំឆ្នើម(អាចជានាយករងទទួលបន្ទុកបចេកទេស ប្រធានក្រុមបច្ចេកទេស អ្នកស្ម័គ្រចិត្ត...) នៅសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្ដាញ ឧទាហរណ៍ បំណិនភាសាអង់គ្លេស បំណិនគ្រប់គ្រងដឹកនាំ បំណិនកុំព្យូទ័រជាដើម។

## ២.១០.២. ការគាំទ្រសាលាមធ្យមសិក្សាធនធានចំពោះសាលាមធ្យមសិក្សាបណ្ដាញ

សាលាមធ្យមសិក្សាធនធាន ជាសាលារៀនមួយដែលទទួលបានធនធានសម្ភារៈមួយចំនួន ហើយធនធានសម្ភារៈទាំងនោះពុំទាន់មាននៅតាមសាលាមធ្យមសិក្សាមួយចំនួនធំក្នុងសាលាមធ្យមសិក្សាបណ្ដាញ។ ក្នុងន័យនេះ សាលាមធ្យមសិក្សាធនធានត្រូវទទួលខុសត្រូវអប់រំដល់សិស្ស បុគ្គលិកអប់រំ និងសហគមន៍ ហើយធ្វើឲ្យធនធាន និងសម្ភារៈទាំងនោះអាចប្រើប្រាស់បានជាអតិបរិមាដោយអ្នកឯទៀតក្នុងសាលាមធ្យមសិក្សាបណ្ដាញ សំដៅបង្កើនគុណភាពសេវាកម្មអប់រំ។សាលាមធ្យមសិក្សាធនធានអាចផ្ដល់ ៖

• កន្លែងឲ្យគ្រូ និងអ្នកគ្រប់គ្រងអប់រំនៅក្នុងសាលាមធ្យមសិក្សាបណ្ដាញមកជួបជុំគ្នាដើម្បីស្វែងរកពីផលប្រយោជន៍នានា ដែលសាលាមធ្យមសិក្សាធនធានអាចផ្ដល់ដល់ពួកគេ។

• ធនធានដែលមានក្នុងសាលាមធ្យមសិក្សាធនធាន (ដែលធនធានទាំងនោះពុំទាន់មាន ឬពុំទាន់ប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពក្នុងសាលារៀននានា ក្នុងសាលាមធ្យមសិក្សាបណ្ដាញ) ដើម្បីអភិវឌ្ឍន៍សមត្ថភាពដល់គ្រូបង្រៀនក្នុងសាលាមធ្យមសិក្សាបណ្ដាញ។

• មូលដ្ឋានសម្រាប់គ្រូឧទេស(ក្រុមបច្ចេកទេស)អភិវឌ្ឍន៍បំណិន និងសមត្ថភាពណាដែលពួកគេពុំទាន់មាន។

•មូលដ្ឋានមួយសម្រាប់អង្គភាពអប់រំដ៏ទៃទៀត រៀបចំកម្មវិធីបណ្ដុះបណ្ដាលដល់មូលដ្ឋាន និងផ្ដល់ឱកាសដល់គ្រូបន្តការសិក្សា ដើម្បីបង្កើនចំណេះដឹងសម្រាប់មេរៀនខ្លះ។

•ឱកាសសម្រាប់ការចែករំលែកសម្ភាររូបវន្តឲ្យបានប្រើប្រាស់ជាអតិបរិមា។

•បណិនបច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍(ICT) និងណែនាំគ្រូអំពីវិធីប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយចម្រុះ (Multi-media)។

•បណ្ណាល័យសម្រាប់ផ្ដល់សម្ភារៈជំនួយដល់ការបង្រៀន និងជាប្រភពឯកសារយោងមួយសម្រាប់សាលាមធ្យមសិក្សាបណ្ដាញ។

• ជាកន្លែងមួយដែលបង្ហាញឲ្យសិស្សមើលឃើញបញ្ញត្តិវិទ្យាសាស្ត្រ និងសង្គម ជាពិសេសចំពោះបញ្ញត្តិដែលមានការពិបាកក្នុងការបង្ហាញ ប្រសិនគ្មានការអនុវត្តនៅក្នុងបន្ទប់ពិសោធន៍វិទ្យាសាស្ត្

## ២.១១.ភារៈកិច្ចរបស់សាលាមធ្យមសិក្សាធនធាន

នាំមុខសាលាមធ្យមសិក្សាដ៏ទៃទៀត ក្នុងការអនុវត្តគោលនយោបាយ គោលការណ៍ កម្មវិធីសិក្សាគោល និងលិខិតបទដ្ឋាននានារបស់ក្រសួងអប់រំ យុវជន និងកីឡា អាជ្ញាធររាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។

• ពង្រឹងភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អលើការងារគ្រប់គ្រង និងប្រើប្រាស់ (មនុស្ស សម្ភារៈថវិកា) របស់សាលារៀន ដោយបើកទូលាយឱ្យសាលាបណ្ដាញធ្វើសកម្មភាពប្រតិបត្តិ ចែករំលែកពីគ្នានូវបទពិសោធន៍នៃការអភិវឌ្ឍធនធានមនុស្ស ធនធានសម្ភារៈ និងផ្នែកស្មារតីសំដៅពង្រឹងគុណភាព និងប្រសិទ្ធភាពអប់រំ

• អភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនទាំងផ្នែកចំណេះដឹង ផ្នែកជំនាញឯកទេស និងផ្នែកចិត្តកុកោសល្យឱ្យដល់កម្រិតស្ដង់ដាគ្រូក្នុងតំបន់ឬអន្តរជាតិទាំងនៅសាលាមធ្យមសិក្សាធនជាន និងសាលាបណ្ដាញ (ជាពិសេសភាសាអង់គ្លេស វិទ្យាសាស្ត្រ វិស្វកម្ម បចេកវិទ្យា គណិតវិទ្យា បច្ចេកវិទ្យាព័ត៌មាន កម្មវិធីសិក្សាថ្មី និងសមត្ថភាព សិក្សាស្រាវជ្រាវបន្ថែម ឬស្វ័យរិក្រឹតការ ស្វ័យសុក្រឹតការ)

• ពង្រឹងសមត្ថភាពវាយតម្លៃលទ្ធសិក្សារបស់សិស្ស ដោយសាលារៀនធ្វើស្វ័យវាយតម្លៃសាសាលារៀន ដើម្បីក្លាយជាសាលារៀនឱ្យទៅជាបជ្ឈមណ្ឌលនៃឧត្តមភាព និងសាលាកុមារមេត្រី ព្រមទាំងអាចផ្សព្វផ្សាយទៅសាលារៀនដ៏ទៃទៀត

• ពង្រឹងអនុវត្តក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន សំដៅបង្កលក្ខណៈឱ្យគ្រូបង្រៀនទាំងអស់មានឥរិយាបថវិជ្ជមាន មានមនសិការវិជ្ជាជីវៈខ្ពស់ និងមានសីលធម៌ល្អ

• បង្កលក្ខណៈឱ្យសិស្សបានបន្តការសិក្សាប្រកបដោយសមធម៌ តាមរយៈការផ្តល់អាហារូបករណ៍ ដល់សិស្សក្រីក្រ និងសិស្សក្រីក្ររៀនពូកែ ជាពិសេសការយកចិត្តទុកដាក់ដល់សិស្សកំព្រា ដ សិស្សពិការ សិស្សជនជាតិភាគតិច សិស្សស្រី និងសិស្សស្ថិតក្នុងគ្រួសារមានវិបត្តិ

• ពង្រឹងការចូលរួមអភិវឌ្ឍវិស័យអប់រំ និងការគ្រប់គ្រងរាល់សកម្មភាពក្នុង និងក្រៅសាលារៀន របស់សិស្ស ពីសំណាក់សហគមន៍មាតាបិតា អ្នកអាណាព្យាបាលសិស្ស សំដៅឱ្យការអនុវត្ត ការងារមានស្វ័យភាព និងគណនេយ្យភាព

• ធ្វើសហប្រតិបត្តិការជាមួយអង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ននានា និង សហគមន៍ ក្នុងគោលបំណងជានានិរន្តរភាពសាលាមធ្យមសិក្សាធនធាន និងធ្វើឱ្យកាន់តែប្រសើរ ឡើងនូវការសិក្សា ការបង្រៀន និងការស្រាវជ្រាវ។

### ២.១១.១. គោលបំណងសាលាមធ្យមសិក្សាធនធាន

**• ការផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាបន្ន សមធម៌ និងឱកាសអប់រំពេញមួយជីវិត** ដោយផ្តោតលើ អន្តរាគមន៍គាំទ្រ និងលើកទឹកចិត្តដល់សិស្សជួបការលំបាក កម្មវិធីសិក្សាទំនើប( ជំនាញ ទន់ បំណិនជីវិត និងអន្តមុខវិជ្ជា ) បុគ្គលិកអប់រំប្រកបដោយគុណភាព និងវិជ្ជាជីវៈខ្ពស់ និងហេដ្ឋារចនាស ម្ព័ន្ធនិងសម្ភារបរិក្ខាស្តង់ដា ដែលបម្រើដល់វិស័យអប់រំពេញមួយជីវិត

• ការដឹកនាំ និងគ្រប់គ្រង ប្រកបដោយស្វ័យភាព និងគណនេយ្យភាព

• ការស្រាវជ្រាវ ផ្តោតលើការជំរុញការសិក្សាមុខវិជ្ជាសង្គម និងវិទ្យាសាស្ត្រ( វិទ្យាសាស្ត្រ បច្ចេក វិទ្យា វិស្វកម្ម និងគណិតវិទ្យា ) ដើម្បីលើកកម្ពស់គុណភាព នៃការបង្រៀន និងការរៀន

• ការបង្កើតថ្មី ផ្តោតលើការសិក្សាតាមបែមការសរសេរគម្រោង ការត្រិះរិះពិចារណា ការដោះ ស្រាយបញ្ហា និងការរៀនផ្អែលើការអភិវឌ្ឍខួរក្បាល

• ការកៀរគរធនធាន តាមវិធានបើកទូលាយឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ ដែលធានាបាន នូវលទ្ធផល តម្លាភាព និងគណនេយ្យភាព

• ការទាក់ទាញសហគមន៍ ដោយផ្តោតនូវជំនឿជាក់លើការដឹកនាំនិងគ្រប់គ្រង ដំណើរការបង្រៀន និងរៀន លទ្ធផលសិក្សា និងបង្កើនការគាំទ្រពីសហគមន៍

### ២.១១.២. ហេដ្ឋារចនាសម្ព័ន្ធនិងសម្ភាររូបវន្ត

• ការផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងឱកាសអប់រំពេញមួយជីវិត

- ➢ ទីតាំង ៖ វិទ្យាល័យដែលមានទហំដី ចាប់ពី ២ ហត្ថ និង ស្ថិតនៅទីប្រជុំជនខេត្ត ក្រុង ស្រុក ខណ្ឌ
- ➢ ប្រភេទអគារ ៖ អគាសិក្សា អគាធនធាន (បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់រៀន ភាសា កុំព្យូទ័រ បណ្ណាល័យ កន្លែងស្តុកសម្រាម បង្គន់អនាម័យ អន្តេវាសិកដ្ឋាន ផ្លូវជម្រាលនិងផ្លូវដើរសម្រាប់សិស្សពិការ អាហារដ្ឋាន បន្ទប់សុខភាព ឃ្លាំងសម្ភារៈ បន្ទប់បំណិនជីវិត និងប្រឹក្សាអាជីព
- ➢ សម្ភារបរិក្ខា ៖ ប្រព័ន្ធទឹកស្អាតនិងលូទឹក ប្រព័ន្ធអគ្គិសនី ប្រព័ន្ធពន្លត់អគ្គីភ័យ បណ្តាញកុំព្យូទ័រនិងអ៊ីនធើណិត

• សម្ភារៈសម្រាប់ការស្រាវជ្រាវ

- ➢ បណ្ណាល័យអេឡិចត្រូនិក
- ➢ កុំព្យូទ័រសម្រាប់គ្រូបង្រៀន
- ➢ បន្ទប់សម្រាប់ស្រាវជ្រាវ
- ➢ ឯកសារស្រាវជ្រាវ
- ➢ បណ្តាញទរគមនាគមន៍

• ការកៀរគរធនធាន តាមវិធានបើកទូលាយឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ ដែលជានាបាននូវលទ្ធផលតម្លាភាព និងគណនេយ្យភាព

- គេហទំព័រ និងប្រព័ន្ធទំនាក់ទំនងរបស់សាលារៀន
- បណ្ណផ្ទត់ស្តីពីព័ត៌មានសាលារៀន
- បញ្ជរផ្សព្វផ្សាយ

•ការទាក់ទាញសហគមន៍ ដោយផ្តល់នូវជំនឿជាក់លើការដឹកនាំនិងគ្រប់គ្រងដំណើរការបង្រៀន និងរៀន លទ្ធផលសិក្សា និងបង្កើនការគាំទ្រពីសហគមន៍

- បន្ទប់ទំនាក់ទំនងព័ត៌មាន
- ប្រអប់សំបុត្រ

## ២.១១.៣.ការគាំទ្រនិងការទទួលស្គាល់

កាផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាបន្ន សមធម៌ និងឱកាសអប់រំ

ពេញមួយជីវិត

•គុណភាពអបរំ

- របាយកាណ៍ស្វ័យវាយតម្លៃសាលារៀន
- របាយការណ៍អធិការកិច្ច (អធិការកិច្ចតំបន់)
- ការធ្វើតេស្តថ្នាក់រៀន
- ការប្រឡងថ្នាក់ជាតិ
- ការវាយតម្លៃរបស់សហគមន៍
- របាយការណ៍សវនកម្ម
- ប្រព័ន្ធតាមដានការសិក្សារបស់សិស្ស

- បរិយាបន្ន
  - ➢ ចំនួនសិស្សទទួលបានការអប់រំបរិយាបន្ន
- សមធម៌
  - ➢ ចំនួនសិស្សទទួលបានអាហារូបករណ៍សិស្សពូកែ អាហារូបករណ៍សិស្សក្រីក្រ សិស្សស្រី និងសិស្សជនជាតិភាគតិច
- ការអប់រំពេញមួយជីវិត
  - ➢ ចំនួនម៉ោងនិងចំនួនបុគ្គលិកអប់រំ ដែលទទួលបានការអប់រំពេញមួយជីវិត
- ការស្រាវជ្រាវ
  - ➢ ចំនួនប្រធានបទ ដែលគ្រូបានស្រាវជ្រាវ និងបោះពុម្ព
  - ➢ ចំនួនប្រធានបទ ដែលសិស្សបានស្រាវជ្រាវ និងបោះពុម្ព
- ការទាក់ទាញសហគមន៍
  - ➢ ចំនួនឬភាគរយប្រជាជនបានចូលរួមក្នុងសកម្មភាពសាលារៀន
  - ➢ ភាគរយមាតាបិតាសិស្សដែលបានចូលរួមក្នុងសកម្មភាពសាលារៀន
  - ➢ ភាគរយមាតាបិតាសិស្សដែលបានផ្តល់ព័ត៌មានត្រលប់មកសាលារៀន

## ២.១១.៤.ធនធានសាលាមធ្យមសិក្សាធនធាន

- ធនធានមនុស្ស
  - ➢ គណៈគ្រប់គ្រង (មាននាយក នាយករងគ្រប់និយាម) អនុលោមទៅតាមការពិពណ៌នាមុខតំណែង ការគ្រប់គ្រងប្រព័ន្ធគុណផល និងស្តង់ដានាយកសាលារៀន

- ភារកិច្ចសំខាន់ៗ

  - ➢ រៀបចំផែកការអភិវឌ្ឍសាលា ផែនការប្រតិបត្តិ
  - ➢ រៀបចំផែនការធនធានមនុស្ស
  - ➢ ស្វែងរកនិងចាត់ចែងប្រើប្រាស់មូលនិធិ និងប្រាក់ចំណូល
  - ➢ គ្រប់គ្រងនិងប្រើប្រាស់ធនធានរបស់សាលារៀនប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធ
  - ➢ អភិវឌ្ឍសមត្ថភាពបុគ្គលិកឱ្យមានជំនាញឯកទេសច្បាស់លាស់
  - ➢ ទំនាក់ទំនងសហគមន៍
  - ➢ ដឹកនាំការប្រជុំ។

- បរិច្ឆការីបន្ទប់ពិសោធន៍ ( សរុប ៦ នាក់)

  - ➢ បរិច្ឆការីពិសោធន៍ ៤ នាក់ ក្នុងនោះមានបន្ទប់ពិសោធន៍រូបវិទ្យា ១ នាក់ គីមីវិទ្យា ១ នាក់ ជីវវិទ្យា ១ នាក់ ផែនដីវិទ្យា ១ នាក់ និងបុគ្គលិកក្នុងបន្ទប់កុំព្យូទ័រ ២ នាក់ ក្នុង១ បន្ទប់ ដែលមានម៉ោងការងារ ១៨ ម៉ោង ក្នុង១សប្តាហ៍។

ភារកិច្ច ៖

- ➢ គ្រប់គ្រងឧបករណ៍ពិសោធន៍ សម្ភារៈបរិក្ខារ និងសារធាតុគីមី ដែលមាននៅក្នុងបន្ទប់ពិសោធន៍
- ➢ ធ្វើជំនួយការគ្រូមុខវិជ្ជាឯកទេស ក្នុងដំណើរការធ្វើសកម្មភាពពិសោធន៍
- ➢ ស្រាវជ្រាវនិងផ្សាយរបកគំហើញថ្មីៗ

មន្ត្រីជាប់កិច្ចសន្យា ៖

- បណ្ណារក្ស ផ្ទាំសាលា អនាម័យ បំណិនជីវិត គ្រូកុំព្យូទ័រ អន្តេវាសិដ្ឋាន និងអាហារដ្ឋាន សុខភាព។

បុគ្គលិកទទួលបន្ទុកគ្រប់គ្រងកុំព្យូទ័រ

- គ្រប់គ្រងសម្ភារបរិក្ខារ និងឧបករណ៍អេឡិចត្រូនិច ដែលមាននៅក្នុងបន្ទប់កុំព្យូទ័រ
- សហការជាប្រចាំជាមួយគ្រូមុខវិជ្ជាឯកទេស ពេលដំណើរការបង្រៀន និងរៀន
- ដំណើរការបន្ទប់កុំព្យូទ័រ សម្រាប់ការបង្រៀនព័ត៌មានវិទ្យា និងស្រាវជ្រាវ
- លើកគម្រោងតម្រូវការសម្ភារៈចាំបាច់ដូចជា ទឹកខ្មៅ ម៉ាស៊ីនបោះពុម្ព ទឹកខ្មៅម៉ាស៊ីនថតចម្លង និងគ្រឿងបន្លាស់តូចតាច....
- ជួសជុសឬស្វែងរកសេវាជួសជុលកុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិចតាមសមត្ថភាពដែលអាចធ្វើបាន
- ស្រាវនិងផ្សព្វផ្សាយរបកគំហើញថ្មីៗ។
- ចូលរួមប្រជុំជាមួយក្រុមបច្ចេកទេសវិទ្យាសាស្ត្រតាមឯកទេសរបស់ខ្លួន។

លើកគម្រោងតម្រូវការសម្ភារៈចាំបាច់ដូចជា ទឹកខ្មៅ ម៉ាស៊ីនបោះពុម្ព ទឹកខ្មៅម៉ាស៊ីនថតចម្លង និងគ្រឿងបន្លាស់តូចតាច....

- ជួសជុសឬស្វែងរកសេវាជួសជុលកុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិចតាមសមត្ថភាពដែលអាចធ្វើបាន
- ផ្សព្វផ្សាយរបកគំហើញថ្មីៗ។
- ចូលរួមប្រជុំជាមួយក្រុមបច្ចេកទេសវិទ្យាសាស្ត្រតាមឯកទេសរបស់ខ្លួន។

គ្រូបង្រៀន ៖

- គ្រូឯកទេសគ្រប់មុខវិជ្ជា អនុលោមតាមសេចក្តណែនាំលេខ ២៥៦ និងសេចក្តីណែនាំលេខ ៣៣ ស្តីពីនិយាមប្រើប្រាស់បុគ្គលិលអប់រំ
- អនុលោមតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងក្រមសីលធម៌គ្រូបង្រៀន

មន្ត្រីទទួលបន្ទុករដ្ឋបាល គណនេយ្យ

- ទទួលការបណ្តុះបណ្តាលអំពី កិច្ចការរដ្ឋបាលគណនេយ្យ...។ល។

ធនធានសម្ភារៈ

ហេដ្ឋារចនាសម្ព័ន្ធរបស់សាលាបធ្យមសិក្សាធនធាន (ស្តង់ដាទី១) នឹងត្រូវអភិវឌ្ឍដោយមានកំណត់នៅក្នុងផែនការអភិវឌ្ឍសាលារៀនតាមលទ្ធភាព។

អទិភាពនៃការប្រើប្រាស់

- ជំរុញការបង្រៀន និងរៀនមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យាវិស្វកម្ម និងគណិតវិទ្យា
- ជំរុញការស្រាវជ្រាវនិងការបង្កើតថ្មី មុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- ចែករំលែកធនធាន ដល់សាលាមធ្យមសិក្សាបណ្តាញ
- ជាទីកន្លែងសម្រាប់លើកកម្ពស់ការសិក្សាពេញមួយជីវិត របស់សហគមន៍
- ការណែនាំឱ្យស្គាល់តួនាទីរបស់សាលាមធ្យមសិក្សាធនធាន
- បំប៉នគណៈគ្រប់គ្រងនិងគ្រូ ក្នុងសាលាមធ្យមសិក្សាបណ្តាញទាំងមូល

ការស្រាវជ្រាវ

- ផ្តល់ឱកាសដល់បុគ្គលិកអប់រំអភិវឌ្ឍសមត្ថភាព និងស្រាវជ្រាវគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់ ជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ

- លើកទឹកចិត្តក្នុងការចូលរួមក្នុងការស្រាវជ្រាវ តាមរយៈការលើកសរសើរ ការទទួលស្គាល់ស្នាដៃ និងការផ្តល់រង្វាន់

ការបង្កើតថ្មី

- រៀបចំកម្មវិធីនិងបញ្ចូលវិធីសាស្ត្របង្រៀនបែបបង្កើតគម្រោងដល់គ្រូនិងសិស្ស
- រៀបចំឱ្យសិស្សសាលល្បងផលិតសម្ភារៈមួយចំនួន តាមគំនិតពួកគេ
- រៀបចំពិព័ណ៌វិទ្យាសាស្ត្រក្នុងសាលារៀន

ការទាក់ទាញសហគមន៍

- ប្រើប្រាស់ធនធានចំណេះដឹងក្នុងសហគមន៍ ក្នុងការបង្រៀន និងរៀនមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន
- ទទួលយកការផ្តល់ព័ត៌មានត្រលប់ពីសហគមន៍ទាក់ទងនិងលទ្ធផលសិក្សារបស់សិស្ស
- ទទួលយកការផ្តល់ព័ត៌មានត្រឡប់ពីសហគមន៍ទាក់ទងនិងការគ្រប់គ្រងថវិកា

កម្មវិធីផ្សេងទៀតដែលអាចប្រើប្រាស់អគាធនធាន

- សិក្ខាសាលាអំពីការគ្រប់គ្រងនិងដឹកនាំ ដល់សាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញ
- កម្មវិធីបណ្តុះបណ្តាលអ្នកជំនាញ និងគ្រូឯកទេស
- ការបំប៉នអំពីការប្រើប្រាស់និងកសាងសម្ភារឧបទេសបង្រៀន
- ការប្រជុំផ្សព្វផ្សាយអំពីបេកគហើញថ្មីៗ
- ការបង្ហាញស្នាដៃរបស់គ្រូ សិស្ស និងសហគមន៍
- កម្មវិធីកីឡា និងកម្មវិធីសង្គមផ្សេងៗទៀត

- ផ្តល់ឱកាសដល់បុគ្គលិកអប់រំអភិវឌ្ឍសមត្ថភាព និងស្រាវជ្រាវគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់ ជាពិសេសមុខវិជ្ជាវិទ្យាសាស្ត្រ
- លើទឹកចិត្តក្នុងការចូលរួមក្នុងការស្រាវជ្រាវ តាមរយៈការលើកសរសើរការទទួលស្គាល់ស្នាដៃ និងការផ្តល់ជារង្វាន់

ធនធនថវិកា

សាលាមធ្យមសិក្សធនជាន មានលទ្ធភាពទូលំទូលាយក្នុងការស្វែងរកធនធានពីគ្រប់ប្រភពក្នុងនោះ៖

- ថវិការដ្ឋាភិបាល ៖ ផ្តល់កញ្ចប់ថវិកាសម្រាប់ដំណើរការសាលា រួមបញ្ចូលថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការអគាធនធាន។ ដោយឡែកបៀវត្សរបស់បុគ្គលិកអប់រំ ជាបន្ទុករបស់រាជរដ្ឋាភិបាល
- ដៃគូអភិវឌ្ឍ ៖ សាលារៀនមានលទ្ធភាពទទួលការគាំទ្រថវិកាកែលម្អសាលារៀន ឬថវិកាផ្សេងទៀតពីគម្រោងអភិវឌ្ឍនានា
- មធ្យោបាយ ប្រភព និងជម្រើសក្នុងការស្វែងរកថវិកា ៖ ចំណូលរបស់សាលារៀនជាសកម្មភាពរកចំណូលដើម្បីជានានិរន្តភាព និងមិនមែនដើម្បីរកប្រាក់ចំណេញ (ស្របតាមច្បាប់ ស្តីពីការអប់រំ)

### ២.១១.៥. បរិស្ថាន

បរិស្ថានខាងក្រៅសាលារៀន ៖គ្រប់សាលាមធ្យមសិក្សាធនជាន គប្បីត្រូវរៀបចំតាមបទដ្ឋានបច្ចេកទេសនិងត្រូវជានាឱ្យមានសោភ័ណ្ឌភាព និងបរិយាកាសល្អ។

ផ្លូវ

- មានផ្លូវថ្នល់ ឬផ្លូវលំធំទូលាយមិនលិចទឹកអាចបើករថយន្តបាន
- បង្កភាពងាយស្រួលឱ្យសិស្សានុសិស្សធ្វើដំណើរទៅមកដោយសុខសុវត្ថិភាព។

បរិយាកាសខាងក្រៅ

- បង្កភាពងាយស្រួលក្នុងការសិក្សារបស់សិស្សានុសិស្ស
- មិនមានសម្លេង ឬការរំខាននានាពីខាងក្រៅ
- គ្មានទឹកស្អុយ និងក្លិនមិនល្អដែលនាំឱ្យប៉ះពាល់ដល់សុខភាព។

របង

- មានភាពសមរម្យរឹងមាំ ដែលអាចធានាបានសោភ័ណ្ឌភាព និងសុខសុវត្ថិភាព
- មានក្លោងទ្វារ និងទ្វារចូលសាលាធំទូលាយ មានស្លាកឈ្មោះគ្រឹះស្ថាន។

បរិស្ថានខាងក្នុងសាលា

ផ្លូវ

- មានផ្លូវចូលទៅកាន់ទីចាត់ការធំទូលាយ និងស្អាត
- ក្នុងបរិវេណសាលាមានផ្លូវស្អាតខ្វាត់ខ្វែងទៅកាន់អគារនានា មិនលិចទឹក និងមានសោភណ្ឌភាព
- មានដាំផ្កាលម្អនៅតាមចិញ្ចើមផ្លូវ

ទីធ្លា

- ធំទូលាយមានអនាម័យ គ្មានសំរាម និងមានសោភ័ណ្ឌភាព
- មានដើមឈើកៅអីថ្មសម្រាប់សិស្សានុសិស្សអង្គុយលេងពេលសម្រាក
- មានធុងសម្រាមតាមទីកន្លែងសមស្រប។

ទីលានគោរពទង់ជាតិ

- មានរៀបចំកំពែងសួនច្បារស្រស់បំព្រងព័ទ្ធជុំវិញដងទង់ជាតិ។

សួនលម្អ

- មានសួនច្បារស្រស់បំព្រង និងមានរបៀបរៀបរយ
- មានសួនកសិកម្មសម្រាប់សិស្សក្នុងការធ្វើការពិសោធន៍ក្នុងការដាំដំណាំ និងបំណិនជីវិតតមមូលដ្ឋាន
- មានសួនជីវៈចម្រុះសម្រាប់សិស្សធ្វើការសិក្សាផ្នែកបរិស្ថាន និងជីវវិទ្យា
- មានរោងក្បុសសម្រាប់អង្គុយលំហែកាយពេលសម្រាក។

អនាម័យ និងរបៀបរៀបរយ

- គ្មានសម្រាម ឬថ្លុកទឹកស្អុយក្នុងបរិវេណសាលារៀន
- មានរៀបចំដាក់ធុងសម្រាមតាមទីតាំងសមស្របក្នុងទីធ្លា
- មានរៀបចំប្រព័ន្ធលូត្រឹមត្រូវ
- មានរៀបចំចំណតរថយន្ត ម៉ូតូ កង់ត្រឹមត្រូវ

បរិស្ថានថ្នាក់រៀន ៖ គ្រប់សាលាមធ្យមសិក្សាជនជាន គប្បីត្រូវរៀបចំតាមបទដ្ឋានបច្ចេកទេសនិងត្រូវជានាឱ្យមានសោភ័ណ្ឌភាព និងបរិយាកាសល្អ។

នៅខាងមុខបន្ទប់រៀន

- ស្អាតជានិច្ច គ្មានសម្រាម គ្មានភក់ជ្រាំ
- មានដាំផ្កាលម្អ
- មានធុងសម្រាម។

នៅខាងក្នុងបន្ទប់រៀន

- មានបរិស្ថានល្អ ស្អាតជានិច្ច មានចន្លោះសមរម្យ មានខ្យល់អាកាសល្អ
- មានដាក់តាំបាវចនា រូបព្រះឆាយាល័ក្ខព្រះមហាក្សត្រ និងថ្នាក់ដឹកនាំ

- តារាងរដ្ឋបាលថ្នាក់រៀនទាំង៩
- ពាក្យស្លោកអប់រំ រូបមន្ត រូបភាពផ្សេងៗដែលទាក់ទងនិងការសិក្សា
- ស្នាដៃ ឬលទ្ធផលសិក្សារបស់សិស្ស
- មានជ្រុងបណ្ណាល័យ និងជ្រុងអនាម័យត្រឹមត្រូវ

## ២.១១.៦. ការខារបណ្តុះបណ្តាល និងការសិក្សារបស់សិស្ស

១. កម្មវិធីសិក្សា(ថ្មី) ៖ កម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស ៖

- សមត្ថភាពភាសាខ្មែរនិងភាសាបរទេសលើបំណិនទាំងបួន (ការស្តាប់ ការនិយាយ ការអាន និងការសរសេរ) ឱ្យបានច្បាស់លាស់
- ចំណេះដឹងគណិតវិទ្យា វិទ្យាសាស្ត្របច្ចេកទេសនិងបច្ចេកទេសព័ត៌មាន និងទូរគមនាគមន៍សម្រាប់ជាមូលដ្ឋានដល់ការបន្តការសិក្សា
- មណិនសិល្បះ សុខភាព កីឡា សោភ័ណ្ឌភាព នវានុវត្តន៍ សហគ្រិនភាព និងពលរដ្ឋវិជ្ជាសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ
- មណិនស្វ័យសិក្សា ស្រាវជ្រាវត្រិះរិះពិចារណា ប្រាស្រ័យទាក់ទង និងដោះស្រាយបញ្ហា
- សមត្ថភាក្នុងការវាយតម្លៃនិងធ្វើសេចក្តីសម្រេចិត្ត ដោយសុភវិនិច្ឆ័យនិងការទទួលខុសត្រូវប្រកបដោយសេចក្តីថ្លៃថ្នូរ
- ការយល់ដឹងក្នុងការបំពេញកាតព្វកិច្ចនិងការប្រើប្រាស់សិទ្ធិពលរដ្ឋ ដោយមានការទទួលខុសត្រូវ
- បំណិនសិក្សាពេញមួយជីវិតជួយលើកកម្ពស់គុណតម្លៃជាមូលដ្ឋាន និងបង្កើនចំណេះដឹង
- ស្មារតីស្រឡាញ់ ការពារ និងកសាងជាតិ មាតុភូមិ  និងពូជសាន៍។

មធ្យមសិក្សាបឋមភូមិ

ក. សមត្ថភាពរំពឹងទុក ៖ ក្រោយពេលបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ សិស្សនឹងទទួលបាន៖

វិជ្ជាសម្បទា

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកអក្សរសាស្ត្រខ្មែរ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាព កាយសម្បទា និងសីលធម៌
- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែទ្យាសាស្ត្រ បច្ចេកវិជ្ជាគមនាគមន៍ និតព័ត៌មាន និងភាសាបរទេស។

បំណិនសម្បទា

- មានបំណិនមូលដ្ឋានរឹងមាំ ច្បាស់លាស់ (ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបំណិនអនុវត្តចំណេះដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាននិងទូរគមនាគមន៍មូលដ្ឋាន
- មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហារឹងមាំនិងទូលំទូលាយទាំងក្នុងការសិក្សា និងក្នុងសង្គម
- មានបំណិនប្រាស្រ័យទាក់ទងទូលំទូលាយ សម្រាប់ការសិក្សា និងការរស់នៅប្រចាំថ្ងៃ
- មានបំណិនបង្ការនិងថែទាំសុខភាពបឋម
- មានសមត្ថភាពស្គាល់ខុស ស្គាល់ត្រូវ

ចរិយាសម្បទា

- ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាទាំងក្នុងនិងក្រៅប្រព័ន្ធ
- ស្គាល់និងឱ្យតម្លៃសន្តានចិត្តមេត្តានិងករុណាចំពោះគ្រួសារ មិត្តភក្តិ និងអ្នកដ៏ទៃ

- ស្គាល់ ស្រឡាញ់ ថែរក្សានិងការពារវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសិល្បៈជាតិ តបន់ និងអន្តរជាតិ
- ស្រឡាញ់និងឱ្យតម្លៃបរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- ស្រឡាញភាពស្អាតបាត ទាំងខ្លួនប្រាណ សាលារៀន ផ្ទះសម្បែង និងទីសាធារណៈ
- មានទម្លាប់និងអនុវត្តន៍ការរស់នៅប្រកបដោយសុខភាពតាមរយៈការធ្វើពលកម្ម និង ហាត់កីឡា
- ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនឯង និងរបស់ក្រុមទាំងក្នុងការសិក្សា និងការរស់នៅ ប្រចាំថ្ងៃ។

  - មុខវិជ្ជា ៖ ភាសាខ្មែរ (សរសេរតាមអាន តែងសេចក្តី វេយ្យាករណ៍ មេសូត្រ សិក្សាអត្ថបទ) គណិតវិទ្យា វិទ្យាសាស្ត្រ (រូបវិទ្យា ផែនដីបរិស្ថានវិទ្យា គីមីវិទ្យា ជីវវិទ្យា) សិក្សាសង្គម (ប្រវត្តិវិទ្យា ភាសាបរទេស សីលធម៌ពលរដ្ឋវិទ្យា គេហសេដ្ឋកិច្ចវិទ្យា) បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន
  - ម៉ោងសិក្សា ៖

១.តារាងរបាយមុខវិជ្ជានិងម៉ោងសិក្សាពីថ្នាក់ទី៧ដល់ថ្នាក់ទី៩

| ល.រ | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ៧ | ៨ | ៩ |
| ១ | ភាសាខ្មែរ | ៧ | ៧ | ៧ |
| ២ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៣ | គណិតវិទ្យា | ៧ | ៧ | ៧ |
| ៤ | វិទ្យាសាស្ត្រ | ៦ | ៦ | ៦ |

| | | | | |
|---|---|---|---|---|
| ៥ | សិក្សាសង្គម | ៧ | ៧ | ៧ |
| ៦ | បច្ចេវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) | ២ | ២ | ២ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៨ | អប់រំសិល្បះ | ១ | ១ | ១ |
| ៩ | អប់រំសុខភាព | ១ | ១ | ១ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៤០ | ៤០ | ៤០ |

សម្គាល់ ៖

- ៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និង១ម៉ោងសិក្សាមានរយះពេល ៥០នាទី។
- ជីវភាសាទី១ ៤ ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសទី២

មធ្យមសិក្សាទុតិយភូមិ

សមត្ថភាពរំពឹងទុកះ ក្រោយពេលការបញ្ចប់ការសិក្សានៅមសិក្សាទុតិភូមិសិស្សនឹងទទួលបាន ៖

- វិជ្ជាសម្បទា

- មានចំណេះដឹងមូលដ្ឋានគ្រឹះរឹងមាំផ្នែកអក្សរសាស្ត្រខ្មែរ វិទ្យាសាស្ត្រសង្គម គណិតវិទ្យា និងអភិវឌ្ឍសុខភាព កាយសម្បទា និងសីលធម៌
- មានចំណេះដឹងរឹងមាំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាគមនាគន៍  និងព័ត៌មាន និងភាសាបរទេស។

- បំណិសម្បទា

- មានបំណិនមូលដ្ឋានរឹងមាំ ច្បាស់លាស់ និងទទូលំទូលាយផ្នែកអក្សរសាស្ត្រខ្មែរ (ប្រៀបធៀប ពន្យល់ វិភាគ បកស្រាយ និងដោះស្រាយបញ្ហា)
- បំណិនមូលដ្ឋានរឹងមាំនិងច្បាស់លាស់ផ្នែកគណិតវិទ្យា( គណនា ប្រៀបធៀប ពន្យល់ រិះគន់ បកស្រាយ និងដោះស្រាយបញ្ហា)
- មានបណិនចំណេះដឹងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាព័ត៌មាននិងទរគមនាគមន៍មូលដ្ឋាន

➢ មានបំណិនត្រិះរិះពិចារណា និងដោះស្រាយបញ្ហារឹងមាំនិងទូលំទូលាយក្នុងការសិក្សា និងក្នុងសង្គម
➢ មានបំណិនប្រាស្រ័យទំនាក់ទំនងទូលំទូលាយនិងមានប្រសិទ្ធភាពក្នុងការសិក្សា និងក្នុងសង្គម
➢ មានសមត្ថភាព និងសីលធម៌ក្នុងការការពារ និងពង្រីកភាពត្រឹមត្រូវ។
- ចរិយាសម្បទា
➢ ស្រឡាញ់និងផ្តល់តម្លៃដល់ការសិក្សាពេញមួយជីវិត
➢ ស្គាល់និងឱ្យតម្លៃខ្ពស់ដល់បរិស្ថាន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
➢ ស្រឡាញ់ភាពស្អាតបាត ទាំងខ្លួនប្រាណសាលារៀន ផ្ទះសម្បែង និងទីធ្លាសាធារណៈ
➢ មានទម្លាប់និងអនុវត្តន៍ការរស់នៅប្រកយដោយសុខភាពតាមរយៈការធ្វើពលកម្មនិងហាត់កីឡា
➢ ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន និងរបស់ក្រុម ទាំងក្នុងការសិក្សា និងការរស់នៅប្រចាំថ្ងៃ។
- មុខវិជ្ជា ៖ អក្សរសាស្ត្រខ្មែរ គណិតវិទ្យា ភាសាបរទេស អប់រំកាយនិងកីឡា វិទ្យាសាស្ត្រ (រូបវិទ្យា ផែនដីបរិស្ថាវិទ្យា គីមីវិទ្យា ជីវវិទ្យា) សិក្សាសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) បច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មាន និងអប់រំសុខភាព។
- ម៉ោងសិក្សា ៖

២. តារាងបាយមុខវជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រ

| ល.រ | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | អក្សរសាស្ត្រខ្មែរ | ៥ | ៥ | ៥ |
| ២ | គណិតវិទ្យា | ៦ | ៦ | ៦ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |

| | | | | |
|---|---|---|---|---|
| ៦ | រូបវិទ្យា | ៤ | ៤ | ៤ |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ | ៣ |
| ៩ | ជីវវិទ្យា | ៣ | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | ២ | ២ | ២ |
| ១១ | ភូមិវិទ្យា | ២ | ២ | ២ |
| ១២ | សីលធម៌ពលរដ្ឋវិជ្ជា | ២ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | | | |

សម្គាល់ ៖

- ៦ថ្ងៃក្នុងមួយសប្តាហ៍ ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និងមួយម៉ោងសិក្សាមាន រយៈពេល ៥០នាទី។

- ជីវភាសាទី១ ៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

៣. តារាងរបាយមុខវិជ្ជានិងម៉ោងសិក្សាថ្នាក់ទី១០ ទី១១ និងទី១២ បណ្តុំវិទ្យាសាស្ត្រសង្គម

| ល.រ | មុខវិជ្ជា | ថ្នាក់ | | |
|---|---|---|---|---|
| | | ១០ | ១១ | ១២ |
| ១ | អក្សរសាស្ត្រខ្មែរ | ៥ | ៥ | ៥ |
| ២ | គណិតវិទ្យា | ៦ | ៦ | ៦ |
| ៣ | ភាសាបរទេស | ៦ | ៦ | ៦ |
| ៤ | អប់រំកាយនិងកីឡា | ២ | ២ | ២ |
| ៥ | គេហសេដ្ឋកិច្ចវិទ្យា | ១ | ១ | ១ |

| | | | | |
|---|---|---|---|---|
| ៦ | រូបវិទ្យា | ៤ | ៤ | ៤ |
| ៧ | ផែនដីបរិស្ថានវិទ្យា | ២ | ២ | ២ |
| ៨ | គីមីវិទ្យា | ៣ | ៣ | ៣ |
| ៩ | ជីវវិទ្យា | ៣ | ៣ | ៣ |
| ១០ | ប្រវត្តិវិទ្យា | ២ | ២ | ២ |
| ១១ | ភូមិវិទ្យា | ២ | ២ | ២ |
| ១២ | សីលធម៌ពលរដ្ឋវិជ្ជា | ២ | ២ | ២ |
| ១៣ | បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) | ១ | ១ | ១ |
| ១៤ | អប់រំសុខភាព | ១ | ១ | ១ |
| សរុបម៉ោងសិក្សាប្រចាំសប្ដាហ៍ | | | | |

សម្គាល់ ៖

- ៦ថ្ងៃក្នុងមួយសប្ដាហ៍ ពី៤ទៅ៧ម៉ោងសិក្សាក្នុងមួយថ្ងៃ និងមួយម៉ោងសិក្សាមានរយៈពេល ៥០នាទី។
- ជីវភាសាទី១ ៤ម៉ោងសិក្សា និង២ម៉ោងសិក្សាសម្រាប់ជីវភាសាទី២។

## ការបង្រៀន និងរៀន

### • បរិស្ថានថ្នាក់រៀន

- ទូលាយមានខ្យល់អាកាសចេញចូលល្អមិនស្អុះស្អាប់ ផ្តល់ផាសុកភាពដល់សិស្ស
- មានការលើកទឹកចិត្ត និងមានក្តីសង្ឃឹមដល់សិស្ស
- ផ្តល់ភាពស្និតស្នាលរវាងគ្រូ និងសិស្ស រវាងសិស្ស និងសិស្ស
- ផ្តល់លទ្ធភាពឲ្យសិស្សបញ្ចេញនូវសក្តានុពលសមត្ថភាពរបស់ខ្លួនក្នុងការសិក្សា
- មានភាពសកម្មតាមរយៈសកម្មភាពសិក្សារបស់សិស្ស

- មានលក្ខណៈប្រជាធិបតេយ្យផ្តល់សិទ្ធិសេរីភាពដល់សិស្ស ពិភាក្សា ផ្លាស់ប្តូរ យោបល់ ដោះស្រាយបញ្ហាការសិក្សា

**ការរៀបចំផែនការបង្រៀន**

- ធ្វើកាលវិភាគ និងផែនការបង្រៀនប្រចាំឆមាស ត្រីមាស ខែ សប្តាហ៍ច្បាស់លាស់
- កំណត់ខ្លឹមសារច្បាស់លាស់
- កំណត់មុខសញ្ញា និងវត្ថុបំណងមេរៀនច្បាស់លាស់
- កំណត់ទីកន្លែង និងសម្ភារបង្រៀនត្រឹមត្រូវ
- កំណត់វិធី និងយុទ្ធសាស្ត្របង្រៀនត្រឹមត្រូវ រៀបចំសកម្មភាពសិក្សា សមស្រប ខ្លឹម សារមេរៀន និងតម្រូវការសិស្សគ្រប់ប្រភេទ។

- **វិធីបង្រៀន**

  - អនុវត្តវិធីសកម្មប្លែកៗដូចជាវិធីបែបសហការ វិធីស្រាវជ្រាវ វិធីអន្តរកម្មមុខវិជ្ជាតាមគោលសិស្សមជ្ឈមណ្ឌល
  - បង្កលក្ខណៈនិងជួយសិស្សក្នុងការសិក្សា
  - ផ្សារភ្ជាប់ចំណេះដឹងបំណិន ទ្រឹស្តីនិងការអនុវត្ត និងបទពិសោធន៍ជាក់ស្តែងរបស់សិស្ស
  - មានទំនាក់ទំនងល្អរវាងគ្រូសិស្សតាមបែបផ្ទាល់ និងប្រយោល
  - ប្រើពហុល្បិចក្នុងការគិត និងប្លែកៗក្នុងការពង្រីកគំនិតរបស់សិស្ស

- **បទបង្ហាញ និងអន្តរកម្ម**

  - ការធ្វើបទបង្ហាញ ឬការសម្របសម្រួលត្រូវមានភាពច្បាស់លាស់
  - តាមប្រព័ន្ធ និងតាមលំដាប់នៃកម្រិតចំណេះដឹងរបស់សិស្ស

- ប្រើប្រាស់វិធីបង្ហាញផ្ទាល់ ឬមិនផ្ទាល់ទៅតាមកាលៈទេសៈនៃស្ថានភាពពិតប្រាកដរបស់សិស្ស
- ប្រើប្រាស់សំណួរតាមកម្រិតនីមួយៗបានត្រឹមត្រូវ ដើម្បីពង្រីកការគិតរបស់សិស្ស
- ប្រើប្រាស់សម្ភារឧបទេសជាជំនួយក្នុងការបកស្រាយបង្ហាញខ្លឹមសារមេរៀន ឬជំនួយក្នុងការគិត
- ប្រើប្រាស់យុទ្ធសាស្ត្រអន្តរកម្មប្លែកៗឲ្យមានប្រសិទ្ធភាព
- បង្កលក្ខណៈនិងផ្តល់សេរីភាពឲ្យសិស្សធ្វើសកម្មភាពជាបុគ្គល ដៃគូ ឬក្រុម
- មានភាពឈ្លាសស្គាល់សិស្សច្បាស់លាស់ ចេះដោះស្រាយការលំបាកក្នុងការសិក្សារបស់សិស្ស
- មានការច្នៃប្រឌិតក្នុងការប្រើវិធីអន្តរាគមន៍សមស្របនឹងបរិយាកាស សិក្សារបស់សិស្ស
- ប្រើប្រាស់ល្បឿននៃការបង្រៀន ឬធ្វើបទបង្ហាញសមស្រប ជាក់ស្តែងតាមខ្លឹមសារនៃមេរៀន
- ប្រើវិបធ្វឹកសិស្សម្នាក់ឲ្យមានបំណិស្នាត់ជំនាញ
- អនុវត្តតួនាទីជាអ្នកដឹកនាំ និងជាអ្នកសម្របសម្រួលប្រកបដោយភាពឈ្លាសវៃ និងសុភវិនិច្ឆ័យ។

- **ការគ្រប់គ្រងថ្នាក់រៀន**

- រៀបចំតុបតែងថ្នាក់រៀនឲ្យបានសមស្រប និងបរិយាកាសសិក្សា
- ត្រួតពិនិត្យ និងកត់ត្រាវត្តមានសិស្សឲ្យបានទៀងទាត់
- រៀបចំអង្គុយឲ្យបានសមស្របតាមស្ថានភាពពិតប្រាកដរបស់សិស្ស
- គ្រប់គ្រងពេលវេលាសិក្សា រយៈពេលបង្រៀន និងពេលសម្រាករបស់សិស្សឲ្យបានត្រឹមត្រូវ

- ត្រួតពិនិត្យសកម្មភាពសិក្សារបស់សិស្សឲ្យបានល្អក្នុងពេលកំពុងបង្រៀន
- ទប់ស្កាត់ឥរិយាបថរាយមាយក្នុងការសិក្សារបស់សិស្សឲ្យបានទាន់ពេល។

- **ការសិក្សា**

**ក. សិស្សានុសិស្សត្រូវគោរពវិន័យដូចជា៖**

- បទបញ្ជាផ្ទៃក្នុង និងវិន័យសាលារៀនឲ្យបានត្រឹមត្រូវ
- មកសិក្សាឲ្យបានទៀងទាត់ និងទាន់ពេលវេលា
- ថែរក្សាទ្រព្យសម្បត្តិរបស់សាលារៀន និងរបស់សាធារណៈ
- មានសីលធម៌ និងសាមគ្គីភាពគ្នាល្អ

**ខ. សិស្សានុសិស្សបំពេញការសិក្សាឲ្យបានល្អដូចជា៖**

- សិក្សាឲ្យបានជោគជ័យទាំងផ្នែកទ្រឹស្តី និងការប្រតិបត្តិ
- ចូលរួមគ្រប់សកម្មភាពសិក្សផ្សេងៗ រួមមានសកម្មភាពក្នុងថ្នាក់ ក្រៅថ្នាក់ ការសិក្សាជាបុគ្គល ដៃគូ ឬជាក្រុម ស្វ័យសិក្សា។ល។
- រៀនប្រើនិងផលិតសម្ភារឧបទេសងាយៗ និងគំនិងច្នៃប្រឌិត
- ធ្វើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ
- បើកចិត្តក្នុងការចែករំលែកការចេះដឹងជាមួយមិត្តភក្តិ។

- **វាយតម្លៃការសិក្សា**

**ក. ក្នុងការសិក្សារបស់សិស្សទាំងអស់ត្រូវ៖**

- ទទួលការវាយតម្លៃផ្នែកសិក្សាទ្រឹស្តីតាមសប្តាហ៍ ខែ ត្រីមាស និងឆមាស
- ទទួលការវាយតម្លៃលើផ្នែកប្រព្រឹតពីគ្រូ មិត្តភក្តិ និងនាយក

ខ. សិស្សមានសិទ្ធិប្រឡងដំរាបណា៖

- មករៀនទៀងទាត់ មានពិន្ទុប្រចាំឆមាស និងប្រចាំឆ្នាំ
- មានអវត្តមានមិនលើលពី ២៥ថ្ងៃក្នុងមួយឆ្នាំសិក្សា

គ. សិស្សមានសិទ្ធប្រឡងថ្នាក់ជាតិ ថ្នាក់ទី៩ និងថ្នាក់ទី១២ ដរាបណាជាប់មធ្យមភាគ។

កម្មវិធីប្រើប្រាស់ធអគារធនធាន

យោងតាមសេចក្តីណែនាំលេខ ៣៥ សាលាមធ្យមសិក្សាធនធានត្រូវបានរៀបចំកាលវិភាគ ដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ កុំព្យូទ័រ និងបណ្ណាល័យសម្រាប់សិស្ស សម្រាប់គ្រប់កម្រិត ថ្នាក់សម្រាប់វិទ្យាល័យធនធាន និងសាលាមធ្យមសិក្សាមណ្ឌាញ បានច្បាស់លាស់និងអនុវត្តឱ្យបានជាប្រចាំតាមកាលវិភាគនេះដោយមានបទកាលវិភាគក្នុងបន្ទប់ទាំងនោះ៖

- កត់ត្រាដើម្បីបញ្ជូនក្នុងរបាយការណ៍អំពីការប្រជុំ ការបណ្តុះបណ្តាល និងការណែនាំផ្សេងៗដែលបានរៀបចំធ្វើនៅក្នុងបន្ទប់ប្រជុំ បន្ទប់ពិសោធន៍ បន្ទប់កុំព្យូទ័រ នៃអគាធនធាន
- រៀបចំប្រជុំពិភាក្សាជាមួយនាយកមធ្យមសិក្សាបណ្តាញរៀងរាល់ឆ្នាំ មុនបើកបវេសនកាលដើម្បីរៀបចំកាលវិភាគដំណើរការបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ កុំព្យូទ័រ និងបណ្ណាល័យ និងបន្ទប់ប្រជុំសម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស នៃសាលាមធ្យមសិក្សាបណ្តាញក្នុងតបន់របស់ខ្លួន
- ផ្សព្វផ្សាយឯកសារមូលដ្ឋានគ្រឹះនៃព័ត៌មានវិទ្យាដល់លោកគ្រូ អ្នកគ្រូមុខវិជ្ជាដទៃ ឱ្យចេះប្រើប្រាស់កុំព្យូទ័រដើម្បីអភិវឌ្ឍមេរៀនជំនាញរបស់ខ្លួន
- ផ្សព្វផ្សាយឯកសារ ការគ្រប់គ្រង និងដឹកនាំក្រុមបច្ចេកទេស ដល់ប្រធានក្រុមបច្ចេកទេសនៃសាលាមធ្យមសិក្សាមណ្ឌាញ

- រៀបចំធ្វើថ្នាក់និទស្សន៍មុខវិជ្ជាផ្សេងៗ ដោយអញ្ជើញប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូសាលាមធ្យមសិក្សាបណ្តាញឱ្យចូលរួមចែករំលែកបទពិសោធន៍។

## ការទទួលស្គាល់ការស្រាវជ្រាវ ពិសោធន៍ និងស្នាដៃ

- ការស្រាវជ្រាវ

  - មានការចូលរួមវគ្គបំប៉ននានាក្រោមការរៀបចំ របស់ក្រសួងអប់រំ យុវជន និងកីឡា ឬមន្ទីរ ឬសាលាសាមី
  - មានខ្ទង់ថវិកាដើម្បីរៀបចំបំប៉នគ្រូមុខវិជ្ជាដូចគ្នា នៅពេលប្រធានក្រុមបច្ចេកទេស ឬអនុប្រធានក្រុមបច្ចេកទេស ឬគ្រូដ៏ទៃទៀតបានទៅការទទួលការបណ្តុះបណ្តាល
  - លើកទឹកចិត្តគ្រូសិស្សឱ្យប្រើប្រាស់វិធីសាស្ត្របង្រៀន រៀនមានប្រសិទ្ធភាព និងចែករំលែកបទពិសោធន៍ក្នុងសាលានិង ក្រៅសាលា។

- ការបង្កើថ្មី

  - រៀបចំប្រធានបទឱ្យគ្រូ និងសិស្សក្នុងការជំរុញដល់បង្កើតថ្មីដូចជា ការសរសេរកំណាព្យ ការតាក់តែងនិពន្ធរឿងខ្លី ការសរសេរករណីសិក្សា ការលើកយកគំហើញវិទ្យាសាស្ត្រថ្មីមកបរិយាយការពិសោធន៍វិទ្យាសាស្ត្រ។ល។
  - រៀបចំប្រធានបទបែបជជែកដេញដោលពីបញ្ហាអ្វីមួយដោយឱ្យគ្រូសិស្សគិតពីគុណសម្បត្តិ និងគុណវិបត្តិនៃបញ្ហានោះ។
  - ការកៀរគធនធាន តាមវិធានបើកទូលាយឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ
  - ប្រើប្រាស់ធនធានក្នុងសហគមន៍ តាមរយៈការអញ្ជើញគាត់មកធ្វើបទបង្ហាញសម្រាប់មុខវិជ្ជាពាក់ព័ន្ធ (មុខវិជ្ជាប្រវត្តិវិទ្យា មុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន មុខវិជ្ជាភូមិវិទ្យា។ល។

- ➢ បង្កើតការចុះសម្ភាសន៍សួរនាំប្រជាជនក្នុងសហគមន៍ពីជាតុពិតជាក់ស្តែង នៃអ្វីមួយ ព្រឹត្តិការណ៍អ្វីមួយ ភាពជោគជ័យរបស់ជនណាម្នាក់
- ➢ ការផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាបន្ន សមធម៌ និងឱកាសអប់រំពេញមួយជីវិត
- ➢ ភាពមិនច្រំដែលនៃកិច្ចតែងការបង្រៀន ឬកិច្ចតែងការបង្រៀនដដែល តែមានការសរសេរនូវបទពិសោធន៍តាមឆ្នាំសិក្សារបស់សិស្ស
- ➢ ប្រធានបទនៃការប្រជុំក្រុមបច្ចេកទេសមានសភាពបទបែន តាមសភាពការណ៍ និងតម្រូវការជាក់ស្តែង
- ➢ ផ្សព្វផ្សាយពីការចូលរួមរៀនសូត្រ របស់គ្រូ សិស្សគ្រប់គ្នា

### ២.១១.៧.គណៈកម្មការនិងក្រុមប្រឹក្សានានា

១. គណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន

- ផ្នែកគ្រប់គ្រង
  - ➢ គណៈកម្មការវាយតម្លៃបុគ្គលិក
  - ➢ គណៈកម្មការគ្រប់គ្រងអន្តេវាសដ្ឋាន
  - ➢ គណៈកម្មការអប់រំ យុវជន និងយេនឌ័រ
  - ➢ គណៈគ្រប់គ្រងថវិកា
  - ➢ គណៈកម្មការគ្រប់គ្រងថវិកា
  - ➢ គណៈកម្មការគ្រប់គ្រងសហគមន៍
- ផ្នែកបច្ចេទេស
  - ➢ គណាកម្មការបច្ចេកទេស

➢ គណៈកម្មការការងារសិក្សារបស់សិស្ស

➢ គណៈកម្មការអប់រំ សិល្បៈ និងកីឡា

➢ គណៈកម្មការអប់រំ អនាម័យ និងបរិស្ថាន

២. ក្រុមប្រឹក្សានានា

•ផ្នែកគ្រប់គ្រង

➢ ក្រុមប្រឹក្សាវិន័យបុគ្គលិក

➢ ក្រុមប្រឹក្សាវិន័យសិក្សា

• ផ្នែកទំនាក់ទំនង និងសង្គម

➢ ក្រុមប្រឹក្សាប្រឡងប្រណាំង

➢ ក្រុមប្រឹក្សាទំនាក់ទំនង និងសណ្ដាប់ធ្នាប់សន្តិសុខ

➢ ក្រុមប្រឹក្សាទំនាក់ទំនងសហគមន៍

### ២.១១.៨. តារាងរចនាសម្ព័ន្ធរបស់សាលាធនធាន



រចនាសម្ព័ន្ធគ្រប់គ្រងសាលាមធ្យមសិក្សាធនជានបានរៀបចំបណ្តាញ ឬប្រព័ន្ធការងារ ក្នុងនោះរួមមានផ្នែកគ្រប់គ្រង និងផ្នែកជំនាញ ដែលជាកត្តាមួយសំខាន់សម្រាប់ជំរុញការងារបង្រៀននិងរៀនឱ្យមានប្រសិទ្ធភាពនិងគុណភាព។

## ១.ផ្នែកគ្រប់គ្រង

- នាយក/នាយិកា

➢ នាយក/នាយិកាមួយនាក់មានតួនាទីជាអ្នកដឹកនាំ និងគ្រប់គ្រងសាលារៀន

- នាយករង/នាយិការងមួយនាក់ទទួលបន្ទុកគ្រប់គ្រង ការិយាល័យរដ្ឋបាល បុគ្គលិកនិង

➢ នាយករង/នាយិការងមួយនាក់ទទួលបន្ទុកគ្រប់គ្រង ការិយាល័យរដ្ឋបាល បុគ្គលិកនិង គណនេយ្យ

➢ នាយករង/នាយិការងមួយនាក់ទទួលបន្ទុកក្រុមប្រឹក្សានានា

## ២.ផ្នែកជំនាញ

- រដ្ឋបាល គណនេយ្យ

➢ នាយករង/នាយិការងមួយនាក់ទទួលបន្ទុកគ្រប់គ្រង ការិយាល័យរដ្ឋបាល បុគ្គលិកនិង គណនេយ្យ

➢ ជំនាញគណនេយ្យ

➢ ជំនាញរដ្ឋបាល លេខាធិការ

- មុខវិជ្ជាឯកទេសនានា

➢ ប្រធានក្រុមបច្ចេកទេសអក្សរសាស្ត្រខ្មែរ

➢ ប្រធានក្រុមបច្ចេកទេសគណិតវិទ្យា

➢ ប្រធានក្រុមបច្ចេកទេសរូបវិទ្យា

➢ ប្រធានក្រុមបច្ចេកទេសគីមីវិទ្យា

➢ ប្រធានក្រុមបច្ចេកទេសជីវវិទ្យា

➢ ប្រធានក្រុមបច្ចេកទេសប្រវត្តិវិទ្យា

➢ ប្រធានក្រុមបច្ចេកទេសភូមិវិទ្យា

- ប្រធានក្រុមបច្ចេកទេសសីលធម៌ និងពលរដ្ឋវិជ្ជា
- ប្រធានក្រុមបច្ចេកទេសភាសាបរទេសទេស
- ប្រធានក្រុមបច្ចេកទេសព័ត៌មានវិទ្យា
- ប្រធានក្រុមបច្ចេកទេសបណិនជីវិត និងកីឡា

# ជំពូកទី៣

# វិធីសាស្ត្រនៃការស្រាវជ្រាវ

## ៣.១. ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

ការស្រាវជ្រាវនេះ ត្រូវបានរៀបចំធ្វើឡើងដោយប្រើទិន្នន័យបែបបរិមាណវិស័យ និងគុណវិស័យដែលបានយកមកវិភាគដើម្បីស្វែងយល់ពីដំណើរការអនុវត្តលើស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ តាមគ្រឹះស្ថានសិក្សាដែលជាគោលដៅនៃការស្រាវជ្រាវលើប្រធានបទនេះ។

## ៣.២. ទីកន្លែងសិក្សាស្រាវជ្រាវ

ជាការពិតណាស់នៅគ្រប់គ្រឹះស្ថានសិក្សាទាំងអស់មិនថា គ្រឹះស្ថានសិក្សាបឋមភូមិ ឬគ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិនោះទេសុទ្ធតែត្រូវការការគ្រប់គ្រងយ៉ាងសំខាន់ និងចាំបាច់ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យអប់រំឱ្យទទួលបានគុណភាព និងមានប្រសិទ្ធភាពខ្ពស់។ ហេតុដូចនេះហើយទាមទារឱ្យមានការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញឱ្យមានដំណើរការល្អ ប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងមានការគ្រប់គ្រង និងដឹកនាំមានលក្ខណៈជាប្រព័ន្ធឱ្យចំទិសដៅ គោលដៅ ផែនការ វត្ថុបំណង គោលបំណង សកម្មភាព តម្លាភាព និងស្របតាមស្ថានភាពក្នុងតបន់ក៏ដូចជាទូទាំប្រទេសផងដែរ។ ការសិក្សាស្រាវជ្រាវនេះបានជ្រើសយកទីតាំងនៅខេត្តតាកែវ។ នៅក្នុងខេត្តតាកែវមានសាលាមធ្យមសិក្សាធនធានទាំងអស់ចំនួន២ និងសាលាបណ្ដាញចំនួន១១ ក៏ប៉ុន្តែអ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាមធ្យមសិក្សាធនធានទាំង២និងសាលាបណ្ដាញចំនួន៦ ដែលមានទីតាំងស្ថិតនៅនៅខេត្តតាកែវដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ ដូចមាននៅខាងក្រោម៖

១. វិទ្យាល័យជាស៊ីម តាកែវ (សាលាមធ្យមសិក្សាធនធាន)

២. វិទ្យាល័យហុន សែន ឈើទាល (សាលាបណ្ដាញ)

៣. វិទ្យាល័យហ៊ុន សែន អង្គប្រិយ៍ (សាលាបណ្ដាញ)

៤. វិទ្យាល័យសុខ អានលាយបូរ (សាលាបណ្ដាញ)

៥. វិទ្យាល័យសម្ដេចឪ (សាលាមធ្យមសិក្សាធនធាន)

៦. វិទ្យាល័យសុខ អានសំរោង (សាលាបណ្ដាញ)

៧. វិទ្យាល័យហ៊ុន សែនស្លាគូរ (សាលាបណ្ដាញ)

៨. វិទ្យាល័យសុខ អានក្ដីទន្ទឹម (សាលាបណ្ដាញ)

## ៣.៣. ក្រុមគោលដៅ

ការសិក្សាស្រាវជ្រាវនេះផ្ដោតទៅលើគណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាបណ្ដាញដែលមាន នាយកឬនាយិកា និងនាយករងឬនាយិការងទទួលបន្ទុកការងារបច្ចេកទេស និងបរិវិច្ឆការីបន្ទប់ពិសោធន៍ និងគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិថ្នាក់វិទ្យាសាស្ត្រដែលកំពុងបង្រៀននៅលាសាមធ្យមសិក្សាធនធាន និងសាលាបណ្ដាញនៅក្នុងខេត្តតាកែវដែល( ចាប់ពីថ្នាក់ទី១០ ថ្នាក់ទី១១ ដល់ថ្នាក់ទី១២)។ចំពោះក្រុមគោលដៅគឺនាយកឬនាយិកា និងនាយករង/នាយិការងទទួលបន្ទុកការងារផ្នែកបច្ចេកទេសនិងបរិវិច្ឆការីចំនួនសរុប២៤នាក់ និងលោកគ្រូ អ្នកគ្រូ ដែលបង្រៀនវិទ្យាសាស្ត្រចាប់ពីថ្នាក់ទី១០ ថ្នាក់ទី១១ ដល់ថ្នាក់ទី១២មានចំនួន៦០នាក់។

**តារាង៣.៣.១ ៖ ក្រុមគោលដៅ និងអ្នកចូលរួម**

| ល.រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម |
|---|---|---|
| ០១ | គណៈគ្រប់គ្រងសាលា និងបរវិច្ឆការីបន្ទប់ពិសោធន៍ | ២៤ |
| ០២ | គ្រូបង្រៀន | ៦០នាក់ |

| សរុបរួម | ៨៤នាក់ |
|---|---|

## តារាង៣.៣.២ កម្រិតវប្បធម៌របស់គ្រូបង្រៀន

| កម្រិតវប្បធម៌គ្រូបង្រៀន | ចំនួន | ភាគរយ | ប្រុស | ភាគរយ | ស្រី | ភាគរយ |
|---|---|---|---|---|---|---|
| បរិញ្ញាបត្រជាន់ខ្ពស់ | ០ | ០% | ០ | ០% | ០ | ០% |
| បរិញ្ញាបត្រ | ៥៤ | ៩០% | ៤៧ | ៧៨% | ៧ | ១១% |
| មធ្យមសិក្សាទុតិយភូមិ | ៦ | ១០% | ២ | ៣% | ៤ | ៧% |
| សរុប | ៦០ | ១០០% | ៤៩ | ៨១% | ១១ | ១៩% |

## តារាង៣.៣.៣ បទពិសោធន៍ការងារ

| បទពិសោធន៍ការងារ | ចំនួន | ភាគរយ | ប្រុស | ភាគរយ | ស្រី | ភាគរយ |
|---|---|---|---|---|---|---|
| តិចជាង៥ឆ្នាំ | ៦ | ១០% | ២ | ៣% | ៤ | ៧% |
| ពី៥ដល់៩ឆ្នាំ | ១៤ | ២៣% | ១១ | ១៨% | ៣ | ៥% |
| លើសពី៩ឆ្នាំ | ៤០ | ៦៧% | ៣៥ | ៥៨% | ៥ | ៨% |
| សរុប | ៦០ | ១០០% | ៤៨ | ៨០% | ១២ | ២០% |

## ៣.៤ ទំហំសំណាក

ភាគសំណាកសម្រាប់សិក្សាស្រាវជ្រាវនេះរួមមាន៖ គណៈគ្រប់គ្រងសាលាដែលជាថ្នាក់ដឹកនាំនិងគ្រប់គ្រងសាលាមធ្យមសិក្សាធនជាន និងសាលាបណ្ដាញមានចំនួន២៤នាក់ និងគ្រូបង្រៀនកម្រិតមធ្យម

សិក្សាទុតិយភូមិថ្នាក់វិទ្យាសាស្ត្រចំនួន៦០នាក់។ ទីតាំងស្ថិតក្នុងខេត្តតាកែវ ដែលអ្នកសិក្សាស្រាវជ្រាវបាន ជ្រើសយកសាលាមធ្យមសិក្សាធនធនទាំង២ និងសាលាបណ្ដាញចំនួន៦ ក្នុងចំណោមសាលាបណ្ដាញ ទាំង១១នៅខេត្តតាកែវ។ ការជ្រើសរើសគណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូមកធ្វើភាគសំណាក។

ការស្រាវជ្រាវនេះត្រូវបានបែងចែកជាពីរដំណាក់កាលសំខាន់ៗ។ ដំណាក់កាលទី១គឺជាការពិនិត្យមើលឯកសារនានាដែលពាក់ព័ន្ធនិងមានស្រាប់។ នៅដំណាក់កាលទី១នេះ អ្នកស្រាវជ្រាវព្យាយាមសិក្សាស្វែងរកឯកសារផ្សេងៗដែលទាក់ទងនឹងប្រធានបទហើយយកវាមកសិក្សាបន្ថែម និងយកវាជាឯកសារយោងផងដែរ។ ដំណាក់កាលទី២គឺជាការចុះប្រមូលព័ត៌មានពីអ្នកពាក់ព័ន្ធដោយផ្ទាល់។ នៅក្នុងដំណាក់កាលនេះ កម្រងសំណួរត្រូវបានរៀបចំឡើងសម្រាប់ជាមូលដ្ឋាន ក្នុងការប្រមូលព័ត៌មាន។ ការយកកម្រងសំណួរទៅប្រមូលព័ត៌មានមានគោលបំណងស្វែងរកព័ត៌មានផ្សេងៗពីភាគីពាក់ព័ន្ធ គឺចង់បានព័ត៌មានពីពួកគាត់។

## ៣.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

មុននឹងឈានដល់ដំណាក់កាលប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានយកលិខិតឧទេសនាមដែលចេញដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ទៅសុំពិកាអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ ដើម្បីចុះប្រមូលទិន្នន័យទៅតាមសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្ដាញតាមគោលដៅ។ ពេលទៅដល់សាលារៀន អ្នកសិក្សាស្រាវជ្រាវ បានបង្ហាញលិខិតឧទេសនាមបេសកម្មចុះប្រមូលទិន្នន័យនោះជូនទៅនាយក/នាយិកាសាលា និងសុំការអនុញ្ញាតពីគាត់ដើម្បីធ្វើការប្រមូលទិន្ន័យ ដោយកោះអញ្ជើញគ្រូបង្រៀនទាំងអស់ដែលអ្នកស្រាវជ្រាវបានស្នើសុំជួបប្រជុំ ដើម្បីធ្វើការណែនាំក្នុងការបំពេញកម្រងសំណួរ ដោយគោរពតាមក្រមសីលធម៌អ្នកស្រាវជ្រាវ តាមការស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំឡើយ។ ក្នុងការបំពេញកម្រងសំណួរនេះ ប្រើប្រាស់ពេលវេលាប្រហែល៤០នាទី។

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្របែបចម្រុះបែបបរិមានណវិស័យ និងបែបគុណវិស័យ ប៉ុន្តែអ្នកស្រាវជ្រាវផ្ដោតទៅលើសំណួរបែបបរិមាណវីស័យច្រើនជាង ដើម្បីឆ្លើយតបទៅនឹង

សំណួរស្រាវជ្រាវដែលបានកំណត់រួចនៅក្នុងជំពូកទី១។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយប្រើកម្រង សំណួរដែលមានសំណួរបែបទម្រង់បិទ និងទម្រង់បើក ដើម្បីប្រមូលទិន្នន័យពីនាយក/នាយិកា នាយករង/នាយិការងបច្ចេកទេស និងបរិច្ឆេរីបន្ទប់ពិសោធន៍សាលាមធ្យមសិក្សាធនធាន និងនាយក/នាយករង នាយិកា/នាយិការងទទួលបន្ទុកបច្ចេកទេសសាលាមធ្យមសិក្សាបណ្តាញ និងគ្រូបង្រៀនថ្នាក់វិទ្យាសស្ត្រនៅកម្រិតថ្នាក់ទី១០,១១ និងទី១២។

អ្នកកស្រាវជ្រាវបានសម្រេចចិត្តជ្រើសរើសតាមបែបបរិមាណវិស័យ និងគុណវិស័យ ដោយប្រើប្រាស់កម្មវិធី Ms Word,Excel និងSPSS ក្នុងការគណនារកតម្លៃ MEAN (មធ្យម)។ ចំពោះប្រធានបទ "**ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ**" ។

## ៣.៦ ការជ្រើសរើសសំណាក

អ្នកស្រាវជ្រាវនេះបានកំណត់ជ្រើសរើសយកសាលាមធ្យមសិក្សាធនធានទាំង២ និងសាលាមធ្យមសិក្សាបណ្តាញចំនួន៦ ក្នុងចំណោមសាលាមធ្យមសិក្សាបណ្តាញទាំង១១ នៅខេត្តតាកែវ។

ដែលសំណាកត្រូវអ្នកស្រាវជ្រាវសរុប៨៤ នាក់ ក្នុងនោះរួមមាន៖ គណៈគ្រប់គ្រងសាលា និងបរិច្ចការីចំនួន ២៤នាក់ គ្រូបង្រៀនថ្នាក់វិទ្យាសាស្ត ( ថ្នាក់ទី១០ , ថ្នាក់ទី១១ , និងថ្នាក់ទី១២ )មានចំនួន៦០នាក់ ដូចបានរៀបរាប់នៅក្នុងតារាងខាងក្រោម។

តារាង៣.៦៖តារាងសាលាគោលដៅ

| ល.រ | ឈ្មោះវិទ្យាល័យ | ចំនួនគណៈគ្រប់គ្រងចូលរួម | ចំនួនគ្រូចូលរួម |
|---|---|---|---|
| ០១ | វិទ្យាល័យជា ស៊ីមតាកែវ (សាលាធនធាន) | ៦ | ៦ |
| ០២ | វិទ្យាល័យហ៊ុន សែនឈើទាល(សាលាបណ្តាញ) | ២ | ៦ |
| ០៣ | វិទ្យាល័យសុខ អានលាយបូរ(សាលាបណ្តាញ) | ២ | ៧ |

| | | | |
|---|---|---|---|
| ០៤ | វិទ្យាល័យហ៊ុន សែនអង្គប្រិយ៍(សាលាបណ្តាញ) | ២ | ៦ |
| ០៥ | វិទ្យាល័យសម្តេចឪ (សាលាធនធាន) | ៦ | ១២ |
| ០៦ | វិទ្យាល័យសុខ អានសំរោង(សាលាបណ្តាញ) | ២ | ៩ |
| ០៧ | វិទ្យាល័យហ៊ុន សែនស្លាគូរ(សាលាបណ្តាញ) | ២ | ៨ |
| ០៨ | វិទ្យាល័យសុខ អានក្តីទន្ទឹម(សាលាបណ្តាញ) | ២ | ៦ |
| សរុប | | ២៤ | ៦០ |

ដែលសំណាកគ្រូវអ្នកស្រាវជ្រាវសរុប៨៤ នាក់ ក្នុងនោះរួមមានៈ គណៈគ្រប់គ្រងសាលាចំនួន១៦ នាក់ និងបរវិច្ចការីបន្ទប់ពិសោធន៍ចំនួន ៨នាក់ គ្រូបង្រៀនថ្នាក់វិទ្យាសាស្ត ( ថ្នាក់ទី១០ , ថ្នាក់ទី១១ , និងថ្នាក់ទី១២ )មានចំនួន៦០នាក់ ដូចបានរៀបរាប់នៅក្នុងតារាងខាងលើ។

## ៣.៧ ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំនួន២ប្រភេទក្នុងការប្រមូលទិន្ន័យតាមបែបបរិមានវិស័យ និងបែបគុណវិស័យ។ ក្នុងកម្រងសំណួរទាំង២ប្រភេទនោះរួមមានៈប្រភេទទី១គឺកម្រងសំណួរសម្រាប់នាយក/នាយករង នាយិកា/នាយិការងបច្ចេកទេស និងបរវិច្ចការីបន្ទប់ពិសោធន៍ មាន៣ផ្នែកគឺទី១˝ព័ត៌មានទូទៅ˝តាមបែបគុណវិស័យ និងមរិមាណវិស័យ ផ្នែកទី២˝កម្រិតសមត្ថភាពរបស់លោក/លោកស្រីដែលជាថ្នាក់ដឹកនាំ និងគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញ ផ្តោតលើធនធានអប់រំ˝តាមបែបបរិមាណវិស័យ ។កម្រងសំណួរទី២ គឺកម្រងសំណួរសម្រាប់លោកគ្រូ/អ្នកគ្រូដែលកំពុងបង្រៀនមុខវិទ្យាវិទ្យាសាស្រ្ត និងពិសោធន៍ ដែលកំពុងបង្រៀនថ្នាក់ទី ១០ ដល់ថ្នាក់ទី១១ ខាងផ្នែកវិទ្យាសាស្រ្ត។កម្រងសំណួរទី២នេះ៣ផ្នែកដែរ គឺផ្នែកគឺទី១˝ព័ត៌មានទូទៅ˝ តាមបែបគុណវិស័យ និងមរិមាណវិស័យ ផ្នែកទី២˝កម្រិតសមត្ថភាពរបស់លោកគ្រូ/អ្នកគ្រូដែលកំពុងបង្រៀថ្នាក់វិទ្យាសាស្រ្តថ្នាក់ទី១០ ដល់ទី១២ សម្រាប់ពួកគាតបញ្ចេញយោបល់បន្ថែមចំពោះថ្នាក់ដឹកនាំ និង

គ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញ ផ្តោតលើធនធានអប់រំ ជាពិសេស បន្ទប់ពិសោធន៍˝តាមបែបបរិមាណវិស័យ។

កម្រងសំណួរទាំង២ប្រភេទនេះ ត្រូវបានបង្កើតឡើង ដោយផ្អែកលើទ្រឹស្តីនានាទាក់ទងនឹង ការគ្រប់គ្រង និងដំណើរការសាលាមធ្យមសិក្សាធនធាន នៃក្រសួងអប់រំ យុវជន និងកីឡា។

## ៣.៨. កម្រងសំណួរ និងគោលបំណង

ក. កម្រងសំណួរប្រភេទទី១

កម្រងសំណួរប្រភេទទី១ ដែលត្រូវប្រើប្រាស់សម្រាប់លោកគ្រូ/អ្នកគ្រូបង្រៀនថ្នាក់ទី១០ ដល់ទី១២ មុខវិជ្ជាវិទ្យាសាស្ត្ររបស់សាលាមធ្យមសិក្សាធនធាន និងសាលាមធ្យមសិក្សាបណ្តាញចែកចេញជាបីផ្នែកគឺ៖

•ផ្នែកទី១ ៖ ˝ព័ត៌មានទូទៅ˝មានចំនួន៧សំណួរ

•ផ្នែកទី២ ៖ ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវមានចំនួន៥៦សំណួរតាមបែបបរិមាណវិស័យ ចែកចេញជា៦ផ្នែកតូចៗគឺ៖

១).ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍មាន៩សំណួរ ចាប់ពីសំណួរទី១ ដល់សំណួរទី៩

២).ការគ្រប់គ្រង និងប្រើប្រាស់បណ្ណាល័យសិក្សាមាន១០ សំណួរ ចាប់ពីសំណួរទី១០ ដល់សំណួរទី១៩

៣). ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារបច្ចេកវិទ្យា មាន៩សំណួរចាប់ពីសំណួរទី២០ ដល់សំណួរទី២៨

៤).ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោលមាន៥សំណួរចាប់ពីសំណួរទី២៩ ដល់សំណួរទី៣៣

៥).ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្សមាន១៥សំណួរចាប់ពីសំណួរទី២០ ដល់សំណួរទី៤៨

៦).ការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកាមាន៨សំណួរចាប់ពីសំណួរទី៤៩ ដល់សំណួរទី៥៦

កម្រងសំណួរប្រភេទទី២ ដែលត្រូវប្រើប្រាស់សម្រាប់នាយក/នាយករង ឬនាយិការ/នាយិការង និងបរិច្ចការីបន្ទប់ពិសោធន៍របស់សាលាមធ្យមសិក្សាធនធាន និងគណៈគ្រងសាលាមធ្យសិក្សាបណ្ដាញ ចែកចេញជាបីផ្នែកគឺ៖

•ផ្នែកទី១ ៖ ៉ព័ត៌មានទូទៅ៉មានចំនួន៥សំណួរ

•ផ្នែកទី២ ៖ ស្ថានភាពនៃការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាបណ្ដាញមានចំនួន៤៧សំណួរតាមបែបបរិមាណវិស័យ ចែកចេញជា៧ផ្នែកតូចៗគឺ៖

១).វត្ថុបំណងគោលនយោបាយរបស់សាលារៀនមាន៧សំណួរ

២).ការគ្រប់គ្រងបន្ទប់ពិសោធន៍មាន ៧សំណួរ

៣). ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ មាន៤សំណួរ

៤).ការគ្រប់គ្រងបណ្ណាល័យមាន៤សំណួរ

៥).កិច្ចគាំទ្រការបង្រៀននិងរៀនមាន១០សំណួរ

៦).កិច្ចសហប្រតិបត្តិការមាន៥សំណួរ

៧).ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍មាន១០សំណួរ

•ផ្នែកទី៣ ៖បញ្ហាប្រឈមលើស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញនៅខេត្តតាកែវ( តើលោក/លោកស្រីបញ្ហាលំបាក និងបញ្ហាប្រឈមអ្វីខ្លះក្នុងការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញនៅខេត្តតាកែវ ?

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

ជំពូកនេះនឹងបង្ហាញពីលទ្ធផល នៃការវិភាគទិន្នន័យលើប្រធានបទ៖ "**ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ** " ។ លទ្ធផលនៃការវិភាគទិន្នន័យត្រូវបានយកមកបកស្រាយ តាមរយៈការបំពេញកម្រងសំណួរ ទៅលើក្រុមគោលដៅដែលត្រូវជួយបំពេញរួមមាន ៖ គ្រូបង្រៀន និងគណៈគ្រប់គ្របសាលារៀន មាន នាយក/នាយិកា នាយករង/នាយិការងទទួលបន្ទុកផ្នែកបច្ចេកទេស និងបរិច្ឆការិបន្ទប់ពិសោធន៍ និងគ្រូបង្រៀនថ្នាក់វិទ្យាសាស្ត្រចាប់ពីថ្នាក់ទី១០ដល់ទី១២ ។ លទ្ធផលដែលទទួលបាន នឹងត្រូវយកមកពិភាក្សា និងវិភាគលើការអនុវត្តការងារគ្រប់គ្រងរបស់គណៈគ្រប់គ្រងសាលាដោយផ្តោតលើការអនុវត្ត ៩ ចំណុច សំខាន់ៗគឺ ៖ ១)ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍ ២)ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សា ៣)ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា ៤)ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោល ៥) ការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស ៦) ការគ្រប់គ្រងនិង ប្រើប្រាស់ធនធានថវិកា ៧) វត្ថុបំណងគោលនយោបាយរបស់សាលារៀន ៨) កិច្ចសហប្រតិបត្តិការ ៩)ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ តាមរបៀបដូចខាងក្រោមនេះ៖

## ៤.១ ការវិភាគទិន្នន័យលើកម្រងសំណួរ សម្រាប់គ្រូបង្រៀន

ការវិភាគនេះអ្នកស្រាយជ្រាវ បានប្រើប្រាស់កម្មវិធី Excel ក្នុងការគណនារកតម្លៃមធ្យម Mean ក្នុងការវាយតម្លៃកម្រិតនៃការអនុវត្តការគ្រប់គ្រង និងដឹកនាំរបស់នាយកសាលានៅមធ្យមសិក្សាទុតិយភូមិដោយធ្វើ ការកំណត់ការវាយតម្លៃចែកជាប្រាំកម្រិត ទៅតាមមធ្យមភាគដូចខាងក្រោម ៖ ១) ខ្សោយណាស់ មានតម្លៃ Mean =1 ដល់ Mean= 1.80 , ២ ) ការអនុវត្តបានខ្សោយមានតម្លៃ Mean =1.81 ដល់Mean = 2.60, ៣) ការអនុវត្តបានមធ្យមមានតម្លៃ Mean = 2.61 ដល់ Mean = 3.40 , ៤ ) ការ

អនុវត្តបានល្អ (Mean = 3.41 ដល់ Mean= 4.20 និង ៥) ការអនុវត្តបានល្អណាស់ Mean =4.21 ដល់ Mean = 5.00 ។

## ៤.២. សំណួរស្រាវជ្រាវទី១ (ភាពចន្លោះបង្ហាញរបស់គ្រូ)

តើស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកការបង្រៀននិងរៀនថ្នាក់វិទ្យាសាស្ត្រនៅខេត្តតាកែវយ៉ាងដូចម្តេច?

៤.២.១. ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍

| ល.រ | **១.ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | លោកគ្រូ អ្នកគ្រូបង្រៀនតាមមុខវិជ្ជាចេះប្រើប្រាស់ឧបករណ៍សម្រាប់ធ្វើពិសោធន៍ | 60 | 2.89 | មធ្យម |
| ២ | បន្ទប់ពិសោធន៍មានលក្ខណៈស្តង់ដារ ធំទូលាយ និងមានសម្ភារៈបច្ចេកទេសទំនើបៗ និងមានសម្ភារៈសម្រាប់ធ្វើពិសោធន៍គ្រប់គ្រាន់ | 60 | 3.09 | មធ្យម |
| ៣ | មានអ្នកជំនាញជួយសម្រួលការងាររបស់លោកគ្រូ អ្នកគ្រូក្នុងការប្រើប្រាស់ឧបករណ៍សម្រាប់ធ្វើការពិសោធន៍ | 60 | 2.72 | មធ្យម |
| ៤ | លោកគ្រូ អ្នកគ្រូមានការបែងចែកពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើពិសោធន៍ទៅតាមមុខវិជ្ជា | 60 | 3.54 | ល្អ |
| ៥ | លោកគ្រូ អ្នកគ្រូយល់ឃើញថាអគារធានធនក៏ដូចជាបន្ទប់ពិសោធន៍ផ្សេងៗទៀតជួយបង្កើនចំណេះដឹងបន្ថែមដល់សិស្ស | 60 | 4.13 | ល្អ |
| ៦ | លោកគ្រូ អ្នកគ្រូសង្កេតឃើញថាសិស្សានុសិស្ស ចូលចិត្តម៉ោងពិសោធន៍ដែលទាក់ទងទៅនឹងមេរៀនរបស់ពួកគេ | 60 | 3.93 | ល្អ |
| ៧ | លោកគ្រូ អ្នកគ្រូមានការចូលរួមក្នុងការថែរក្សាសម្ភារៈ និងឧបករណ៍ពិសោធន៍ឲ្យបានល្អគង់វង្ស | 60 | 2.91 | មធ្យម |

| | | | | |
|---|---|---|---|---|
| ៨ | លោកគ្រូ អ្នកគ្រូមានគំនិតឆ្នៃប្រឌិតខ្ពស់ក្នុងការអភិវឌ្ឍ និងកែប្រែបន្ទប់ពិសោធន៍ ឲ្យបានរីកចម្រើន និងមានភាពល្អប្រសើរ | 60 | 2.08 | មធ្យម |
| ៩ | ការរៀបចំសម្ភារៈ និងឧបករណ៍សម្រាប់ធ្វើការពិសោធមានរបៀបរៀបរយ និងមានការបែងចែកប្រភេទដោយមានលក្ខណៈត្រឹមត្រូវនិងច្បាស់លាស់ | 60 | 2.51 | មធ្យម |
| Total | | | 3.08 | មធ្យម |

តាមតារាង៤.២.១ ផ្នែកការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍មានសូចនាករសរុបចំនួន០៩ ក្នុងនោះ តម្លៃពិន្ទុមធ្យមភាគកម្រិតល្អមានតែ០៣សូចនាករប៉ុណ្ណោះគឺចំណុចទី(៤)លោកគ្រូ អ្នកគ្រូមានការបែងចែកពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើពិសោធន៍ទៅតាមមុខវិជ្ជាដែលមានតម្លៃមធ្យមភាគ Mean=3.54 ទទួលបានកម្រិតល្អ ចំណុចទី(៥)លោកគ្រូ អ្នកគ្រូយល់ឃើញថាអគារជានធនក៏ដូចជាបន្ទប់ពិសោធន៍ផ្សេងៗទៀតជួយបង្កើនចំណេះដឹងបន្ថែមដល់សិស្សដែលមានតម្លៃមធ្យមភាគ Mean 4.13 ដែលមានកម្រិតពិន្ទុមធ្យមភាគល្អខ្ពស់ជាងគេបំផុតក្នុងចំណោមតម្លៃមធ្យមភាគល្អទាំងបីក្នុងសូចនាករសរុបទាំងអស់ចំនួនប្រាំបី។ ចំណុចទី(៦)លោកគ្រូ អ្នកគ្រូសង្កេតឃើញថាសិស្សានុសិស្ស ចូលចិត្តម៉ោងពិសោធន៍ដែលទាក់ទងទៅនឹងមេរៀនរបស់ពួកគេដែលមានតម្លៃមធ្យមភាគ Mean=3.93 ទទួលបានកម្រិតល្អ។ ក្រៅពីសូចនាករទាំងបីខាងលើ តម្លៃពិន្ទុសុទ្ធតែមានមធ្យមភាគមធ្យមទាំងអស់បូករួមមធ្យមភាគសរុមផងដែរគឺ Mean 3.08។ដោយឡែកមធ្យមភាគដែលមានតម្លៃពិន្ទុទាបជាងគេគឺចំណុចទី(៨) លោកគ្រូ អ្នកគ្រូមានគំនិតឆ្នៃប្រឌិតខ្ពស់ក្នុងការអភិវឌ្ឍ និងកែប្រែបន្ទប់ពិសោធន៍ ឲ្យបានរីកចម្រើន និងមានភាពល្អប្រសើរដែលមានតម្លៃមធ្យមភាគ Mean 2.08។ នៅក្នុងការបូកសរុបនិងវាយតម្លៃតាមរយៈសូចនាករទាំង៨បានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថាគ្រូបង្រៀននៅសាលាមធ្យមសិក្សាធនជាន និងសាលាមណ្ឌាញ នៅខេត្តតាកែវយល់ឃើញថា ការអនុវត្តការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍នៅសាលាធនជាន របស់នាយកសាលាមានកម្រិតមធ្យម ។

### ៤.២.២ .ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សា

| ល.រ | **ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សា** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | បណ្ណាល័យបានបើក និងបិទទ្វារទៀងទាត់ម៉ោង | 60 | 3.87 | ល្អ |
| ២ | បណ្ណាល័យមានសៀវភៅច្រើនសម្រាប់អាន និងសិក្សាស្រាវជ្រាវ | 60 | 2.99 | មធ្យម |
| ៣ | ការរៀបចំទុកដាក់សៀវភៅមានរបៀបរៀបរយ ទៅតាមកម្រិតថ្នាក់នីមួយៗ និងមានលក្ខណៈងាយស្រួលក្នុងការខ្ចីសៀវភៅ និងការអាន | 60 | 3.75 | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | បណ្ណាល័យសិក្សាមានបន្ទប់ធំទូលាយ មានកន្លែងអង្គុយអានសៀវភៅ មានខ្យល់អាកាសចេញចូលល្អ និងមានពន្លឺគ្រប់គ្រាន់ | 60 | 3.37 | មធ្យម |
| ៥ | លោកគ្រូ អ្នកគ្រូយល់ឃើញថាបណ្ណាល័យពិតជាមានសារៈសំខាន់និងចាំបាច់សម្រាប់ការសិក្សាស្រាវជ្រាវរបស់គ្រូបង្រៀន និងសិស្ស | 60 | 4.04 | ល្អ |
| ៦ | បណ្ណារក្សមានទំនួលខុសត្រូវខ្ពស់ចំពោះការងាររបស់គាត់ | 60 | 3.82 | ល្អ |
| ៧ | ការគ្រប់គ្រង និងការរៀបចំសម្ភារៈសិក្សា និងឯកសារផ្សេងៗនៅក្នុងបណ្ណាល័យមានរបៀបរៀបរយ និងមានសណ្តាប់ធ្នាប់ល្អ | 60 | 3.51 | ល្អ |
| ៨ | លោកគ្រូ អ្នកគ្រូជួយជម្រុញ និងលើកទឹកចិត្តសិស្សឲ្យចូលរួមក្នុងការអានសៀវភៅក្នុងបណ្ណាល័យឲ្យបានច្រើន | 60 | 4.10 | ល្អ |
| ៩ | លោកគ្រូ អ្នកគ្រូមានគំនិតផ្តួចផ្តើមក្នុងការចូលរួមរកឯកសារសំខាន់ៗដែលមានអត្ថប្រយោជន៍ និងផ្តល់ចំណេះដឹងបន្ថែមដល់សិស្ស | 60 | 3.32 | មធ្យម |
| ១០ | លោកគ្រូ អ្នកគ្រូយល់ឃើញថាបណ្ណាល័យគឺជាឃ្លាំងចំណេះដឹងដ៏មានតម្លៃសម្រាប់អ្នកសិក្សាស្រាវជ្រាវ | 60 | 3.67 | ល្អ |
| Tolal | | | 3.77 | ល្អ |

តាមតារាង៤.២.២ បានបង្ហាញថាតម្លៃជាមធ្យមសរុប Mean = 3.77 តម្លៃមធ្យមភាគនេះបញ្ជាក់ថា នាយកសាលា នៅសាលាធនធាន អនុវត្តការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សាបានល្អ ។ ក្នុងចំណោមសូចនាករទាំងដប់ដែលអ្នកស្រាវជ្រាវបានយកមកធ្វើជាកម្រងសំ ណួរសម្រាប់វាយតម្លៃ សូចនាករដែលមានកម្រិតមធ្យមគឺមានបីសូចនាករគឺ ចំណុចទី(២)បណ្ណាល័យមានសៀវភៅច្រើនសម្រាប់អាន និងសិក្សាស្រាវជ្រាវដែលមានតម្លៃ Mean=2.99។ ចំណុចទី(៤)បណ្ណាល័យសិក្សាមានបន្ទប់ធំទូលាយ មានកន្លែងអង្គុយអានសៀវភៅ មានខ្យល់អាកាសចេញចូលល្អ និងមានពន្លឺគ្រប់គ្រាន់ ដែលមានតម្លៃ Mean = 3.37 និងចំណុចទី(៩)លោកគ្រូ អ្នកគ្រូមានគំនិតផ្តួចផ្តើមក្នុងការចូលរួមរកឯកសារសំខាន់ៗដែលមានអត្ថប្រយោជន៍ និងផ្តល់ចំណេះដឹងបន្ថែមដល់សិស្សដែលមានតម្លៃ Mean = 3.32។

### ៤.២.៣. ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា

| ល.រ | ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | បន្ទប់បច្ចេកវិទ្យា (ICT) នៅក្នុងអគារធនជាន ធំទូលាយ មានខ្យល់អាកាសចេញចូល និងមានពន្លឺគ្រប់គ្រាន់ | 60 | 3.42 | មធ្យម |
| ២ | នៅក្នុងបន្ទប់ពិសោធICT មានឧបករណ៍សម្រាប់ការធ្វើពិសោធន៍គ្រប់គ្រាន់ | 60 | 2.99 | មធ្យម |
| ៣ | មានគ្រូបង្រៀនកុំព្យូទ័រឯកទេសខាង ICT ដើម្បីជួយគ្រូបង្រៀននៅក្នុងបន្ទប់ពិសោធន៍ ICT | 60 | 3.54 | ល្អ |
| ៤ | នៅក្នុងបន្ទប់ ICT មានកុំព្យូទ័រគ្រប់គ្រាន់សម្រាប់ធ្វើពិសោធន៍ និងសិក្សាស្រាវជ្រាវ | 60 | 3.37 | មធ្យម |
| ៥ | កុំព្យូទ័រនៅក្នុងបន្ទប់ពិសោធន៍ ICT សុទ្ធតែអាចដំណើរការ និងប្រើប្រាស់បាន | 60 | 3.40 | មធ្យម |
| ៦ | លោកគ្រូ អ្នកគ្រូមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សាស្រាវជ្រាវបន្ថែមទៅលើប្រព័ន្ធបច្ចេកវិទ្យានៅក្នុងបន្ទប់ពិសោធ ICT | 60 | 3.34 | មធ្យម |
| ៧ | លោកគ្រូ អ្នកគ្រូមានការគ្រប់គ្រងល្អ និងបែងចែកកាលវិភាគច្បាស់លាស់ក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍ ICT | 60 | 3.24 | មធ្យម |
| ៨ | ការសិក្សាប្រព័ន្ធបច្ចេកវិទ្យាITC ផ្ដោតលើ Microsoft Word, Excel &Power Point | 60 | 2.99 | មធ្យម |
| ៩ | លោកគ្រូ អ្នកគ្រូយល់ឃើញថាបន្ទប់ ICT នៅក្នុងអគារធនជានពិតជាកន្លែងមួយយ៉ាងសំខាន់ក្នុងការផ្ដល់ចំណេះដឹងដល់គ្រូ និងសិស្សដោយមិនអាចខ្វះបាននាពេលបច្ចុប្បន្ន និងនៅថ្ងៃអនាគត | 60 | 2.80 | មធ្យម |
| Total | | | 3.23 | មធ្យម |

តាមតារាង៤.២.៣ បានបង្ហាញថាតម្លៃ មធ្យមសរុប Mean = 3.23 មានន័យថាការអនុវត្តការគ្រប់គ្រង និងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យាមានកម្រិតមធ្យម ។ ដូចគ្នាផងដែរគ្រប់សូចនាករទាំងអស់ដែលអ្នកស្រាវជ្រាវបានកំណត់ក្នុង ចំណុចនេះដែលមានចំនួន ប្រាំបួន សូចនាករ តម្លៃ Mean មានប្រហាក់ប្រហែលគ្នា គឺបង្ហាញពីការអនុវត្ត របស់នាយកសាលាទទួលបានលទ្ធផលមធ្យមស្ទើរតែគ្រប់សូចនាករទាំងអស់ដោយលើកលែងតែសូចនាករតែមួយគត់ដែលមានកម្រិតពិន្ទុមធ្យមភាគល្អដែលមានតម្លៃ Mean=3.54 គឺសូចនាករទី(៣)។ សរុបជារួមមកអ្នកស្រាវជ្រាវបានរកឃើញថា ដោយផ្អែកលើលទ្ធផលនៃកម្រងសំណួរចំនួនប្រាំបួនដែលលោកគ្រូអ្នកគ្រូបាន ជួយបំពេញ និងជួយវាយតម្លៃលើការអនុវត្តការគ្រប់គ្រង និងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា លទ្ធផលឃើញថានាយកសាលានៅមធ្យមសិក្សាធនជាន និងសាលាបណ្ដាញបានអនុវត្តដោយទទួលបានលទ្ធផលមធ្យម តាមរយៈការគណនាតម្លៃ Mean នេះ ។

៤.២.៤ ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោល

| ល.រ | **ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោល** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់សម្រាប់សិស្សក្នុងការសិក្សាទៅតាមមុខវិជ្ជានីមួយៗ | 60 | 3.57 | ល្អ |
| ២ | សៀវភៅសិក្សាគោលមានគុណប្រយោជន៍ និងជួយជំរុញដល់ការសិស្ស | 60 | 3.80 | ល្អ |
| ៣ | ការប្រគល់សៀវភៅសិក្សាគោលទៅសាលាវិញតាមការកំណត់កាលបរិច្ឆេតត្រឹមត្រូវ | 60 | 3.45 | មធ្យម |
| ៤ | លោកគ្រូ អ្នកគ្រូគិតថាសិស្សទាំងអស់ចាំបាច់ត្រូវតែមានសៀវភៅសិក្សាគោលដោយមិនអាចខ្វះបាន | 60 | 4.05 | ល្អ |
| ៥ | លោកគ្រូ អ្នកគ្រូជួយជម្រុញ និងលើកទឹកចិត្តសិស្សឲ្យចេះស្រឡាញ់ថែរក្សា និងសិក្សាស្រាវជ្រាវបន្ថែមពីសៀវភៅសិក្សាគោល | 60 | 4.20 | ល្អ |

| | | |
|---|---|---|
| Total | 3.81 | ល្អ |

តាមតារាង៤.២.៤ អ្នកស្រាវជ្រាវបានរកឃើញថាតម្លៃមធ្យមសរុប Mean = 3.81 នេះបង្ហាញថាការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោលទទួលបានលទ្ធផលល្អ ។ ក្នុងចំណោមសូចនាករដែលអ្នកស្រាវជ្រាវបានកំណត់ចំនួនប្រាំចំណុចនៅក្នុងផ្នែកនៃការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោលនេះ សូចនាករដែលមានកម្រិតទាបជាងគេមានពីរសូចនាការគឺសូចនាករទី(៣)ការប្រគល់សៀវភៅសិក្សាគោលទៅសាលាវិញតាមការកំណត់កាលបរិច្ឆេតត្រឹមត្រូវ ដែលអ្នកស្រាវជ្រាវរកឃើញតម្លៃពិន្ទុមធ្យមភាគ Mean = 3.45 ។ ក្រៅពីចំណុចទី(៣)នេះដោយមានសូចនាករចំនួនបួនក្នុងចំណោមសូចនាករសរុបចំនួនសរុបចំនួនប្រាំដែលទទួលបានលទ្ធផលមធ្យមភាគល្អ ដោយសរុបជារួមមកអ្នកស្រាវជ្រាវបានរកឃើញថា ដោយផ្អែកលើលទ្ធផលនៃកម្រងសំណួរចំនួនប្រាំដែលលោកគ្រូអ្នកគ្រូបាន ជួយបំពេញនិងជួយវាយតម្លៃលើការអនុវត្តការគ្រប់គ្រង និងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា លទ្ធផលឃើញថានាយកសាលានៅមធ្យមសិក្សាធនធាន និងសាលាបណ្តាញបានអនុវត្តដោយទទួលបានលទ្ធផលល្អតាមរយៈការគណនាតម្លៃ Mean នេះ។

៤.២.៥ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស(គ្រូបង្រៀន)

| ល.រ | **ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស (គ្រូបង្រៀន)** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | លោកនាយក/លោកស្រីនាយិកាបែងចែកកាលវិភាគបង្រៀនសម្រាប់លោកគ្រូ អ្នកគ្រូដោយស្មើរភាពគ្នា | 60 | 3.94 | ល្អ |
| ២ | លោកនាយក/លោកស្រីនាយិកាមិនអនុញ្ញាតឲ្យគ្រូផ្ទេរចេញទោះបីដឹងថាសាលារបស់ខ្លួនខ្វះគ្រូក៏ដោយ | 60 | 3.75 | ល្អ |
| ៣ | លោកគ្រូ អ្នកគ្រូមកបង្រៀនទៀងទាត់ពេលវេលា | 60 | 3.85 | ល្អ |

| | | | | |
|---|---|---|---|---|
| ៤ | លោកនាយក/លោកស្រីនាយិការៀបចំចាត់ចែងកាលវិភាគ និងចាត់តាំងឲ្យគ្រូបង្រៀនតាមមុខវិជ្ជាតាម ជំនាញ ឯកទេស និងមានទេពកោសល្យច្បាស់លាស់ក្នុងការបង្រៀន(ត្រូវតាមគុណវុឌ្ឍិគ្រូបង្រៀន) | 60 | 3.90 | ល្អ |
| ៥ | លោកនាយក/លោកស្រីនាយិកាធ្វើថ្នាក់និទស្សន៍ចំពោះគ្រូបង្រៀនទើបចេញថ្មី និងគ្រូមានបទពិសោធន៍ក្នុងការបង្រៀនច្រើនឆ្នាំយ៉ាងទៀងទាត់ | 60 | 4.02 | ល្អ |
| ៦ | គ្រូបង្រៀនមួយចំនួនតូចមានឈ្មោះបម្រើការងារនៅក្នុងអង្គភាព ប៉ុន្តែមិនមានវត្តមានក្នុងការបំពេញការងារទាល់តែសោះ(មានតែឈ្មោះ) | 60 | 1.90 | ខ្សោយ |
| ៧ | គ្រប់ការប្រជុំរួម និងប្រជុំក្រុមបច្ចេកទេស ឃើញថាលោកគ្រូ អ្នកគ្រូបានមកចូលរួមប្រជុំយ៉ាងទៀងទាត់ | 60 | 3.60 | ល្អ |
| ៨ | លោកនាយក/លោកស្រីនាយិកាយកចិត្តទុកដាក់ចំពោះគ្រូបង្រៀនដែលមកពីឆ្ងាយក្នុងការរៀបចំអន្តេវាសិកឲ្យស្នាក់នៅ | 60 | 1.70 | ខ្សោយណាស់ |
| ៩ | សាលារៀនរបស់លោកគ្រូ អ្នកគ្រូ មានមុខវិជ្ជាមួយចំនួនលើសគ្រូ និងមុខវិជ្ជាមួយចំនួនទៀតខ្វះគ្រូ | 60 | 3.49 | ល្អ |
| ១០ | លោកគ្រូ អ្នកគ្រូខ្លះមកបង្រៀនតែដើមឆ្នាំសិក្សា (គ្រូអសកម្មនឹងការងារ)ជាពិសេស គ្រូមុខវិជ្ជាអប់រំកាយ និងកីឡា | 60 | 1.87 | ខ្សោយ |
| ១១ | លោកគ្រូ អ្នកគ្រូមានបំណែងចែកកម្មវិធីសិក្សា និងបង្រៀនតាមកិច្ចតែងការត្រឹមត្រូវច្បាស់លាស់ | 60 | 3.65 | ល្អ |
| ១២ | កិច្ចតែងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូបានកំណត់វត្ថុបំណងត្រឹមត្រូវច្បាស់លាស់ និងក្តោបខ្លឹមសារមេរៀនទាំងស្រុង | 60 | 3.87 | ល្អ |
| ១៣ | លោកនាយក/លោកស្រីនាយិកាតែងតែលើកទឹកចិត្តបុគ្គលិកតាមរយៈពាក្យសំដី សម្ភារៈ ឬថវិកាជាដើម | 60 | 3.94 | ល្អ |
| ១៤ | លោកនាយក/លោកស្រីនាយិកាតែងតែដាស់តឿន និងណែនាំដល់បុគ្គលិកណាដែលអសកម្មនឹងការងារ | 60 | 3.84 | ល្អ |
| ១៥ | បុគ្គលិកយកចិត្តទុកដាក់ចំពោះការផ្សព្វផ្សាយព័ត៌មាន ឬសេចក្តីណែនាំផ្សេងៗដែលទាក់ទងទៅនឹងដំណើរការបង្រៀននិងរៀនពីសំណាក់គណៈគ្រប់គ្រងសាលា | 60 | 3.80 | ល្អ |

| Total | 3.41 | ល្អ |
|---|---|---|

តាមតារាង៤.២.៥ អ្នកស្រាវជ្រាវបានរកឃើញថាតម្លៃមធ្យមសរុប Mean = 3.41 នេះបានបង្ហាញឲ្យឃើញថាការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស(គ្រូបង្រៀន)ដោយទទួលបានលទ្ធផលល្អ ។ ក្នុងចំណោមសូចនាករដែលអ្នកស្រាវជ្រាវបានកំណត់ចំនួនដប់ប្រាំចំណុចនៃការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស(គ្រូបង្រៀន)នេះ សូចនាករដែលមានកម្រិតទាបជាងគេ ដែលមានកម្រិតមធ្យមភាគខ្សោយ និងខ្សោយណាស់ មានតែបីសូចនាករប៉ុណ្ណោះ គឺចំណុចទី(៦)គ្រូបង្រៀនមួយចំនួនតូចមានឈ្មោះបម្រើការងារនៅក្នុងអង្គភាព ប៉ុន្តែមិនមានវត្តមានក្នុងការបំពេញការងារទាល់តែសោះ(មានតែឈ្មោះ) ដែលអ្នកស្រាវជ្រាវរកឃើញតម្លៃមធ្យមភាគ Mean = 1.90 ។ ចំណុចទី(៨)លោកនាយក/លោកស្រីនាយិកាយកចិត្តទុកដាក់ចំពោះគ្រូបង្រៀនដែលមកពីឆ្ងាយក្នុងការរៀបចំអន្តេវាសិកឲ្យស្នាក់នៅដែលមានតម្លៃពិន្ទុមធ្យមភាគ Mean = 1.70 (ដែលមានកម្រិតខ្សោយណាស់ ក្នុងចំណុចនេះមានន័យថានៅក្នុងសាលាទាំងប៉ុន្មានដែលអ្នកស្រាវជ្រាវបានលើកយកមកសិក្សា និងស្រាវជ្រាវបានបញ្ជាក់ឲ្យដឹងថានៅក្នុងសាលាខាងលើមិនមានការរៀបចំអន្តេវសិកសម្រាប់លោកគ្រូ អ្នកគ្រូដែលជាគ្រូបង្រៀនហើយមកពីចម្ងាយឲ្យស្នាក់នៅនោះទេ ដោយមានតែគ្រូបង្រៀនមួយចំនួនតូចបំផុតដែលបានសុំស្នាក់អាស្រ័យជាបណ្ណោះអាសន្នតែប៉ុណ្ណោះ)។ ចំណុចទី(១០) លោកគ្រូ អ្នកគ្រូខ្លះមកបង្រៀនតែដើមឆ្នាំសិក្សា(គ្រូអសកម្មនឹងការងារ)ជាពិសេស គ្រូមុខវិជ្ជាអប់រំកាយ និងកីឡា ដែលអ្នកស្រាវជ្រាវបានរកឃើញតម្លៃពិន្ទុមធ្យមភាគ Mean = 1.87 ។ ដោយឡែកក្រៅពីចំណុច(ទី៦ ទី៨ និងទី១០)នេះដោយមានសូចនាករចំនួនដប់ពីរក្នុងចំណោមសូចនាករសរុបចំនួនដប់ប្រាំដែលទទួលបានលទ្ធផលមធ្យមភាគល្អដែលមានតម្លៃពិន្ទុមធ្យមភាគប្រហាក់ប្រហែលគ្នាចន្លោះមធ្យមភាគ3.60 ដល់4.02។ ដោយសរុបជារួមមក អ្នកស្រាវជ្រាវបានរកឃើញថា ដោយផ្អែកលើលទ្ធផលនៃកម្រងសំណួរចំនួនដប់ប្រាំដែលលោកគ្រូ អ្នកគ្រូបាន ជួយបំពេញ និងជួយវាយតម្លៃលើការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស(គ្រូបង្រៀន) លទ្ធផលឃើញថានាយក/នាយិ

កាសាលានៅមធ្យមសិក្សាធនធាន និងសាលាបណ្ដាញបានអនុវត្តដោយទទួលបានលទ្ធផលល្អតាមរយៈការគណនាតម្លៃ Mean នេះ។

### ៤.២.៦ ការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកា

| ល.រ | **ការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកា** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | ដំណើរការនៃការចាយវាយថវិកាសម្រាប់ការអភិវឌ្ឍសាលារៀន មានតម្លាភាព យុត្តិធម៌ បើកចំហរ និងមានការប្រជុំផ្សព្វផ្សាយជាប្រចាំ | 60 | 4.35 | ល្អ |
| ២ | ថវិកាសម្រាប់ទ្រទ្រង់សាលារៀនត្រូវបានប្រើប្រាស់ចំទិសដៅក្នុងគោលគំនិតអភិវឌ្ឍន៍សាលា ក៏ដូចជាការកែលម្អបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធនានា | 60 | 3.85 | ល្អ |
| ៣ | លោកនាយក/លោកស្រីនាយិកាធ្វើការរៀបចំប្រជុំប្រចាំខែនីមួយៗ ដោយមានការផ្សព្វផ្សាយអំពីចំណូល និងខ្ទង់ចំណាយរបស់សាលារៀនតាមរយៈការបង្ហាញលើក្ដាខៀនព័ត៌មាន ដោយមានវិក័យបត្របញ្ជាក់ពីការចំណាយ និងចំណូលផ្សេងៗ | 60 | 3.90 | ល្អ |
| ៤ | លោកនាយក/លោកស្រីនាយិកាបើកការប្រជុំក្រុមបច្ចេកទេសតាមត្រីមាសនីមួយៗយ៉ាងទៀងទាត់ | 60 | 4.10 | ល្អ |
| ៥ | លោកនាយក/លោកស្រីនាយិកាគៀរគរថវិកាពីសប្បុរសជន សហគមន៍ មាតាបិតាសិស្សក្នុងការទ្រទ្រង់ និងអភិវឌ្ឍន៍សាលារៀន | 60 | 3.30 | មធ្យម |
| ៦ | ការចំណាយថវិការបស់សាលារៀនត្រូវឆ្លងកាត់ភាគីពាក់ព័ន្ធនានាដើម្បីសម្រេច | 60 | 3.45 | ល្អ |
| ៧ | លោកនាយក/លោកស្រីនាយិកាប្រើប្រាស់ថវិកាតាមផែនការ ប្រចាំឆ្នាំ និងចំគោលដៅ | 60 | 4.35 | ល្អ |
| ៨ | លោកនាយក/លោកស្រីនាយិកាខិតខំលះបង់កម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ និងគ្រប់គ្រង | 60 | 4.15 | ល្អ |

| | | |
|---|---|---|
| សរុប | 3.80 | ល្អ |

តាមតារាង៤.២.៦ ផ្នែកការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកាដែលមានសូចនាករសរុបទាំងអស់ចំនួន០៨ ក្នុងនោះ តម្លៃពិន្ទុមធ្យមភាគកម្រិតល្អមានចំនួន០៧សូចនាករក្នុងនោះមានៈចំណុចទី(១)ដំណើរការនៃការចាយវាយថវិកាសម្រាប់ការអភិវឌ្ឍសាលារៀន មានតម្លាភាព យុត្តិធម៌ បើកចំហរ និងមានការប្រជុំផ្សព្វផ្សាយជាប្រចាំដែលមានតម្លៃមធ្យមភាគ Mean= 4.35ទទួលបានកម្រិតល្អ ចំណុចទី(២)ថវិកាសម្រាប់ទ្រទ្រង់សាលារៀនត្រូវបានប្រើប្រាស់ចំទិសដៅក្នុងគោលគំនិតអភិវឌ្ឍន៍សាលា ក៏ដូចជាការកែលម្អបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធនានាដែលមានតម្លៃមធ្យមភាគ Mean =3.85 ដែលមានកម្រិតមធ្យមភាគល្អ។ ចំណុចទី(៣)លោកនាយក/លោកស្រីនាយិកាធ្វើការរៀបចំប្រជុំប្រចាំខែនីមួយៗដោយមានការផ្សព្វផ្សាយអំពីចំណូល និងខ្ទង់ចំណាយរបស់សាលារៀនតាមរយៈការបង្ហាញលើក្តាខៀនព័ត៌មាន ដោយមានវិក័យបត្របញ្ជាក់ពីការចំណាយ និងចំណូលផ្សេងៗដែលមានតម្លៃមធ្យមភាគ Mean=3.9 ទទួលបានកម្រិតល្អ។ ចំណុចទី(៤) លោកនាយក/លោកស្រីនាយិកាបើកការប្រជុំក្រុមបច្ចេកទេសតាមត្រីមាសនីមួយៗយ៉ាងទៀងទាត់ដែលមានតម្លៃមធ្យមភាគ Mean= 4.10 ទទួលបានកម្រិតល្អ។ ដោយឡែកមធ្យមភាគដែលមានតម្លៃពិន្ទុទាបជាងគេបំផុតក្នុងចំណោមសូចនាករទាំងប្រាំបី គឺចំណុចទី(៥)លោកនាយក/លោកស្រីនាយិកាគៀរគរថវិកាពីសប្បុរសជន សហគមន៍ មាតាបិតាសិស្សក្នុងការទ្រទ្រង់ និងអភិវឌ្ឍន៍សាលារៀនដែលមានតម្លៃមធ្យមភាគ Mean= 3.30 ដែលមានកម្រិតមធ្យមភាគមធ្យម។ ក្រៅពីសូចនាករចំណុចទី(៥)ខាលើនេះសុទ្ធតែមានកម្រិតមធ្យមភាគល្អទាំងអស់បូករួមមធ្យមភាគសរុមផងដែរដែលមានតម្លៃ Mean= 3.80។ នៅក្នុងការបូកសរុប និងវាយតម្លៃតាមរយៈសូចនាករទាំង៨ដែលអ្នកសិក្សាស្រាវជ្រាវបានដាក់ឲ្យលោកគ្រូ អ្នកគ្រូផ្តល់ចម្លើយតាមរយៈការបំពេញកម្រងសំណួរបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថា ការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកាមានល្អ។

តាមលទ្ធផលការបកស្រាយខាងលើក្នុងផ្នែកដំណើរការគ្រប់គ្រង និនងការប្រើប្រាស់ធនធានថវិកាទទួលបានតម្លៃពិន្ទុមធ្យមភាគរួមគឺកម្រិតល្អ ដូច្នេះមានន័យថា លោកនាយក លោកស្រីនាយិកាចាយថវិកា

ដោយមានតម្លាភាព យុត្តិធម៌ បើកចំហរ ប្រើប្រាស់ចំទិសដៅ។ ម្យ៉ាងទៀត ការផ្តល់ប្រាក់អាហាររូបករណ៍មានតម្លាភាព ការផ្សព្វផ្សាយពីចំណូលចំណាយរបស់សាលារៀនបានទូលំទូលាយ និងការចំណាយថវិកានានារបស់សាលាត្រូវឆ្លងកាត់ភាគីពាក់ព័ន្ធនានានៅក្នុងអង្គភាពដើម្បីសម្រេចផងដែរ។

សរុបជារួមមកក្នុងសំណួរស្រាវជ្រាវទី (១) តើស្ថានភាពនៃការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញក្នុងខេត្តតាកែវមានស្ថានភាពដូចម្តេច?តាមរយៈលទ្ធផលកម្រងសំណួរចំពោះលោកគ្រូ អ្នកគ្រូ ជាលទ្ធផលបានបង្ហាញថា ការអនុវត្តការគ្រប់គ្រងរបស់នាយក/នាយិកាសាលាចំពោះស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញក្នុងខេត្តតាកែវបានអនុវត្តការគ្រប់គ្រង ទាំង៦ចំណុចសំខាន់គឺ ១) ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍ ២)ការគ្រប់គ្រង និងប្រើប្រាស់បណ្ណាល័យ ៣) ការគ្រប់គ្រង និងប្រើប្រាសសម្ភារបច្ចេកវិទ្យា ៤) ការគ្រប់គ្រងនិងប្រើប្រាស់សៀវភៅគោល ៥) ការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស និង ៦).ការគ្រប់គ្រង និងប្រើប្រាស់ធនធានថវិកា អ្នកស្រាវជ្រាវបានរកឃើញថា នាយក/នាយិកាសាលាអនុវត្តន៍ភាគច្រើនទទួលបានលទ្ធផលល្អ គឺមានតែសកម្មភាពមួយចំនួនតូចប៉ុណ្ណោះដែលនាយក/នាយិកាសាលាអនុវត្តបានត្រឹមតែ កម្រិតមធ្យម ។

## ៤.៣ ការវិភាគទិន្នន័យលើកម្រងសំណួរ សម្រាប់គណៈគ្រប់គ្រងសាលារៀន

នៅក្នុងចំណុច ៤.៣ នេះអ្នកស្រាវជ្រាវបានជួបពិភាក្សាជាមួយសាស្រ្តចារ្យដឹកនាំបង្គោល និងដឹកនាំរងបាន សម្រេចគំណត់កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលារៀនរួមមាន ៖ នាយក/នាយិកា ឬនាយករង/នាយិការងទទួលបន្ទុកការងារបច្ចេកទេស និងបរិច្ចាការីបន្ទប់ពិសោធន៍ គឺកំណត់យកសូចនាករនិងខ្លឹមសារប្រហាក់ប្រហែលគ្នាទៅនឹងកម្រងសំណួរដែលអ្នកស្រាវជ្រាវបានបង្កើតសម្រាប់គ្រូបង្រៀនដែរ ។ដែលសូចនាករទាំងនេះគឺចង់ឲ្យគណៈគ្រប់គ្រងសាលារៀន សម្រេចចិត្ត ធ្វើការវាយតម្លៃសកម្មភាពការអនុវត្តការដឹកនាំនិងគ្រប់គ្រង របស់នាយក/នាយិកាចំពោះសាលាមធ្យមសិក្សាធនធាន និងបណ្តាញលា ជាអ្នកវាយតម្លៃសកម្មភាពរបស់ខ្លួន ព្រមទាំងមានឱកាសបង្ហាញពីបញ្ហាប្រឈមក្នុងការដឹកនាំ

និង គ្រប់គ្រង ដែលនាយក/នាយិកាសាលាមធ្យមសិក្សាធនធាន និងមធ្យមសិក្សាបណ្ដាញបានជួបប្រទះផងដែរ ។ កម្រងសំណួរនេះអ្នកស្រាវជ្រាវបាន ផ្ដោតទៅលើសកម្មភាព នៃការដឹកនាំ និងគ្រប់គ្រង ដែលផ្ដោតលើការនុវត្តរបស់នាយក/នាយិកាសាលាដោយផ្អែកលើគោលចំណុចសំខាន់ចំនួន៧ រួមមាន ៖ ១)វត្ថុបំណងគោលនយោបាយរបស់សាលារៀន ២)ការគ្រប់គ្រងបន្ទប់ពិសោធន៍ ៣)ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ ៤) ការគ្រប់គ្រងបណ្ណាល័យ ៥) កិច្ចគាំទ្រការបង្រៀន និងរៀន ៦) កិច្ចសហប្រតិបត្តិការ និង ៧)ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ តាមរបៀបដូចខាងក្រោម ៖

ការវិភាគនេះអ្នកស្រាយជ្រាវ បានប្រើប្រាស់កម្មវិធី Excel ក្នុងការគណនារកតម្លៃមធ្យម (Mean)ដើម្បីធ្វើការវាយតម្លៃក្រិតនៃការអនុវត្តការគ្រប់គ្រងនិងដឹកនាំរបស់នាយកសាលានៅមធ្យមសិក្សាទុតិយភូមិ ដោយធ្វើ ការកំណត់ការវាយតម្លៃចែកជាប្រាំកម្រិត ទៅតាមមធ្យមភាគដូចខាងក្រោម ៖ ១ ខ្សោយណាស់ (មានតម្លៃចន្លោះ Mean=1 ដល់ 1.80) , ២ ការអនុវត្តបានខ្សោយ(មានតម្លៃចន្លោះMean=1.81 ដល់ 2.60 ) , ៣ ការអនុវត្តបានមធ្យម (មានតម្លៃចន្លោះ Mean=2.61 ដល់ 3.40) , ៤ ការអនុវត្តបានល្អ (មានតម្លៃចន្លោះ Mean = 3.41 ដល់ 4.20) និង 5 ការអនុវត្តបានល្អណាស់ (មានតម្លៃចន្លោះ Mean = 4.21 ដល់ 5.00) ដូចគ្នាជាមួយការកំណត់កម្រិតវាយតម្លៃក្នុងកម្រងសំណួររបស់គ្រូបង្រៀនដែរ ។

៤.៤ សំណួរស្រាវជ្រាវទី១

តើស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញលើផ្នែកអប់រំវិទ្យាសាស្ត្រកនៅខេត្តតាកែវយ៉ាងដូចម្ដេច?

៤.៤.១ វត្ថុបំណងគោលនយោបាយរបស់សាលារៀន

| ល.រ | **វត្ថុបំណងគោលនយោបាយរបស់សាលារៀន** | ចំនួន | មធ្យមភាគ | គម្លាត |
|---|---|---|---|---|

| | | | | |
|---|---|---|---|---|
| ១ | ភាគរយសិស្សលើលទ្ធផលតេស្តមុខវិជ្ជាសិក្សាគោល | 24 | 3.96 | ល្អ |
| ២ | ភាគរយសិស្សលើលទ្ធផលតេស្តមុខវិជ្ជាវិទ្យាសាស្ត្រ | 24 | 3.80 | ល្អ |
| ៣ | ភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | 24 | 4.45 | ល្អណាស់ |
| ៤ | ភាគរយសិស្សប្រឡងជាប់សញ្ញាប្រមធ្យសិក្សាទុតិយភូមិ | 24 | 3.17 | មធ្យម |
| ៥ | ភាគរយសិស្សចូលរៀន | 24 | 4.30 | ល្អ |
| ៦ | ភាគរយសិស្សរៀនត្រួតថ្នាក់ | 24 | 1.20 | ខ្សោយណាស់ |
| ៧ | ភាគរយសិស្សបោះបង់ការសិក្សា | 24 | 1.10 | ខ្សោយណាស់ |
| សរុប | | | 2.98 | មធ្យម |

តាមតារាង៤.៤.១ ក្នុងចំណោមសូចនាករទាំងប្រាំពីរចំណុចនេះ ដែលអ្នកសិក្សាស្រាវជ្រាវបានកំណត់ជាសំណួរស្រាវជ្រាវដើម្បីឲ្យគណៈគ្រប់គ្រងសាលាបំពេញដើម្បីរកចម្លើយ ក្នុងការគណនារកតម្លៃមធ្យមភាគសរុបទទួលបានលទ្ធផល Mean = 2.98 តាមលទ្ធផលនេះ បង្ហាញថា នាយក/នាយិកាសាលានៅមធ្យមសិក្សាធនជាន និងសាលាបណ្ដាញបានអនុវត្តការដឹកនាំ និងគ្រប់គ្រងស្ដីអំពីវត្ថុបំណងគោលនយោបាយរបស់សាលាមធ្យមសិក្សាធនាន និងមធ្យមសិក្សាបណ្ដាញមានមានកម្រិតមធ្យមដោយផ្អែកលើលទ្ធផលខាងលើនេះ។ នៅក្នុងចំណោមសូចនាករទាំងអស់មានសូចនាករតែមួយគត់ដែលមានតម្លៃមធ្យមភាគខ្ពស់ជាងគេបំផុតគឺ Mean= 4.45 ដែលទទួលបានកម្រិតល្អណាស់គឺនៅត្រង់ចំណុចទី(៣)ភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិមានន័យថា(សិស្សប្រឡងជាប់ច្រើនលើសលប់)។មានតែសូចនាករពីរប៉ុណ្ណោះដែលមានតម្លៃមធ្យមភាគទាបបំផុត Mean = 1.10 នៅត្រង់ចំណុចទី(៧)ភាគរយសិស្សបោះបង់ការសិក្សា នៅក្នុងសូចនាករនេះមានន័យថាអត្រាសិស្សបោះបង់ការសិក្សានៅមាន

កម្រិតទាប និងចំណុចទី(៦) ភាគរយសិស្សរៀនត្រួតថ្នាក់ មានន័យថាអត្រាសិស្សរៀនត្រួតថ្នាក់នៅតាមសាលាមានកម្រិតតិចតួចបំផុត។

៤.៤.២ .ការគ្រប់គ្រងបន្ទប់ពិសោធន៍

| ល.រ | **ការគ្រប់គ្រងបន្ទប់ពិសោធន៍** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | បានធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន | 24 | 3.80 | ល្អ |
| ២ | បានធ្វើផែនការសម្រាប់ការបណ្តុះបណ្តាលការបណ្តុះបណ្តាលគ្រូ ទាក់ទងបន្ទប់ពិសោធន៍ | 24 | 2.70 | មធ្យម |
| ៣ | បានប្រើប្រាស់អស់លទ្ធភាពរបស់បន្ទប់ពិសោធន៍ | 24 | 3.95 | ល្អ |
| ៤ | ធ្វើឲ្យប្រាកដថាបុគ្គលិកអប់រំមានជំនាញច្បាស់លាស់ | 24 | 3.30 | មធ្យម |
| ៥ | ស្វែងរកប្រាក់ចំណូល ថវិកាដើម្បីធានានិរន្តភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ | 24 | 2.90 | មធ្យម |
| ៦ | មាននីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ដែលខូច | 24 | 3.80 | ល្អ |
| ៧ | បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច | 24 | 4.40 | ល្អណាស់ |
| សរុប | | | 3.55 | ល្អ |

តាមតារាង៤.៤.២. ផ្នែកការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍មានសូចនាករសរុបចំនួន០៧ ក្នុងនោះតម្លៃពិន្ទុមធ្យមភាគកម្រិតល្អណាស់មានតែ០១សូចនាករប៉ុណ្ណោះគឺចំណុចទី(៧)បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ចដែលមានតម្លៃមធ្យមភាគ Mean=4.40 ទទួលបានមធ្យមភាគកម្រិតល្អណាស់ និងនៅក្នុងចំណោមសូចនាករទាំងអស់មានបធ្យមភាគដែលមានកម្រិតល្អចំនួនបីសូចនាករផងដែរគឺះចំណុចទី(១)បានធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធានដែល

មានតម្លៃមធ្យមភាគ Mean= 3.80។ ចំណុចទី(៣) បានប្រើប្រាស់អស់លទ្ធភាពរបស់បន្ទប់ពិសោធន៍ដែលមានកម្រិតមធ្យមភាគ Mean= 3.95។ចំណុចទី(៦)មាននីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ដែលខូចដែលមានកម្រិតមធ្យមភាគ Mean=3.95។ ក្រៅពីសូចនាករទាំប៉ុន្មានខាងលើគឺសុទ្ធតែទទួលបានកម្រិតមធ្យមភាគកម្រិតមធ្យមដូចគ្នា។ នៅក្នុងការបូកសរុបនិងវាយតម្លៃតាមរយៈសូចនាករទាំង៧ បានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថាគណៈគ្រប់គ្រងនៅសាលាមធ្យមសិក្សាធនជាន និងសាលាមណ្ឌាញ នៅខេត្តតាកែវយល់ឃើញថា ការអនុវត្តការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍នៅសាលាធនជានរបស់លោក/លោកស្រីទទួលបានលទ្ធផលកម្រិតល្អ ។

៤.៤.៣ ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ

| ល.រ | **ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | កុំព្យូទ័រដំណើរការគ្រប់ចំនួន | 24 | 3.80 | ល្អ |
| ២ | មានអ្នកទទួលបន្ទុកបន្ទប់កុំព្យូទ័រ | 24 | 3.35 | មធ្យម |
| ៣ | មានការរៀបំកាលវិភាគសម្រាប់ប្រើប្រាស់បន្ទប់កុំព្យូទ័រ | 24 | 3.55 | ល្អ |
| ៤ | មានបង្រៀនកុំព្យូទ័របន្ថែម ដើម្បីអភិវឌ្ឍសមត្ថភាព | 24 | 3.20 | មធ្យម |
| Total | | | 3.47 | ល្អ |

តាមតារាង៤.៤.៣ បានបង្ហាញថាការគណនារកតម្លៃមធ្យមសរុបនៃសូចនាករទាំងបួនចំណុចដែលអ្នកស្រាវជ្រាវបានកំណត់សម្រាប់ប្រមូលទិន្នន័យពីគណៈគ្រប់គ្រងសាលារៀនបានបង្ហាញតម្លៃមធ្យមភាគសរុប គឺ Mean = 3.47 តម្លៃមធ្យមសរុបនេះបានបង្ហាញថា ការអនុត្តការការគ្រប់គ្រងបន្ទប់កុំព្យូទ័ររបស់លោកនាយកឬលោកស្រីនាយិកាសាលា គឺបានកម្រិតល្អ ។

### ៤.៤.៤. ការគ្រប់គ្រងបណ្ណាល័យ

| ល.រ | ការគ្រប់គ្រងបណ្ណាល័យ | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | មានបណ្ណារក្សប្រចាំការទៀតទាត់ | 24 | 3.50 | ល្អ |
| ២ | បណ្ណារក្សបានទទួលការបណ្តុះបណ្តាល | 24 | 3.30 | មធ្យម |
| ៣ | មានសៀវភៅស្រាវជ្រាវសំបូរបែប | 24 | 3.40 | មធ្យម |
| ៤ | មានកាលវិភាគសម្រាប់ការប្រើប្រាស់បណ្ណាល័យ | 24 | 4.00 | ល្អ |
| សរុប | | | 3.55 | ល្អ |

តាមតារាង៤.៤.៤ បានបង្ហាញថាការគណនារកតម្លៃមធ្យមសរុបនៃសូចនាករទាំងបួនចំណុចដែលអ្នកស្រាវជ្រាវបានកំណត់សម្រាប់ប្រមូលទិន្នន័យពីគណៈគ្រប់គ្រងសាលារៀនបានបង្ហាញតម្លៃមធ្យមភាគសរុបគឺ Mean = 3.55 តម្លៃមធ្យមសរុបនេះបានបង្ហាញថា ការអនុត្តការការគ្រប់គ្រងបណ្ណាល័យរបស់លោកនាយកឬលោកស្រីនាយិកាសាលា គឺបានកម្រិតល្អ ។ នៅក្នុងចំណោមសូចនាករទាំងបួនតាមការគណនារបស់អ្នកសិក្សាស្រាវជ្រាវបានបង្ហាញថាកម្រិតនៃការអនុវត្តភាគច្រើនគឺទទួលបានលទ្ធផលកម្រិតមធ្យមភាគល្អ ដូចទៅនឹងលទ្ធផលកម្រិតមធ្យមភាគសរុបផងដែរ។ ដោយឡែកមានតែមួយសូចនាករពីរប៉ុណ្ណោះដែលទទួលបានកម្រិតមធ្យមភាគមធ្យមដែលមានតមម្លៃកម្រិតមធ្យមភាគប្រហាក់ប្រហែលគ្នាគឺៈចំណុចទី (២)បណ្ណារក្សបានទទួលការបណ្តុះបណ្តាលដែលមានកម្រិតមធ្យមភាគតម្លៃ Mean= 3.30 និងនៅក្នុងចំណុចទី(៣)មានសៀវភៅស្រាវជ្រាវសំបូរបែបដែលមានកម្រិតមធ្យមភាគតម្លៃ Mean= 3.40 ។

### ៤.៤.៥ កិច្ចគាំទ្រការបង្រៀន និងរៀន

| ល.រ | **កិច្ចគាំទ្រការបង្រៀន និងរៀន** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | ផ្តល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | 24 | 2.80 | មធ្យម |
| ២ | មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រង | 24 | 4.25 | ល្អណាស់ |
| ៣ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាបណ្តាញទាំងអស់ | 24 | 4.20 | ល្អ |
| ៤ | ជានាបាននូវយន្តការស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍ ប្រកបដោយសុវត្ថភាព | 24 | 4.00 | ល្អ |
| ៥ | មានកាលវិភាគថ្នាក់គ្រូនៅមុខបន្ទប់ពិសោធន៍ | 24 | 4.45 | ល្អណាស់ |
| ៦ | មានការគាំទ្រ និងលើកទឹកចិត្តគ្រូ សិស្សសម្រាប់ធ្វើការស្រាវជ្រាវនៅបន្ទប់ពិសោធន៍ | 24 | 4.35 | ល្អ |
| ៧ | បន្ទប់ពិសោធន៍មានសេចក្តីណែនាំ ស្តីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធ | 24 | 4.10 | ល្អ |
| ៨ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់ជួសជុលសម្ភារៈជាទៀងទាត់ | 24 | 3.45 | ល្អ |
| ៩ | មានបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់លោកគ្រូ អ្នកគ្រូ | 24 | 3.40 | ល្អ |
| ១០ | មានផ្តល់រង្វាន់លើកទឹកចិត្ត ដល់របៀបពិសោធន៍ថ្មីៗ | 24 | 3.30 | មធ្យម |
| សរុប | | | 3.83 | ល្អ |

តាមតារាង៤.៤.៥បានបង្ហាញថាការគណនារកតម្លៃមធ្យមសរុបនៃសូចនាករទាំងដប់ចំណុចដែលអ្នកស្រាវជ្រាវបានកំណត់សម្រាប់ប្រមូលទិន្នន័យពីគណៈគ្រប់គ្រងសាលារៀនបានបង្ហាញតម្លៃមធ្យមភាគសរុបគឺ Mean = 3.83 តម្លៃមធ្យមសរុបនេះបានបង្ហាញថា  ការអនុត្តការងារភាពជាអ្នកដឹកនាំ

និងគ្រប់គ្រងរបស់លោកនាយក/លោកស្រីនាយិកាសាលា គឺទទួលបានកម្រិតល្អ ។ នៅក្នុងចំណោមសូចនាករទាំងដប់តាមការគណនារបស់អ្នកសិក្សាស្រាវជ្រាវបានបង្ហាញថាកម្រិតនៃការអនុវត្តភាគច្រើនគឺទទួលបានលទ្ធផលកម្រិតមធ្យមភាគល្អ ដូចទៅនឹងលទ្ធផលតម្លៃមធ្យមភាគសរុបផងដែរ។ ដោយឡែកមានតែមួយសូចនាករពីរប៉ុណ្ណោះដែលទទួលបានកម្រិតមធ្យមភាគល្អណាស់ដែលមានតម្លៃកម្រិតមធ្យមភាគប្រហាក់ប្រហែលគ្នាគឺៈចំណុចទី (២)មានរៀបចំការប្រជុំ ស្តីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយគណៈគ្រប់គ្រងដែលមានកម្រិតមធ្យមភាគតម្លៃ Mean= 4.25 និងនៅក្នុងចំណុចទី (៣)មានសៀវភៅស្រាវជ្រាវសំបូរបែបដែលមានកម្រិតមធ្យមភាគតម្លៃ Mean= 3.45 ។

៤.៤.៦ កិច្ចសហប្រតិបត្តិការ

| ល.រ | **កិច្ចសហប្រតិបត្តិការ** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | សាលាបឋមសិក្សាបណ្តាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | 24 | 3.80 | ល្អ |
| ២ | បានបង្កបរិយាកាស ឱ្យភាគីពាក់ព័ន្ធ អាចប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | 24 | 3.85 | ល្អ |
| ៣ | បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍ របស់សាលាបណ្តាញ | 24 | 4.20 | ល្អ |
| ៤ | ចែករំលែកធនធានសម្ភារៈ និងចំណេះដឹងដល់សាលាបណ្តាញ | 24 | 4.00 | ល្អ |
| ៥ | ត្រួតពិនិត្យជាប្រចាំនៃសម្ភារៈ ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | 24 | 3.90 | ល្អ |
| សរុប | | | 3.95 | ល្អ |

តាមតារាង៤.៤.៦បានបង្ហាញថាការគណនារកតម្លៃមធ្យមសរុបនៃសូចនាករទាំងប្រាំចំណុចដែលអ្នកស្រាវជ្រាវបានកំណត់សម្រាប់ប្រមូលទិន្នន័យពីគណៈគ្រប់គ្រងសាលារៀនបានបង្ហាញតម្លៃមធ្យមភាគ

សរុបគឺ Mean = 3.95 តម្លៃមធ្យមសរុបនេះបានបង្ហាញថា  ការអនុវត្តការងារភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់លោកនាយក/លោកស្រីនាយិកានៅសាលាមធ្យមសិក្សាធនធាន និងមធ្យមសិក្សាបណ្ដាញគឺទទួលបានកម្រិតល្អ ។ នៅក្នុងចំណោមសូចនាករទាំងប្រាំតាមការគណនារបស់អ្នកសិក្សាស្រាវជ្រាវបានបង្ហាញថាកម្រិតនៃការអនុវត្តភាគច្រើនគឺទទួលបានលទ្ធផលកម្រិតមធ្យមភាគល្អ ដូចទៅនឹងលទ្ធផលតម្លៃមធ្យមភាគសរុបផងដែរ។

៤.៤.៧  ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍

| ល.រ | **ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | បានអនុវត្តម៉ោងពិសោធន៍តាមកាលវិភាគថ្នាក់មុខវិជ្ជាគ្រប់គ្រាន់ | 24 | 3.80 | ល្អ |
| ២ | បានធ្វើដំណើរការពិសោធន៍តាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ | 24 | 3.50 | ល្អ |
| ៣ | បន្ទប់ពិសោធន៍មានសេចក្ដីណែនាំ ស្ដីពីនីតិវិធីសុវត្ថិភាពសម្ភារៈធ្វើពិសោធ | 24 | 3.30 | មធ្យម |
| ៤ | បន្ទប់ពិសោធន៍មានសម្ភារៈគ្រប់គ្រាន់សម្រាប់ពិសោធន៍តាមមេរៀននីមួយៗ | 24 | 2.60 | ខ្សោយ |
| ៥ | បន្ទប់ពិសោធន៍មានបរិយាកាសសិក្សាល្អ ធ្វើឲ្យសិស្សងាយស្រួលសិក្សា | 24 | 3.75 | ល្អ |
| ៦ | បានប្រើប្រាស់ចំណេះដឹងថ្មី លើការងារពិសោធន៍ | 24 | 3.35 | មធ្យម |
| ៧ | មានវិធីសាស្ត្របង្រៀនពិសោធន៍ដោយឡែក ពីការបង្រៀនក្នុងថ្នាក់ | 24 | 3.15 | មធ្យម |
| ៨ | បានប្រើអស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | 24 | 3.70 | ល្អ |

| | | | | |
|---|---|---|---|---|
| ៩ | គោរពតាមនីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ | 24 | 3.40 | មធ្យម |
| ១០ | សិស្សមានឆន្ទៈ និងចង់ស្វែងយល់នៃមេរៀនក្នុងម៉ោងពិសោធន៍ | 24 | 3.45 | ល្អ |
| សរុប | | | 3.10 | មធ្យម |

តាមតារាង៤.៤.៧បានបង្ហាញថាការគណនារកតម្លៃមធ្យមសរុបនៃសូចនាករទាំងដប់មួយចំណុច ដែលអ្នកស្រាវជ្រាវបានកំណត់សម្រាប់ប្រមូលទិន្នន័យពីគណៈគ្រប់គ្រងសាលារៀនបានបង្ហាញតម្លៃមធ្យមភាគសរុបគឺ Mean = 3.95 តម្លៃមធ្យមសរុបនេះបានបង្ហាញថា ការអនុវត្តការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ និងការងារភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់លោកនាយក/លោកស្រីនាយិកានៅសាលាមធ្យមសិក្សាធនជាន និងមធ្យមសិក្សាបណ្ដាញនៅខេត្តតាកែវ គឺទទួលបានកម្រិតមធ្យម ។ នៅក្នុងចំណោមសូចនាករទាំងដប់មួយតាមការគណនារបស់អ្នកសិក្សាស្រាវជ្រាវបានបង្ហាញថាកម្រិតនៃការអនុវត្តភាគច្រើនគឺទទួលបានលទ្ធផលកម្រិតមធ្យមភាគមធ្យម ដូចទៅនឹងលទ្ធផលតម្លៃមធ្យមភាគសរុបផងដែរ។ នៅក្នុងនោះមានតែសូចនាករតែមួយប៉ុណ្ណោះដែលមានកម្រិតមធ្យមភាគទាបបំផុតដែលមានតម្លៃ Mean= 2.60។

សរុមជារួមមកក្នុងសំណួរស្រាវជ្រាវទី (1) តើស្ថានភាពនៃការគ្រប់គ្រងសាលាមធ្យមសិក្សាធនជាន និងសាលាបណ្ដាញក្នុងខេត្តតាកែវយ៉ាងដូចម្ដេច?តាមរយៈលទ្ធផលកម្រងសំណួរ ចំពោះលោក/លោកស្រីដែលជាគណៈគ្រប់គ្រងសាលា ជាលទ្ធផលបានបង្ហាញថា ការអនុវត្តការគ្រប់គ្រងរបស់នាយក/នាយិកាសាលា ចំពោះស្ថានភាពនៃការគ្រប់គ្រងសាលាធនជាន និងសាលាបណ្ដាញក្នុងខេត្តតាកែវបានអនុវត្តការគ្រប់គ្រង ទាំង៧ចំណុចសំខាន់គឺ ១) វត្ថុបំណងគោលនយោបាយរបស់សាលារៀន ២)ការគ្រប់គ្រងបន្ទប់ពិសោធន៍ ៣) ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ ៤) ការគ្រប់គ្រងបណ្ណាល័យ ៥) កិច្ចគាំទ្រការបង្រៀន និងរៀន ៦).កិច្ចសហប្រតិបត្តិការ ៧).ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ អ្នកស្រាវជ្រាវ

បានរកឃើញថា នាយក/នាយិកាសាលាអនុវត្តភាគច្រើនទទួលបានលទ្ធផលល្អ គឺមានតែសកម្មភាពមួយចំនួនតូចប៉ុណ្ណោះដែលនាយក/នាយិកាសាលាមធ្យមសិក្សាធនធាន និងសាលាបណ្ដាញអនុវត្តបានត្រឹមតែ កម្រិតមធ្យម ។

## ៤.៥. លទ្ធផលនៃការពិនិត្យលើកម្រងសំណួរស្រាវជ្រាវទី១

ឆ្លងតាមការបកស្រាយលើសូចនាករតាមផ្នែកនីមួយៗដែលទទួលបានពីគ្រូបង្រៀន និងគណៈគ្រប់គ្រងសាលានៅក្នុងវិទ្យាល័យគោលដៅទាំង៨ក្នុងខេត្តតាកែវ អ្នកស្រាវជ្រាវបានលទ្ធផលដូចខាងក្រោម៖

តារាង៤.៥.១. ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញលើការបង្រៀននិងរៀនមុខវិជ្ជាថ្នាក់វិទ្យាសាស្ត្រ

| ល.រ | **ខ្លឹមសារ** | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍ | 60 | 3.08 | មធ្យម |
| ២ | ការគ្រប់គ្រង និងប្រើប្រាស់បណ្ណាល័យសិក្សា | 60 | 3.77 | ល្អ |
| ៣ | ការគ្រប់គ្រង និងប្រើប្រាស់សម្ភារបច្ចេកវិទ្យា | 60 | 3.23 | មធ្យម |
| ៤ | ការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល | 60 | 3.81 | ល្អ |
| ៥ | ការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស | 60 | 3.41 | ល្អ |
| ៦ | ការគ្រប់គ្រង និងប្រើប្រាស់ធនធានថវិកា | 60 | 3.80 | ល្អ |
| | សរុប | | 3.63 | ល្អ |
| | *គណៈគ្រប់គ្រងសាលា* | | | |

| ខ្លឹមសារ | | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | វត្ថុបំណងគោលនយោបាយរបស់សាលារៀន | 24 | 2.91 | មធ្យម |
| ២ | ការគ្រប់គ្រងបន្ទប់ពិសោធន៍ | 24 | 3.55 | ល្អ |
| ៣ | ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ | 24 | 3.61 | ល្អ |
| ៤ | ការគ្រប់គ្រងបណ្ណាល័យ | 24 | 3.55 | ល្អ |
| ៥ | កិច្ចគាំទ្រការបង្រៀន និងរៀន | 24 | 3.83 | ល្អ |
| ៦ | កិច្ចសហប្រតិបត្តិការ | 24 | 3.95 | ល្អ |
| ៧ | ការបងៀន និងរៀននៅបន្ទប់ពិសោធន៍ | 24 | 3.10 | មធ្យម |
| សរុប | | | 3.51 | ល្អ |

តាមតារាង៤.៥.១ លទ្ធផលនៃការគណនាលើកម្រងសំណួរដែលប្រមូលពីគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនថ្នាក់វិទ្យាសាស្ត្រនៅតាមវិទ្យាល័យគោលដៅទាំង៨បានបង្ហាញថា ការគ្រប់គ្រងសាលាធនជាន និងសាលាបណ្ដាញដោយផ្ដោតលើចំណុចគោលសំខាន់ៗទាំងអស់ខាងលើ បានបង្ហាញថា ការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍នៅសាលាមធ្យមសិក្សាធនជាននៅខេត្តតាកែវ ស្ថិតនៅកម្រិតមួយដែលអាចទទួលយកបានព្រោះតម្លៃ Mean=3.08 គឺនៅចំណុចទី(១)ការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍ ដែលមានកម្រិតមធ្យម មានបញ្ហាជាច្រើនដែលលោកគ្រូ/អ្នកគ្រូនៅសាលាធនជាន និងសាលាមណ្ឌាញ ព្រមទាំងបរិច្ចការីបន្ទប់ពិសោន៍ បានលើកឡើងអំពីបញ្ហាជាច្រើនដែលស្រដៀងគ្នាអំពីការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍ ដែលពួកគាត់បានលើកឡើងថា សម្ភារៈសម្រាប់ធ្វើពិសោធន៍ភាគច្រើកពួកគាត់មិនស្គាល់ និងមិនចេះប្រើប្រាស់ និងចំណុចទី(៣)ការគ្រប់គ្រង និងប្រើ ប្រាស់សម្ភារបច្ចេកវិទ្យាមានកម្រិតមធ្យមដោយមានកម្រិតមធ្យមភាគ Mean=3.23។ បើយោងទៅលើទិន្នន័យដែលទទួលបានចំពោះទស្សនៈលើការគ្រប់គ្រងសាលាធនជាន និងសាលាមណ្ឌាញដោយផ្ដោតលើចំណុចគោលសំខា

ន់ៗទាំអស់ខាងលើនេះមានដូចជា៖ ផ្នែកការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍ ផ្នែកការគ្រប់គ្រង និងប្រើប្រាស់បណ្ណាល័យ ផ្នែកការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល ផ្នែកការគ្រប់គ្រង និងការប្រើប្រាស់សម្ភារបច្ចេកវិទ្យា ផ្នែកការគ្រប់គ្រង ការប្រើប្រាស់ធនធានមនុស្ស និងការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកា។ក្នុងចំណោមសូចនាករទាំង៦នេះ អ្នកស្រាវជ្រាវយល់ឃើញថាមានសូចចនាករចំនួនពីរ ដែលស្ថិនៅក្នុងកម្រិតមធ្យមភាគទាបជាងគេក្នុងចំណោមសូចនាករទាំង៥ខាងលើនេះ។ ជាក់ស្តែងនៅតាមវិទ្យាល័យនៅតាមវិទ្យាល័យគោលដៅទាំង៨ក្នុងខេត្តតកែវ  បានបង្ហាញថាបច្ចេកវិទ្យាក្នុងដំណើរការបង្រៀន និងរៀន មិនសូវសំបូរបែបនោះទេ ពេលគឺខ្វះខាតច្រើន ទាក់ទងនឹងបន្ទប់សម្រាប់ដំណើរការពិសោធ សម្ភារៈសម្រាប់ធ្វើពិសោធន៍ និងការបង្រៀនដោយការប្រើប្រាស់បច្ចេកវិទ្យាទំនើបដូចជាការប្រើប្រាស់ LCD កុំព្យូទ័រ ការបង្រៀនដោយការប្រើប្រាស់ស្លាយ ក្នុងដំណើរការបង្រៀន។ ជាពិសេសគណៈគ្រប់គ្រង និងលោកគ្រូ/អ្នកគ្រូ នៅសាលាណ្ដាញភាគច្រើន បានលើកឡើងថា សាលាមានបញ្ហាលំបាកក្នុងការដឹកនាំ សិស្សថ្នាក់វិទ្យាសាស្ត្រ មកធ្វើការពិសោធនៅសាលាធនធាន ដូចជា បញ្ហាថវិកា មធ្យោយបាយក្នុងការធ្វើដំណើរ និងពេលវេលាជាដើម។

## ៤.៦. បញ្ហាលំបាក និងបញ្ហាប្រឈមរបស់គណៈគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញ

អ្នកស្រាវជ្រាវបានប្រើកម្រងសំណួរបែបគុណវិស័យ ជាកម្រងសំណួរស្រាវជ្រាវសម្រាប់លោកនាយក/លោកស្រីនាយិកា លោកនាយក/លោកស្រីនាយិការងទទួលបន្ទុកបច្ចេកទេស និងបរិច្ឆការីបន្ទប់ពិសោធន៍ដែលមានសេចក្ដីថា“តើលោក/លោកស្រីមានបញ្ហាប្រឈមអ្វីខ្លះក្នុងការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញ ?” ចំពោះសំណួរស្រាវជ្រាវមួយនេះគណៈគ្រប់គ្រងសាលារៀន ក៏ដូចជាបរិច្ឆការីបន្ទប់ពិសោធន៍ដោយផ្ដោតយកចិត្តទុកដាក់យ៉ាងសំខាន់សំដៅលើបញ្ហាប្រឈម និងជួបបញ្ហាលំបាកក្នុងការដឹកនាំដំណើរការបន្ទប់ពិសោធន៍នៅក្នុងអគារធនធានរបស់សាលាធនធាន ចំណែកគណៈគ្រប់គ្រង

សាលាបណ្ដាញក៏បានលើកឡើងនូវការជួបប្រទះបញ្ហាលំបាក និងប្រញ្ហាប្រឈមដែលទាក់ទងទៅនឹងការដឹកនាំដំណើរការបន្ទប់ពិសោធន៍ដូចគ្នានឹងគណៈគ្រប់គ្រងសាលាធនធានផងដែរ។

បញ្ហាលំបាក និងបញ្ហាប្រឈមក្នុងការគ្រប់គ្រងសាលាធាន និងសាលាបណ្ដាញមានដូចជា៖

❖ **បញ្ហាលំបាក**

- បញ្ហាលំបាកក្នុងការរៀបចំកាលវិភាគក្នុងការធ្វើពិសោធនៅបន្ទប់ពិសោធន៍នៅក្នុងអគារធនធាននៃសាលាធនធានព្រោះមានសាលាបណ្ដាញច្រើនដែលត្រូវដឹកនាំសិស្សមកធ្វើពិសោធនៅក្នុងបន្ទប់ពិសោធន៍ដោយសារមានបន្ទប់ពិសោធន៍តែមួយ
- បញ្ហាលំបាកក្នុងការទំនាក់ទំនងរវាងសាលាធនធាន និងសាលាបណ្ដាញដើម្បីសហការគ្នាក្នុងការធ្វើពិសោធដោយសាលាបណ្ដាញមួយចំនួននៅឆ្ងាយពីសាលាធនធាន ជាពិសេសបញ្ហាដោះស្រាយចំពោះមធ្យោយក្នុងការធ្វើដំណើរ
- បញ្ហាលំបាកក្នុងក្នុងការគ្រប់គ្រប់គ្រង និងការរៀបចំទុកដាក់សម្ភារៈពិសោធន៍ និងសារជាតុគីមីសម្រាប់ធ្វើពិសោធ
- បញ្ហាលំបាកក្នុងរកទិញសារជាតុគីមីសម្រាប់ធ្វើពិសោធ និងសម្ភារៈពិសោធន៍
- បញ្ហាលំបាកក្នុងការរកកន្លែងជួសជុលឧបករណ៍ពិសោធន៍នៅពេលដែលឧបករណ៍ទាំងនោះខូច
- បញ្ហាលំបាកក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍នៅពេលដែលដាច់ភ្លើងម្ដងៗព្រោះនៅពេលខ្លះប្រព័ន្ធអគ្គិសនីមិនអាចដំណើរការបាន(ដាច់ភ្លើង)និងសាលាមិនមានម៉ាស៊ីនភ្លើងសម្រាប់ជំនួយនៅពេលដែលភ្លើងដាច់ម្ដងៗ
- បញ្ហាលំបាកក្នុងការប្រើប្រាស់បន្ទប់កុំព្យូទ័រដោយសារមានកុំព្យូទ័រមិនគ្រប់គ្រាប់សម្រាប់សិស្សប្រើប្រាស់

- បញ្ហាលំបាកក្នុងការរកកន្លែងជួសជុសនៅពេលដែលកុំព្យូទ័រខូចម្តងៗ ដោយសាលាមិនមានគ្រូជំនាញជួសជុលកុំព្យូទ័រច្បាស់លាស់
- បញ្ហាលំបាកក្នុងការគ្រប់គ្រងសិស្សនៅពេលសិស្សចូលប្រើប្រាស់បន្ទប់កុំព្យូទ័រដោយសារខ្វះគ្រូជំនាញកុំព្យូទ័រដែលមានសមត្ថភាពគ្រប់គ្រាន់និងច្បាស់លាស់
- បញ្ហាលំក្នុងការបែងចែកកាលវិភាគសិស្សដើម្បីទទួលបានឱកាសក្នុងការប្រើប្រាស់បន្ទប់កុំព្យូទ័រ(មានចំនួនសិស្សច្រើន ប៉ុន្តែមានកុំព្យូទ័រតិចតួចដែលមិនគ្រប់គ្រាន់ក្នុងការប្រើប្រាស់)
- បញ្ហាលំបាកសម្រាប់សិស្សក្នុងសិក្សាស្រាវជ្រាវពីព្រោះបណ្ណាល័យមិនមានសៀវភៅសិក្សាគោលគ្រប់គ្រាន់សម្រាប់សិស្សដើម្បីខ្ចីយកទៅរៀន និងសិក្សាស្រាវជ្រាវបន្ថែមនៅផ្ទះរៀងៗខ្លួន
- បញ្ហាលំបាកក្នុងការបែងចែកគ្រូក្នុងការដឹកនាំសិស្សមកធ្វើពិសោធនៅក្នុងអគារធនធាននៃសាលាមធ្យមសិក្សាធនធានដោយសារភាពខ្វះខាតគ្រូដែលមានជំនាញឯកទេសខាងបន្ទប់ពិសោធន៍។

❖ **បញ្ហាប្រឈម**

- ការដឹកនាំសិស្សមកធ្វើពិសោធរបស់របស់សាលាបណ្តាញមកប្រើប្រាស់បន្ទប់ពិសោធន៍នៅក្នុងអគារធនធននៃសាលាមធ្យមសិក្សាធនធានម្តងៗអាចជួបបញ្ហាគ្រោះថ្នាក់ផ្សេងៗព្រោះមិនមានសុវត្ថិភាពក្នុងការធ្វើដំណើរដោយសារមានយានជំនិះតិចតួច និងមានចំនួនសិស្សច្រើន
- បញ្ហាខ្វះគ្រូបង្រៀនជំនាញឯកទេសខាងផ្នែកធ្វើពិសោធ
- បញ្ហាខ្វះគ្រូជំនាញឯកទេសខាងផ្នែកបច្ចេកវិទ្យា
- គ្រូបង្រៀនថ្នាក់មុខវិជ្ជាវិទ្យាសាស្ត្រមិនមានការចូលរួមឲ្យបានល្អប្រសើរជាមួយអ្នកទទួលបន្ទុកបន្ទប់ពិសោធន៍

- កង្វះថវិកាក្នុងការដំណើរការនៃអគារធនធាន
- កង្វះថវិកាក្នុងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ
- សមត្ថភាពចំណេះដឹងរបស់គ្រូបង្រៀនក្នុងការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យានៅមានកម្រិតនៅឡើយ
- ពិបាកក្នុងការរកទិញសម្ភារៈពិសោធន៍ ជាពិសេសសារធាតុគីមីតែម្តង
- កង្វះគ្រូឯកទេស ជាពិសេសគ្រូឯកទេសកាន់បន្ទប់ពិសោធន៍តែម្តង គឺលោកគ្រូ/អ្នកគ្រូមិនចង់កាន់បន្ទប់ពិសោធន៍
- ពិបាកក្នុងការជ្រើសរើសគ្រូចូលកាន់បន្ទប់ពិសោធន៍
- លោកគ្រូ អ្នកគ្រូមួយចំនួនមិនស្គាល់ឧបករណ៍ពិសោធន៍ ហើយសម្ភារៈឬឧបករណ៍ដែលខូចពិបាករកកន្លែងជួសជុលឬទិញថ្មីមិនដឹងជារកកន្លែងទិញនៅឯណា ពោលគឺពិបាកក្នុងការរកទិញសម្ភារៈពិសោធន៍ ជាពិសេសសារធាតុគីមីតែម្តង
- គ្មានគ្រូជំនាញឬអ្នកបច្ចេកទេសផ្នែកបន្ទប់ពិសោធន៍ ពីព្រោះអ្នកកាន់បន្ទប់ពិសោធន៍មានការផ្លាស់ប្តូរគ្នាកាន់ជាញឹកញាប់ និងមិនបានបណ្តុះបណ្តាលទៀត
- កង្វះការចូលរួមពីគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ មានន័យថា លោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រគាត់មានជំនាញផ្នែកពិសោធន៍ ប៉ុន្តែគាត់មិនសហការជាមួយបរិច្ឆការីទេ នៅពេលដែលបរិច្ឆការីមិនចេះប្រើប្រាស់ឧបករណ៍ពិសោធន៍នោះ
- គ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រមួយចំនួនមិនចេះប្រើប្រាស់ឧបករណ៍ពិសោធន៍ ហើយសម្ភារៈពិសោធន៍មួយចំនួនមិនស្គាល់ និងមិនចេះប្រើប្រាស់
- អ្នកទទួលបន្ទុកបន្ទប់ពិសោធន៍មិនមានគ្រប់គ្រាប់តាមកាលវិភាគថ្នាក់
- សមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀនលើផ្នែកពិសោធន៍នៅមានកម្រិត
- គ្រូបង្រៀន ទទួលបានការបណ្តុះបណ្តាលតិចតួច ស្តីពីការប្រើប្រាស់បន្ទប់ពិសោធន៍តាមឯកទេស។

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ឆ្លងតាមរយៈទិន្ន័យ ដែលបានមកពីការវិភាគលើកម្រងសំណួរដែលទាក់ទងទៅនឹងគោលគំនិតសំខាន់ៗរបស់ប្រធានបទ "ស្ថានភាពនៃ**ការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ**" អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថា ការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញ ដែលផ្តោតលើគោលគំនិតសំខាន់ៗមានដូចជា៖ ការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៦ ការគ្រប់គ្រង និងការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យ ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារបច្ចេកវិទ្យា ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោល ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស ការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកា ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ កិច្ចគាំទ្រការបង្រៀន កិច្ចសហប្រតិបត្តិការ និងការលើកទឹកចិត្ត នៅវិទ្យាល័យគោលដៅទាំង៨(ដែលមានសាលាមធ្យមសិក្សាធនធានចំនួន២ និងសាលាមធ្យមសិក្សាបណ្តាញចំនួន៦) គឺតម្លៃពន្ធុសរុបរួមលើផ្នែកទាំងនេះមានតម្លៃMean=3.31ទទួលបានកម្រិតមធ្យមភាគមធ្យម។ ដូចនេះអ្នកស្រាវជ្រាវអាចវាយតម្លៃបានថា ការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញ ដែលអ្នកស្រាវជ្រាវផ្តោតសំខាន់ទៅការគ្រប់គ្រង និងការប្រើប្រាស់ធនធានអប់រំនៅមានភាពខ្វះចន្លោះច្រើនទៅតាមផ្នែកនីមួយៗខាងលើដែលជាហេតុនាំឲ្យមានផលប៉ះពាល់ដល់ផ្នែកភាពជាអ្នកដឹកនាំ ការគ្រប់គ្រង និងគុណភាអប់រំ។រីឯតាមគោលគំនិតសំខាន់ៗនីមួយៗ អ្នកស្រាវជ្រាវអាចសន្និដ្ឋាន និងវាយតម្លៃតាមគោលគំនិតទាំងនោះដូចខាងក្រោម៖

### ៥.១.១. សេចក្តីសន្និដ្ឋានលើសំណួរស្រាវជ្រាវទី១

តារាង៥.១.១.១. ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញនៅខេត្តតាកែវ

| ល.រ | ខ្លឹមសារ | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍ | 60 | 3.08 | មធ្យម |
| ២ | ការគ្រប់គ្រង និងប្រើប្រាស់បណ្ណាល័យសិក្សា | 60 | 3.77 | ល្អ |
| ៣ | ការគ្រប់គ្រង និងប្រើប្រាស់សម្ភារបច្ចេកវិទ្យា | 60 | 3.23 | មធ្យម |
| ៤ | ការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល | 60 | 3.81 | ល្អ |
| ៥ | ការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស | 60 | 3.41 | ល្អ |
| ៦ | ការគ្រប់គ្រង និងប្រើប្រាស់ធនធានថវិកា | 60 | 3.80 | ល្អ |
| | សរុប | | 3.63 | ល្អ |

ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍ ចំណុចនេះឃើញថាការអនុវត្តទទួលបានកម្រិតតម្លៃពិន្ទុរួម Mean=308 ទទួលបានមធ្យមភាគកម្រិតមធ្យម នេះសបញ្ជាក់ថាការគ្រប់គ្រង និងការប្រើប្រាស់បន្ទប់ពិសោធន៍នៅមានកម្រិតនៅឡើយ ពីព្រោះលោកគ្រូ/អ្នកគ្រូក៏ដូចជាបរិច្ចការីបន្ទប់ពិសោធន៍មិនទាន់ស្គាល់ឈ្មោះអស់ និងមិនចេះប្រើប្រាស់ឧបករណ៍ពិសោធន៍។សម្ភារៈសម្រាប់ធ្វើពិសោធមួយចំនួនមិនអាចដំណើរការ( ប្រើមិនកើត )។ ម្យ៉ាងទៀតនៅក្នុងបន្ទប់ពិសោធន៍មិនមានសម្ភារៈសម្រាប់ធ្វើពិសោធគ្រប់គ្រាន់។

ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សា កម្រិតអនុត្តលើចំណុចនេះមានតម្លៃពិន្ទុ Mean=3.77 ទទួលបានកម្រិតមធ្យមភាគកម្រិតល្អ ដូច្នេះបានបង្ហាញថា ការគ្រប់គ្រងបណ្ណាល័យ មានលក្ខណៈល្អប្រសើរច្រើន បណ្ណាល័យមានបន្ទប់ធំទូលាយ ខ្យល់អាកាសចេញចូល និងមានពន្លឺគ្រប់គ្រាន់ បង្កភាពងាយស្រួលក្នុងការចូលស្វ័យសិក្សា ម៉្យាងទៀតបណ្ណារក្សយកចិត្តទុកដាក់ចំពោះសិស្ស មានភាពរួសរាយរាក់ទាក់ និងសម្រួលដល់សិស្សក្នុងការស្វែងរកសៀវភៅសិក្សាជាដើម។

ផ្នែកការគ្រប់គ្រង និងប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា មានតម្លៃពិន្ទុសរុបរួម Mean=3.23 ទទួលបានកម្រិតមធ្យមភាគកម្រិតមធ្យម តាមទិន្នន័យនេះអាចវាយតម្លៃបានថា សម្ភារបច្ចេកវិទ្យាសម្រាប់ដំណើរការបង្រៀន និងរៀននៅតាមវិទ្យាល័យគោលដៅទាំង៨នេះមានចំនួនតិចតួចណាស់ ឬស្ទើតែគ្មាន លើកលែងតែសាលាមធ្យមសិក្សាធនធានទាំងពីរប៉ុណ្ណោះដែលមានសម្ភារបច្ចេកវិទ្យា ដូចជាកុំព្យូទ័រ ស្លាយជាដើម...។

ផ្នែកការគ្រប់គ្រង និងប្រើប្រាស់សៀវភៅសិក្សាគោល មានតម្លៃពិន្ទុសរុបរួម Mean=3.81 ទទួលបានកម្រិតមធ្យមភាគល្អក្រោយទទួលបានលទ្ធផលកម្រិតល្អបែបនេះ ប៉ុន្តែនៅតែមានចំណុចខ្វះខាតជាច្រើនទៀតចពោះ ផ្នែកការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោលដូចជា សៀវភៅសិក្សាគោលមុខវិជ្ជាមួយចំនួនមានមិនគ្រប់គ្រាន់ជាមួយនឹងបរិមាណសិស្ស ហើយសៀវភៅសិក្សាគោលខ្លះទៀតមានសភាពចាស់ រហែក បាត់ទំព័រមួយចំនួន ដែលនាំឲ្យមានការពិបាកក្នុងការរៀនសូត្រ ចំណែកសៀវភៅសិក្សាគោលថ្មីៗមានចំនួនតិចតួចណាស់សម្រាប់គ្រូ និងសិស្សក្នុងការសិក្សាស្រាវជ្រាវ។

ផ្នែកការគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស មានតម្លៃពន្ទុមធ្យមភាគសរុបរួម Mean=4.41 ទទួលបានកម្រិតមធ្យមភាគល្អនៅក្នុងសូចនាករនេះ ទោះបីជាសូចនាករមានកម្រិតល្អក៏ដោយនៅតែមានចំណុចខ្វះខាតក៏ដូចជាចំណុចអសកម្មមួយចំនួនដែលគណៈគ្រប់គ្រងសាលារៀនមិនទាន់បំពេញនូវកាតព្វកិច្ចរបស់ខ្លួនបានល្អប្រសើរគ្រប់ជ្រុងជ្រោយនោះទេ មានចំណុចមួយចំនួនដូចជា លោកនាយក/លោកស្រីនាយិកាបែងចែកកលវិភាគមិនទាន់មានភាពស្មើគ្នានោះទេដែលជាហេតុបង្កឲ្យមានភាពមិនប្រក្រតី និងមានភាពលំអៀងរវាងបុគ្គលិកមួយចំនួនតូចនៅក្នុងអង្គភាពរបស់ខ្លួន។ លោកនាយក/លោកស្រីនាយិកាអនុញ្ញាតឲ្យគ្រូមួយចំនួនផ្ទេរចេញទោះបីលោក/លោកស្រីដឹងថាសាលារៀនរបស់ខ្លួនកំពុងតែខ្វះគ្រូក៏ដោយ ដែលជាហេតុធ្វើឲ្យការបំពេញតួនាទី និងទំនួលខុសត្រូវខ្ពស់ក្នុងនាមជាគណៈគ្រប់គ្រងសាលារៀនមិនទាន់ភាពច្បាស់លាស់ល្អប្រសើរ និងប្រាកដប្រជាក្នុងការងារគ្រប់គ្រង និងដឹកនាំនោះទេ។

ផ្នែកការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកា តាមរយៈអ្នកស្រាវជ្រាវចំពោះសូចនាករនេះបាន បញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថាតម្លៃមធ្យមភាគសរុបMean=3.80នៅក្នុងសូចនាករនេះបង្ហាញថាការ គ្រប់គ្រងនិងធនធានថវិការបស់សាលារៀនរបស់លោក/លោកស្រីគឺទទួលបានលទ្ធផលកម្រិតល្អ។ ទោះបីបើនៅក្នុងសូចនាករនេះទទួលបានកម្រិតល្អក៏ដោយក៏ប៉ុន្តែនៅតែមានចំណុចខ្វះខាតមួយចំនួនតូច ផងដែរ ដែលធ្លាប់បានកើតឡើងជារឿយក្នុងការបំពេញកាតព្វកិច្ចក្នុងនាមជាអ្នកដឹកនាំនិងគ្រប់គ្រងអង្គ ភាពទាំងមូលផងដែរ ដូចជាដំណើរការនៃការចាយវាយថវិកាសម្រាប់អភិវឌ្ឍន៍សាលារៀន មិនទាន់មាន តម្លាភាព យុត្តិធម៌ បើកចំហ និងមិនមានការប្រជុំផ្សព្វផ្សាយជាប្រចាំនោះទេ។

## ៥.១.២. សេចក្តីសន្និដ្ឋានលើសំណួរស្រាវជ្រាវទី១( គណៈគ្រប់គ្រងសាលា )

| ខ្លឹមសារ | | ចំនួន | មធ្យមភាគ | កម្រិត |
|---|---|---|---|---|
| ១ | វត្ថុបំណងគោលនយោបាយរបស់សាលារៀន | 24 | 2.91 | មធ្យម |
| ២ | ការគ្រប់គ្រងបន្ទប់ពិសោធន៍ | 24 | 3.55 | ល្អ |
| ៣ | ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ | 24 | 3.61 | ល្អ |
| ៤ | ការគ្រប់គ្រងបណ្ណាល័យ | 24 | 3.55 | ល្អ |
| ៥ | កិច្ចគាំទ្រការបង្រៀន និងរៀន | 24 | 3.83 | ល្អ |
| ៦ | កិច្ចសហប្រតិបត្តិការ | 24 | 3.95 | ល្អ |
| ៧ | ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ | 24 | 3.10 | មធ្យម |
| សរុប | | | 3.51 | ល្អ |

ផ្នែកវត្ថុបំណងគោលនយោបាយរបស់សាលារៀន ចំណុចនេះឃើញថាការអនុវត្តទទួលបានកម្រិតតម្លៃពិន្ទុ Mean=2.91ទទួលបានមធ្យមភាគកម្រិតមធ្យម នេះសបញ្ជាក់ថាវត្ថុបំណងគោលនយោបាយរបស់សាលារៀន នៅសាលាមធ្យមសិក្សាធនធាន និងសាលាបណ្ដាញនៅមានកម្រិតនៅឡើយ ពីព្រោះភាគរយនៃលទ្ធផលសិស្សប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានកម្រិតទាប ដែលជាបញ្ហាមួយចំពោះគុណភាពអប់រំនៅសាលាមធ្យមសិក្សាធនធាន និងសាលាមធ្យម និងវាក៏ជាការទទួលបន្ទុករបស់គណៈគ្រប់គ្រងសាលារៀន ក៏ដូចជាបុគ្គលិកគ្រប់ដែលទទួលការងារ និងជាអ្នកអនុវត្តជាក់ស្ដែងនៅក្នុងស្ថាប័នទាំងពីរនេះ។

ផ្នែកការគ្រប់គ្រងបន្ទប់ពិសោធន៍ កម្រិតអនុត្តលើចំណុចនេះមានតម្លៃពិន្ទុ Mean=3.55 ទទួលបានកម្រិតមធ្យមភាគកម្រិតល្អ ដូច្នេះបានបង្ហាញថា ការគ្រប់គ្រងបន្ទប់ពិសោធន៍ មានការបែងចែកបុគ្គលិកបំពេញការងារទៅតាមតួនាទីរៀងៗខ្លួន និងមានទំនួលខុសត្រូវខ្ពស់ ជាពិសេសការរៀបចំទុកដាក់សម្ភារៈសម្រាប់ធ្វើពិសោធ មានសណ្ដាប់ធ្នាប់និងមានរបៀបរៀបរយទៅតាមផ្នែកនីមួយៗត្រឹមត្រូវច្បាស់លាស់។

ផ្នែកការគ្រប់គ្រងបន្ទប់កុំព្យូទ័រ មានតម្លៃពិន្ទុសរុបរួម Mean=3.61 ទទួលបានកម្រិតមធ្យមភាគកម្រិតល្អតាមទិន្នន័យនេះអាចវាយតម្លៃបានថា ការគ្រប់គ្រងនៅក្នុងបន្ទប់កុំព្យូទ័រមានអ្នកបច្ចេកទេសខាងព័ត៌មានវិទ្យាពិនិត្យ និងតាមដានក្នុងការប្រើប្រាស់ម្ភារបច្ចេកវិទ្យាសម្រាប់ដំណើរការបង្រៀនមានទំនួលខុសត្រូវខ្ពស់ ប៉ុន្តែក៏នៅតែមានចំណុចខ្វះខាតមួយចំនួនដែលជាបញ្ហាចោតនៅក្នុងផ្នែកនេះផងដែរ ដូចជាមានការយឺតយ៉ាងក្នុងរៀបចំ និងជួសជុលកុំព្យូរទ័រ នៅពេលដែលកុំព្យូទ័រណាដែលមិនអាចដំណើរការបាន។

ផ្នែកការគ្រប់គ្រងបណ្ណាល័យ មានតម្លៃមធ្យមភាគសរុប Mean=3.55ទទួលបានកម្រិតមធ្យមភាគល្អក្រោយទទួលបានលទ្ធផលកម្រិតល្អបែបនេះ ប៉ុន្តែនៅតែមានចំណុចខ្វះខាតជាច្រើនទៀតចពោះ

ផ្នែកការគ្រប់គ្រងបណ្ណាល័យដូចជាគណៈគ្រប់គ្រងសារៀនមិនមានការដាក់ស្នើសុំឲ្យបណ្ណារក្សមានការចូលរួមនឹងវគ្គបណ្តុះបណ្តាលនានាដែលទាក់ទងទៅនឹងការងារផ្នែកការគ្រប់គ្រងបណ្ណាល័យ។

ផ្នែកកិច្ចគាំទ្រការបង្រៀន និងរៀន មានតម្លៃមធ្យមភាគសរុប Mean=3.83ទទួលបានកម្រិតមធ្យមភាគល្អនៅក្នុងសូចនាករនេះ ទោះបីជាសូចនាករមានកម្រិតល្អក៏ដោយនៅតែមានចំណុចខ្វះខាតក៏ដូចជាចំណុចអសកម្មមួយចំនួនដែលគណៈគ្រប់គ្រងសាលារៀនមិនទាន់បំពេញនូវកាតព្វកិច្ចរបស់ខ្លួនបានល្អប្រសើរគ្រប់ជ្រុងជ្រោយនោះទេ មានចំណុចមួយចំនួនដូចជាលោកនាយក/លោកស្រីនាយិកាមិនទាន់មានការរៀបបែងចែកកាលវិភាគដើម្បីផ្តល់ឱកាសឱ្យសាលាបណ្តាញបាចចូលរួមធ្វើពិសោធគ្រប់គ្រាន់ និងមានការបែងចែកកាលវិភាគដើម្បីឱ្យសិស្សមានពេលវេលាគ្រប់គ្រាប់ក្នុងការចូលរួមធ្វើពិសោធ និងឱកាសទទួលបាននូវចំណេះដឹងថ្មីៗដែលទាក់ទងទៅនឹងបន្ទប់ពិសោធន៍នៅក្នុងអគារធនធាន នៃសាលាមធ្យមសិក្សាធនធាន។

ផ្នែកកិច្ចសហប្រតិបត្តិការ តាមរយៈអ្នកស្រាវជ្រាវចំពោះសូចនាករនេះបានបញ្ជាក់ឲ្យឃើញយ៉ាងច្បាស់ថាតម្លៃមធ្យមភាគសរុប Mean=3.95 នៅក្នុងសូចនាករនេះបង្ហាញថាការគ្រប់គ្រងនិងដឹកនាំរបស់របស់លោក/លោកស្រីគឺទទួលបានលទ្ធផលកម្រិតល្អ។ ទោះបីបើនៅក្នុងសូចនាករនេះទទួលបានកម្រិតល្អក៏ដោយ ក៏ប៉ុន្តែនៅតែមានចំណុចខ្វះខាតមួយចំនួនតូចផងដែរ ដែលធ្លាប់បានកើតឡើងជារឿយក្នុងការបំពេញកាតព្វកិច្ចក្នុងនាមជាអ្នកដឹកនាំ និងគ្រប់គ្រងអង្គភាពទាំងមូលផងដែរដូចជាសាលាមធ្យមសិក្សាបណ្តាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន មិនទាន់មានកិច្ចសហប្រតិបត្តិការ និងការអនុវត្តការធ្វើពិសោធឲ្យបានផុលផុសនោះទេ ដែលមិនទាន់មានភាពរលូន និងទទួលបាននូវលទ្ធផលជោគជ័យគ្រប់ជ្រុងជ្រោយនោះទេ។

ផ្នែកការបង្រៀន និងរៀននៅបន្ទប់ពិសោធ៍ កម្រិតអនុវត្តលើសូចនាករនេះមានតម្លៃពិន្ទុ Mean=3.10 ទទួលបានកម្រិតមធ្យមភាគកម្រិតមធ្យម ទោះបីបើនៅក្នុងសូចនាករនេះទទួលបាននូវកម្រិតមធ្យមក៏ដោយ តែអាចបង្ហាញឲ្យឃើញថា ការបង្រៀន និងរៀននៅបន្ទប់ពិសោធន៍ មានការបែង

ចែកបុគ្គលិកបំពេញការងារទៅតាមតួនាទីរៀងៗខ្លួន និងមានទំនួលខុសត្រូវខ ជាពិសេសការរៀបចំទុកដាក់សម្ភារៈសម្រាប់ធ្វើពិសោធ មានសណ្តាប់ធ្នាប់និងមានរបៀបរៀបរយទៅតាមផ្នែកនីមួយៗត្រឹមត្រូវច្បាស់លាស់។សម្រាប់សិស្សចូលធ្វើពិសោធភាគច្រើនមានការចាប់ការចាប់អារម្មណ៍នឹងមេរៀនដែលពួកគេកំពុងសិក្សា និងទទួលបាននូវចំណេះដឹងថ្មីដល់ពួកគេផងដែរ។

### ៥.១.៣.សំណូមពរ

- គណៈគ្រប់គ្រងសាលាមធ្យមសិក្សាធនជានគួរមានសៀវភៅណែនាំកិច្ចតែងការធ្វើពិសោធ និងរបៀបធ្វើរបាយការពិសោធន៍ ព្រមទាំងសៀវភៅកត់ត្រាការចូលធ្វើពិសោធ
- គណៈគ្រប់គ្រងសាលាធនជាន និងសាលាបណ្តាញគួរមានទំនាក់គ្នាយ៉ាងជិតស្និត និងមានភាពល្អប្រសើរក្នុងការលើទឹកចិត្តគ្រូបង្រៀនថ្នាក់វិទ្យាសាស្ត្រក៏ដូចជាសិស្សឲ្យចូលចិត្តបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ
- គណៈគ្រប់គ្រងសាលាត្រូវពិនិត្យតាមដាន ការធ្វើពិសោធរបស់គ្រូតាមកាលវិភាគជាប្រាំ
- គណៈគ្រប់គ្រងសាលាគួរពង្រឹងយន្តការអនុវត្តក្នុងការប្រើប្រាស់បន្ទប់ពិសោធន៍វិទ្យាសាស្ត្ររបស់គ្រូនិងសិស្សឲ្យអស់លទ្ធភាព
- គណៈគ្រប់គ្រងសាលាធនជាន និងសាលាបណ្តាញត្រូវមានគោលជំហរច្បាស់លាស់ និងមានទំនួលខុសត្រូវខ្ពស់ចំពោះអគារធនជាន ដើម្បីឲ្យមានតម្លាភាព ប្រសិទ្ធភាពក្នុងការផ្តល់ចំណេះផ្នែកពិសោធន៍
- គណៈគ្រប់សាលាធនជាន និងសាលាបណ្តាញ ត្រូវជំរុញគ្រូដែលមិនធ្លាប់រៀនពិសោធ ឲ្យចូលរួមវគ្គបណ្តុះបណ្តាលឬសិក្ខាសាលានានាលើផ្នែកពិសោធន៍

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា(២០១៩)ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០ គោលដៅអភិវឌ្ឍន៍ប្រកដោយចីរភាពទី៤

ក្រសួងអប់រំ យុវជន និងកីឡា (២០០៨) គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធនរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨)ឯកសារស្តង់ដាសាលាមធ្យមសិក្សាធនធាន

ក្រសួង អប់រំយុវជន និងកីឡា (២០១១) សៀវភៅណែនាំប្រតិបត្តិសាលាមធ្យមសិក្សាធនធាន របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន ចុះថ្ងៃទី០២ខែឧសភា ឆ្នាំ២០០៨

សេចក្តីណែនាំលេខ២៦អយក.សណន ចុះថ្ងៃទី២០ខែតុលា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់លក្ខណៈសម្បត្តិ និងប្រើប្រាស់ថវិកាសម្រាប់ដំណើរការវិទ្យាល័យធនធាន

ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ(២០១១) បញ្ជីរាយនាមសាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញ ក្រោមគម្រោង EEQP

ក្រសួងអប់រំ យុវជន និងកីឡា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ (២០១៩)បញ្ជីរាយនាមសាលាមធ្យមសិក្សាធនធាន៥០ ក្រោមគម្រោងអភិវឌ្ឍវិស័យអប់រំមធ្យមសិក្សា ទុតិយភូមិទី២(USESDP2)

ក្រសួងអប់រំ យុវជន និងកីឡា ប្រកាសស្តីពី ការបង្កើតអគារធនធាន លេខ ៣២៧៧ អយក.ប្រក ចុះថ្ងៃទី៤ខែធ្នូឆ្នាំ២០១០

ក្រសួងអប់រំ យុវជន និងកីឡា ប្រកាសស្តីពី ការបង្កើតអគារធនធាន លេខ ២៥៩០ អយក.ប្រក ចុះថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០១១

ក្រសួងអប់រំ យុវជន និងកីឡា ប្រកាសស្តីពី ការបង្កើតអគារធនធាន លេខ ៦០៣ អយក.ប្រក ចុះថ្ងៃទី២២ខែកុម្ភៈ ឆ្នាំ២០១៣

ក្រសួងអប់រំ យុវជន និងកីឡា ប្រកាសស្តីពី ការបង្កើតអគារធនធាន លេខ ១០១០ អយក.ប្រក ចុះថ្ងៃទី២ខែឧសភា ឆ្នាំ២០១៤

ក្រសួងអប់ រំយុវជន និងកីឡា (២០១៩).  របាយការណ៍សន្និបាតបូកសរុបការងារអប់រំ ២០១៩-២០២០. រាជធានីភ្នំពេញ: ក្រសួងអប់ រំយុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៦).  កម្មវិធីសិក្សាគោលសម្រាប់អប់រំមូលដ្ឋានចំណេះទូទៅ.

រាជធានីភ្នំពេញ: ក្រសួងអប់ រំយុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (ខែធ្នូ ២០១៨). ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃសាលាមធ្យមសិក្សាធនធាន. រាជធានីភ្នំពេញ: ក្រសួងអប់ រំយុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦). ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់បំប៉ននាយកសាលាបឋមសិក្សា និងវិក្រឹតការ. រាជធានីភ្នំពេញ: ក្រសួងអប់ រំយុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៨). គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធានរបស់នាយកដ្ឋានមធ្យមសិក្សាចំណោះទូទៅខែឧសភា ឆ្នាំ២០០៨. រាជធានីភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩).ឯកសារយុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៩-២០២៣. រាជធានីភ្នំពេញ: ក្រសួងអប់ រំយុវជន និងកីឡា។

ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០(ខែកុម្ភៈឆ្នាំ២០១៩). ស្តីពីការអប់រំនៅកម្ពុជា. រាជធានីភ្នំពេញ: ក្រសួងអប់ រំយុវជន និងកីឡា។

វិទ្យាស្ថានជាតិអប់រំ(២០២០). ឯកសារស្តីពីការលើកកម្ពស់សមត្ថភាពគ្រប់គ្រង និងប្រើប្រាស់អគារធនធាន និងសាលាបណ្ដាញ. រាជធានីភ្នំពេញ: វិទ្យាស្ថានជាតិអប់រំ(NIE)។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ កម្រងសំណួរស្រាវជ្រាវសម្រាប់គ្រូបង្រៀន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរស្រាវជ្រាវ

## សម្រាប់លោកគ្រូ/អ្នកគ្រូថ្នាក់វិទ្យាសាស្ត្រ

ខ្ញុំបាទឈ្មោះស៊ុំ សុខឿន ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ឆ្នាំសិក្សា ២០១៩-២០២១ នៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរនិក្ខេបបទបញ្ចប់ការសិក្សាលើប្រធានបទ" ការគ្រប់គ្រងសាលាធនជាន និងសាលាបណ្ដាញ"។ ក្នុងការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទប្រមូលទិន្នន័យពីសាលាមធ្យមសិក្សាធនជាន និងសាលាបណ្ដាញ ដែលមានភូមិសាស្ត្រស្ថិតនៅក្នុងខេត្តតាកែវ។ ការសិក្សាស្រាវជ្រាវនេះ មានបំណងស្វែងរកទិន្នន័យដើម្បីឆ្លើយតបទៅលើ ការគ្រប់គ្រងសាលាធនជាន និងសាលាបណ្ដាញដែលបានជម្រាបជូនខាងលើ។

អាស្រ័យហេតុនេះ សូមលោកនាយក/នាយករង និងបរិច្ឆការី មេត្តាចូលរួមផ្ដល់ទិន្នន័យក្នុងការសិក្សារបស់ខ្ញុំបាទដោយក្ដីអនុគ្រោះ។ ការចូលរួមផ្ដល់ព័ត៌មាននេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការសិក្សារបស់ខ្ញុំបាទទៅលើប្រធានបទខាងលើ។ ខ្ញុំបាទសូមធានាថា ទិន្នន័យដែលទទួលបានគឺរក្សាទុកជាការសម្ងាត់ និងត្រូវយកមកប្រើប្រាស់ក្នុងការវិភាគ សម្រាប់តែការសិក្សាស្រាវជ្រាវ សរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់ខ្ញុំបាទតែប៉ុណ្ណោះ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោកគ្រូ/អ្នកគ្រូ

# កម្រងសំណួរសម្រាប់គ្រូបង្រៀន

## ផ្នែកទី១៖ អំពីព័ត៌មានផ្ទាល់ខ្លួន

១.ឈ្មោះ៖ ..........................................................................................................

២. ភេទ៖ □ប្រុស □ ស្រី

៣. គ្រូបង្រៀនមុខវិជ្ជា៖..................................................................................................

៤.វិទ្យាល័យ៖..........................................................................................................

៥.ស្រុក៖...............................................................................................................

៦. កម្រិតវប្បធម៌

□ មធ្យមសិក្សាទុតិយភូមិ

□ បរិញ្ញាបត្រ

□ បរិញ្ញាបត្រជាន់ខ្ពស់

□បណ្ឌិត

៧. បទពិសោធន៍បម្រើការងារក្នុងវិស័យអប់រំ

□តិចជាង៥ឆ្នាំ

□ ពី៥ដល់៩ឆ្នាំ

□ លើសពី៩ឆ្នាំ

## ផ្នែកទី២៖ អំពីស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្តាញលើផ្នែកអប់រំវិទ្យាសាស្ត្រ

សូមលោកគ្រូ អ្នកគ្រូគូសសញ្ញា(✓) ក្នុងកូឡោនមួយតាមការពន្យល់ដូចខាងក្រោម៖

- "ល្អណាស់" មានន័យថាការអនុវត្តតាមខ្លឹមសារ ឬគោលគំនិតបានច្រើនបំផុត ឬជាប្រចាំគ្រប់ពេល ពោលគឺក្នុងកម្រិតពី៩០%-១០០%
- "ល្អ" មានន័យថាការអនុវត្តខ្លឹមសារ ឬគោលគំនិតនោះបានច្រើន ឬស្ទើរតែគ្រប់ពេល ពោលគឺក្នុងកម្រិតពី៦០%-៩០%
- "មធ្យម" មានន័យថាការអនុវត្តខ្លឹមសារ ឬគោលគំនិតនោះបានមធ្យម បានអនុវត្តខ្លះ ឬមិនបានអនុវត្តខ្លះពោលគឺក្នុងកម្រិតពី៤០%-៦០%

- "ខ្សោយ" មានន័យថាការអនុវត្តខ្លឹមសារ ឬគោលគំនិតនោះបានតិច ឬអនុវត្តម្តងកាល ពោលគឺក្នុងកម្រិតពី ១០%-៤០%
- "ខ្សោយណាស់" មានន័យថាការអនុវត្តខ្លឹមសារ ឬគោលគំនិតនោះបានតិចបំផុត ឬមិនដែលបានអនុវត្តទាល់តែសោះ ពោលគឺក្នុងកម្រិតពី ០%-១០%

| | | កម្រិតនៃអនុវត្ត | | | | |
|---|---|---|---|---|---|---|
| **ល.រ** | **សំណួរ** | ល្អណាស់ | ល្អ | មធ្យម | ខ្សោយ | ខ្សោយណាស់ |
| ***ក.ការគ្រប់គ្រង និងប្រើប្រាស់បន្ទប់ពិសោធន៍*** | | | | | | |
| ១ | លោកគ្រូ អ្នកគ្រូង្រៀនតាមមុខវិជ្ជាចេះប្រើប្រាស់ឧបករណ៍សម្រាប់ធ្វើការពិសោធ | | | | | |
| ២ | បន្ទប់ពិសោធមានលក្ខណៈស្តង់ការ ធំទូលាយ និងមានសម្ភារៈបច្ចេកវិទ្យា ទំនើបៗ និងមានសម្ភារៈសម្រាប់ធ្វើការពិសោធគ្រប់គ្រាន់ | | | | | |
| ៣ | មានអ្នកជំនាញក្នុងការជួយសម្រួលការងារដល់លោកគ្រូ អ្នកគ្រូក្នុងការប្រើប្រាស់ឧបករណ៍សម្រាប់ធ្វើការពិសោធ | | | | | |
| ៤ | លោកគ្រូ អ្នកគ្រូមានការបែងចែកពេលវេលាគ្របគ្រាន់ក្នុងការធ្វើពិសោធទៅតាមមុខវិជ្ជា | | | | | |
| ៥ | លោកគ្រូ អ្នកគ្រូយល់ឃើញថាអគារជានធនក៏ដូចជាបន្ទប់ពិសោធផ្សេងៗទៀតជួយបង្កើនចំណេះដឹងបន្ថែមដល់សិស្ស | | | | | |
| ៦ | លោកគ្រូ អ្នកគ្រូសង្កេតឃើញថាសិស្សានុសិស្ស ចូលចិត្តម៉ោងពិសោធដែលទាក់ទងទៅនឹងមេរៀនរបស់ពួកគេ | | | | | |
| ៧ | លោកគ្រូ អ្នកគ្រូមានចូលរួមក្នុងការថែរក្សាសម្ភារៈ និងឧបករណ៍ពិសោធឲ្យបានល្អគង់វង្ស | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៨ | លោកគ្រូ អ្នកគ្រូមានគនិតឆ្នៃប្រឌិតខ្ពស់ក្នុងការអភិវឌ្ឍ និងកែប្រែបន្ទប់ពិសោធ ឲ្យបានរីកចម្រើន និងមានភាពល្អប្រសើរ | | | | | |
| ៩ | ការរៀបចំសម្ភារៈ និងឧបករណ៍សម្រាប់ធ្វើការពិសោធមានរបៀបរៀបរយ និងមានការបែងចែកប្រកបដោយមានលក្ខណៈត្រឹមត្រូវនិងច្បាស់លាស់ | | | | | |
| *ខ. ការគ្រប់គ្រង និងការប្រើប្រាស់បណ្ណាល័យសិក្សា* | | | | | | |
| ១០ | បណ្ណាល័យបានបើក និងបិទទ្វារទៀងទាត់ម៉ោង | | | | | |
| ១១ | បណ្ណាល័យមានសៀវភៅច្រើនសម្រាប់អាន និងសិក្សាស្រាវជ្រាវ | | | | | |
| ១២ | ការរៀបចំទុកដាក់សៀវភៅមានរបៀបរៀបរយ ទៅតាមកម្រិតថ្នាក់នីមួយៗ និងមានលក្ខណៈងាយស្រួលក្នុងការខ្ចីសៀវភៅ និងការអាន | | | | | |
| ១៣ | បណ្ណាល័យសិក្សាមានបន្ទប់ធំទូលាយ មានកន្លែងអង្គុយអានសៀវភៅ មានខ្យល់អាកាសចេញចូលល្អ និងមានពន្លឺគ្រប់គ្រាន់ | | | | | |
| ១៤ | លោកគ្រូ អ្នកគ្រូយល់ឃើញថាបណ្ណាល័យពិតជាមានសារៈសំខាន់និងចាំបាច់សម្រាប់ការសិក្សាស្រាវជ្រាវរបស់គ្រូបង្រៀន និងសិស្ស | | | | | |
| ១៥ | បណ្ណារក្សមានទំនួលខុសត្រូវខ្ពស់ចំពោះការងាររបស់គាត់ | | | | | |
| ១៦ | ការគ្រប់គ្រង និងការរៀបចំសម្ភារសិក្សា និងឯកសារផ្សេងៗនៅក្នុងបណ្ណាល័យមានរបៀបរៀបរយ និងមានសណ្ដាប់ធ្នាប់ល្អ | | | | | |
| ១៧ | លោកគ្រូ អ្នកគ្រូជួយជម្រុញ និងលើកទឹកចិត្តសិស្សឲ្យចូលរួមក្នុងការអានសៀវភៅក្នុងបណ្ណាល័យឲ្យបានច្រើន | | | | | |
| ១៨ | លោកគ្រូ អ្នកគ្រូមានគំនិតផ្ដួចផ្ដើមក្នុងការចូលរួមរកឯកសារសំខាន់ដែលមានអត្ថប្រយោជន៍ និងផ្ដល់ចំណេះដឹងបន្ថែមដល់សិស្ស | | | | | |
| ១៩ | លោកគ្រូ អ្នកគ្រូយល់ឃើញថាបណ្ណាល័យគឺជាឃ្លាំងចំណេះដឹងដ៏មានតម្លៃសម្រាប់អ្នកសិក្សាស្រាវជ្រាវ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| *គ.ការគ្រប់គ្រង និងការប្រើប្រាស់សម្ភារបច្ចេកវិទ្យា (ICT)* | | | | | | |
| ២០ | បន្ទប់បច្ចេកវិទ្យា (ICT) នៅក្នុងអគារធនធាន ធំទូលាយ មាន ខ្យល់អាកាសចេញចូល និងមានពន្លឺគ្រប់គ្រាន់ | | | | | |
| ២១ | នៅក្នុងបន្ទប់ពិសោធICT មានឧបករណ៍សម្រាប់ការធ្វើការ ពិសោធគ្រប់គ្រាន់ | | | | | |
| ២២ | គ្រូបង្រៀនកុំព្យូទ័រជំនាញឯកទេសខាង ICT ជាជំនួយដល់គ្រូ បង្រៀននៅក្នុងបន្ទប់ពិសោធ ICT | | | | | |
| ២៣ | នៅក្នុងបន្ទប់ ICT មានកុំព្យូទ័រគ្រប់គ្រាន់សម្រាប់ធ្វើការពិសោធ និងសិក្សាស្រាវជ្រាវ | | | | | |
| ២៤ | កុំព្យូទ័រនៅក្នុងបន្ទប់ពិសោធ ICT សុទ្ធតែអាចដំណើរការ និង ប្រើប្រាស់បាន | | | | | |
| ២៥ | លោកគ្រូ អ្នកគ្រូមានពេលវេលាគ្រប់គ្រាន់ក្នុងការសិក្សា ស្រាវជ្រាវបន្ថែមទៅលើប្រព័ន្ធបច្ចេកវិទ្យានៅក្នុងបន្ទប់ពិសោធ ICT | | | | | |
| ២៦ | លោកគ្រូ អ្នកគ្រូមានការគ្រប់គ្រងល្អ និងបែងចែកកាលវិភាគ ច្បាស់លាស់ក្នុងការប្រើប្រាស់បន្ទប់ពិសោធ ICT | | | | | |
| ២៧ | ការសិក្សាប្រព័ន្ធបច្ចេកវិទ្យាITC ផ្តោតលើ Microsoft Word, Excel &Power Point | | | | | |
| ២៨ | លោកគ្រូ អ្នកគ្រូយល់ឃើញថាបន្ទប់ ICT នៅក្នុងអគារធនធាន ពិតជាកន្លែងមួយយ៉ាងសំខាន់ក្នុងការផ្តល់ចំណេះដឹងដល់គ្រូ និងសិស្សដោយមិនអាចខ្វះបាននាពេលបច្ចុប្បន្ន និងនៅថ្ងៃ អនាគត | | | | | |
| *ឃ. ការគ្រប់គ្រង និងការប្រើប្រាស់សៀវភៅសិក្សាគោល* | | | | | | |
| ២៩ | មានសៀវភៅសិក្សាគោលមានគ្រប់គ្រាន់សម្រាប់សិស្សក្នុងការ សិក្សាទៅតាមមុខវិជ្ជានីមួយៗ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣០ | សៀវភៅសិក្សាគោលមានគុណប្រយោជន៍ និងជួយជំរុញដល់ការសិស្ស | | | | | |
| ៣១ | ការប្រគល់សៀវភៅសិក្សាគោលទៅសាលាវិញតាមការកំណត់កាលបរិច្ឆេតត្រឹមត្រូវ | | | | | |
| ៣២ | លោកគ្រូ អ្នកគ្រូគិតសិស្សទាំងអស់ចាំបាច់ត្រូវតែមានសៀវភៅសិក្សាគោលដោយមិនអានខ្វះបាន | | | | | |
| ៣៣ | លោកគ្រូ អ្នគ្រូជួយជម្រុញ និងលើកទឹកចិត្តសិស្សឲ្យចេះស្រឡាញ់ថែរក្សា និងសិក្សាស្រាវជ្រាវបន្ថែមពីសៀវភៅសិក្សាគោល | | | | | |
| | *ង. ការគ្រប់គ្រង និងការប្រើប្រាស់ធនធានមនុស្ស* | | | | | |
| ៣៤ | លោកនាយក/លោកស្រីនាយិកាបែងចែកកាលវិភាគបង្រៀនសម្រាប់លោកគ្រូ អ្នកគ្រូដោយស្មើភាពគ្នា | | | | | |
| ៣៥ | លោកនាយក/លោកស្រីនាយិកាអនុញាតឲ្យគ្រូផ្ទេរចេញទោះបីដឹងសាលារបស់ខ្លួនខ្វះគ្រូក៏ដោយ | | | | | |
| ៣៦ | លោកគ្រូ អ្នកគ្រូមកបង្រៀនទៀងទាត់ពេលវេលា | | | | | |
| ៣៧ | លោកនាយក/លោកស្រីនាយិការៀបចំចាត់ចែងកាលវិភាគ និងចាត់តាំងឲ្យគ្រូបង្រៀនតាមមុខវិជ្ជាត្រូវតាម ជំនាញ ឯកទេស និងមានទេពកោសល្យច្បាស់លាស់ក្នុងការបង្រៀន( ត្រូវតាមគុណវុឌ្ឍិគ្រូបង្រៀន ) | | | | | |
| ៣៨ | លោកនាយក/លោកស្រីនាយិកាធ្វើថ្នាក់និទស្សន៍ចំពោះគ្រូបង្រៀនទើបចេញថ្មី និងគ្រូមានបទពិសោធក្នុងការបង្រៀនច្រើនឆ្នាំយ៉ាងទៀងទាត់ | | | | | |
| ៣៩ | គ្រូបង្រៀនមួយចំនួនតូចមានឈ្មោះបម្រើការងារនៅក្នុងអង្គភាពប៉ុន្តែមិនមានវត្តមានក្នុងការបំពេញការងារទាល់តែសោះ( មានតែឈ្មោះ ) | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤០ | គ្រប់ការប្រជុំរួម និងប្រជុំក្រុមបច្ចេកទេស ឃើញថាលោកគ្រូ អ្នកគ្រូបានមកចូលរួមប្រជុំយ៉ាងទៀងទាត់ | | | | | |
| ៤១ | លោកនាយក/លោកស្រីនាយិកាយកចិត្តទុកដាក់ចំពោះគ្រូបង្រៀនដែលមកពីឆ្ងាយក្នុងការរៀបចំអន្តេវាសិកឲ្យស្នាក់នៅ | | | | | |
| ៤២ | សាលារៀនរបស់លោកគ្រូ អ្នកគ្រូ មានមុខវិជ្ជាមួយចំនួនលើសគ្រូ និងមុខវិជ្ជាមួយចំនួនទៀតខ្វះគ្រូ | | | | | |
| ៤៣ | លោកគ្រូ អ្នកគ្រូខ្លះមកបង្រៀនតែដើមឆ្នាំសិក្សា (គ្រូអសកម្មនឹងការងារ)ជាពិសេស គ្រូមុខវិជ្ជាអប់រំកាយ និងកីឡា | | | | | |
| ៤៤ | លោកគ្រូ អ្នកគ្រូមានបំណែងចែកកម្មវិធីសិក្សា និងបង្រៀនតាមកិច្ចតែងការត្រឹមត្រូវច្បាស់លាស់ | | | | | |
| ៤៥ | កិច្ចតែងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូបានកំណត់វត្ថុបំណងត្រឹមត្រូវច្បាស់ លាស់ និងក្តោមខ្លឹមសារមេរៀនទាំងស្រុង | | | | | |
| ៤៦ | លោកនាយក/លោកស្រីនាយិកាតែងតែលើកទឹកចិត្តបុគ្គលិកតាមរយៈពាក្យសំដី សម្ភារៈ ឬថវិការជាដើម | | | | | |
| ៤៧ | លោកនាយក/លោកស្រីនាយិកាតែងតែដាស់តឿន និងណែនាំដល់បុគ្គលិកណាដែលអសកម្មនឹងការងារ | | | | | |
| ៤៨ | បុគ្គលិកយកចិត្តទុកដាក់ចំពោះការផ្សព្វផ្សាយព័ត៌មាន សេចក្តីជូនដំណឹងថ្មីៗ ឬសេចក្តីណែនាំផ្សេងៗដែលទាក់ទងទៅនឹងដំណើរការបង្រៀននិងរៀនពីសំណាក់គណៈគ្រប់គ្រងសាលា | | | | | |
| *ច. ការគ្រប់គ្រង និងការប្រើប្រាស់ធនធានថវិកា* | | | | | | |
| ៤៩ | ដំណើរការនៃការចាយវាយថវិកាសម្រាប់ការអភិវឌ្ឍសាលារៀនមានតម្លាភាព យុត្តិធម៌ បើកចំហរ និងមានការប្រជុំផ្សព្វផ្សាយជាប្រចាំ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥០ | ថវិកាសម្រាប់ទ្រទ្រង់សាលារៀនត្រូវបានប្រើប្រាស់ចំទិសដៅក្នុងគោលគំនិតអភិវឌ្ឍន៍សាលា ក៏ដូចជាការកែលម្អបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធនានា | | | | | |
| ៥១ | លោកនាយក/លោកស្រីនាយិកាធ្វើការរៀបចំប្រជុំប្រចាំខែនីមួយៗ ដោយមានការផ្សព្វផ្សាយអំពីចំណូល និងខ្ទង់ចំណាយរបស់សាលារៀនតាមរយៈការបង្ហាញលើក្តាខៀនព័ត៌មាន ដោយមានវិក័យបត្របញ្ជាក់ពីការចំណាយ និងចំណូលផ្សេងៗ | | | | | |
| ៥២ | លោកនាយក/លោកស្រីនាយិកាបើកការប្រជុំក្រុមបច្ចេកទេសតាមត្រីមាសនីមួយៗយ៉ាងទៀងទាត់ | | | | | |
| ៥៣ | លោកនាយក/លោកស្រីនាយិកាគៀរគរថវិកាពីសប្បុរសជនសហគមន៍ មាតាបិតាសិស្សក្នុងការទ្រទ្រង់ និងអភិវឌ្ឍន៍សាលារៀន | | | | | |
| ៥៤ | ការចំណាយថវិការបស់សាលារៀនត្រូវឆ្លងកាត់ភាគីពាក់ព័ន្ធនានាដើម្បីសម្រេច | | | | | |
| ៥៥ | លោកនាយក/លោកស្រីនាយិកាប្រើប្រាស់ថវិកាតាមផែនការប្រចាំឆ្នាំ និងចំគោលដៅ | | | | | |
| ៥៦ | លោកនាយក/លោកស្រីនាយិកាខិតខំលះបង់កម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំ និងគ្រប់គ្រង | | | | | |

មតិយោបល់ និងសំណូមពរផ្សេងៗ៖

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

សូមអរគុណ

ឧបសម្ព័ន្ធទី២៖ កម្រងសំណួរស្រាវជ្រាវសម្រាប់គណៈគ្រប់គ្រងសាលារៀន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

## កម្រងសំណួរស្រាវជ្រាវ

## សម្រាប់នាយក/នាយករង និងបរិច្ឆការីបន្ទប់ពិសោធន៍

ខ្ញុំបាទឈ្មោះស៊ុំ សុខឿន ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ឆ្នាំសិក្សា ២០១៩-២០២១ នៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទកំពុងសរសេរនិក្ខេបបទបញ្ចប់ការសិក្សាលើប្រធានបទ" ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញលើផ្នែកអប់រំវិទ្យាសាស្ត្រនៅខេត្តតាកែវ"។ ក្នុងការសិក្សាស្រាវជ្រាវនេះ ខ្ញុំបាទប្រមូលទិន្នន័យពីសាលាមធ្យមសិក្សាធនធាន និងសាលាបណ្ដាញ ដែលមានភូមិសាស្ត្រស្ថិតនៅក្នុងខេត្តតាកែវ។ ការសិក្សាស្រាវជ្រាវនេះ មានបំណងស្វែងរកទិន្នន័យដើម្បីឆ្លើយតបទៅលើ ស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញលើផ្នែកអប់រំវិទ្យាសាស្ត្រ ដែលបានជម្រាបជូនខាងលើ។

អាស្រ័យហេតុនេះ សូមលោកនាយក/នាយករង និងបរិច្ឆការី មេត្តាចូលរួមផ្តល់ទិន្នន័យក្នុងការសិក្សារបស់ខ្ញុំបាទដោយក្តីអនុគ្រោះ។ ការចូលរួមផ្តល់ព័ត៌មាននេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់ការសិក្សារបស់ខ្ញុំបាទទៅលើប្រធានបទខាងលើ។ ខ្ញុំបាទសូមធានាថា ទិន្នន័យដែលទទួលបានគឺរក្សាទុកជាការសម្ងាត់ និងត្រូវយកមកប្រើប្រាស់ក្នុងការវិភាគ សម្រាប់តែការសិក្សាស្រាវជ្រាវ សរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់ខ្ញុំបាទតែប៉ុណ្ណោះ។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចូលរួមរបស់លោក/លោកស្រី។

# កម្រងសំណួរសម្រាប់គណៈគ្រប់គ្រង

## ផ្នែកទី១៖ អំពីព័ត៌មានផ្ទាល់ខ្លួន

១- ឈ្មោះ ៖.....................................................................................................

២- តួនាទី ៖ □ នាយក ឬ□នាយិកា □នាយករង ឬ□នាយិការង □បរិច្ឆការី

ទទួលបន្ទុក៖ ......................................................................................

៣- សាលា ៖.....................................................................................................

៤- ស្រុក/ក្រុង៖.................................................................................................

## ផ្នែកទី២៖ អំពីស្ថានភាពនៃការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញលើផ្នែកអប់រំវិទ្យាសាស្ត្រ

សូមលោក/លោកស្រីគូសសញ្ញាគ្រីស (✓) នៅក្នុងប្រអប់ណាមួយដែលបញ្ជាក់ពីសកម្មភាពជាក់ស្ដែងនៅសាលាធនជាន និងសាលាបណ្ដាញរបស់លោក លោកស្រី។

សូមលោក/ លោកស្រីគូសសញ្ញា(✓) ក្នុងកូឡោនមួយតាមការពន្យល់ដូចខាងក្រោម៖

- "អនុវត្តន៍បានច្រើនបំផុត" មានន័យថាការអនុវត្តតាមខ្លឹមសារ ឬគោលគំនិតបានច្រើនបំផុត ឬជាប្រចាំគ្រប់ពេល ពោលគឺក្នុងកម្រិតពី៩០%-១០០%
- "អនុវត្តន៍បានច្រើន" មានន័យថាការអនុវត្តខ្លឹមសារ ឬគោលគំនិតនោះបានច្រើន ឬស្ទើរតែគ្រប់ពេល ពោលគឺក្នុងកម្រិតពី៦០%-៩០%
- "អនុវត្តន៍បានមធ្យម" មានន័យថាការអនុវត្តខ្លឹមសារ ឬគោលគំនិតនោះបានមធ្យម បានអនុវត្តខ្លះ ឬមិនបានអនុវត្តខ្លះពោលគឺក្នុងកម្រិតពី៤០%-៦០%
- "អនុវត្តបានតិច" មានន័យថាការអនុវត្តខ្លឹមសារ ឬគោលគំនិតនោះបានតិច ឬអនុវត្តម្ដងកាលពោលគឺក្នុងកម្រិតពី ១០%-៤០%
- "អនុវត្តន៍បានតិចបំផុត" មានន័យថាការអនុវត្តខ្លឹមសារ ឬគោលគំនិតនោះបានតិចបំផុត ឬមិនដែលបានអនុវត្តទាល់តែសោះ ពោលគឺក្នុងកម្រិតពី ០%-១០%

| | | កម្រិតនៃការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| ល.រ | បរិយាយ | អនុវត្តបានតិចបំផុត | អនុវត្តបានតិច | អនុវត្តបានមធ្យម | អនុវត្តបានច្រើន | អនុវត្តបានច្រើនបំផុត |
| | *ក. វត្ថុបំណងគោលនយោបាយរបស់សាលារៀន* | | | | | |
| ១ | ភាគរយសិស្សលើលទ្ធផលតេស្តមុខវិជ្ជាសិក្សាគោល | | | | | |
| ២ | ភាគរយសិស្សលើលទ្ធផលតេស្តមុខវិជ្ជាវិទ្យាសាស្រ្ត | | | | | |
| ៣ | ភាគរយសិស្សប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | | | | | |
| ៤ | ភាគរយសិស្សប្រឡងជាប់សញ្ញាប្រមធ្យសិក្សាទុតិយភូមិ | | | | | |
| ៥ | ភាគរយសិស្សចូលរៀន | | | | | |
| ៦ | ភាគរយសិស្សរៀនត្រួតថ្នាក់ | | | | | |
| ៧ | ភាគរយសិស្សបោះបង់ការសិក្សា | | | | | |
| | *ខ. ការគ្រប់គ្រងបន្ទប់ពិសោធន៍* | | | | | |
| ៨ | បានធ្វើផែនការអភិវឌ្ឍសាលាមធ្យមសិក្សាធនធាន | | | | | |
| ៩ | បានធ្វើផែនការសម្រាប់ការបណ្តុះបណ្តាលការបណ្តុះបណ្តាលគ្រូ ទាក់ទងបន្ទប់ពិសោធន៍ | | | | | |
| ១០ | បានប្រើប្រាស់អស់លទ្ធភាពរបស់បន្ទប់ពិសោធន៍ | | | | | |
| ១១ | ធ្វើឲ្យប្រាកដថាបុគ្គលិកអប់រំមានជំនាញច្បាស់លាស់ | | | | | |
| ១២ | ស្វែងរកប្រាក់ចំណូល ថវិកាដើម្បីធានានិរន្តភាពនៃការប្រើប្រាស់បន្ទប់ពិសោធន៍ | | | | | |
| ១៣ | មាននីតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ដែលខូច | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១៤ | បានចាត់ចែងបុគ្គលិកទទួលខុសត្រូវបន្ទប់ពិសោធន៍ តាមតួនាទី និងភារកិច្ច | | | | | |
| *គ.ការគ្រប់គ្រងបន្ទប់កុំព្យូទ័រ* | | | | | | |
| ១៥ | កុំព្យូទ័រដំណើរការគ្រប់ចំនួន | | | | | |
| ១៦ | មានអ្នកទទួលបន្ទុកបន្ទប់កុំព្យូទ័រ | | | | | |
| ១៧ | មានការរៀបចំកាលវិភាគសម្រាប់ប្រើប្រាស់បន្ទប់កុំព្យូទ័រ | | | | | |
| ១៨ | មានបង្រៀនកុំព្យូទ័របន្ថែម ដើម្បីអភិវឌ្ឍសមត្ថភាព | | | | | |
| *ឃ. ការគ្រប់គ្រងបណ្ណាល័យ* | | | | | | |
| ១៩ | មានបណ្ណារក្សប្រចាំការទៀតទាត់ | | | | | |
| ២០ | បណ្ណារក្សបានទទួលការបណ្ដុះបណ្ដាល | | | | | |
| ២១ | មានសៀវភៅស្រាវជ្រាវសំបូរបែប | | | | | |
| ២២ | មានកាលវិភាគសម្រាប់ការប្រើប្រាស់បណ្ណាល័យ | | | | | |
| *ង. កិច្ចគាំទ្រការបង្រៀន និងរៀន* | | | | | | |
| ២៣ | ផ្ដល់ឱកាសឱ្យគ្រូមុខវិជ្ជាវិទ្យាសាស្ត្រ ចូលរួមវគ្គបំប៉នទាក់ទងការងារពិសោធន៍ | | | | | |
| ២៤ | មានរៀបចំការប្រជុំ ស្ដីពីការងារបន្ទប់ពិសោធន៍តាមកាលកំណត់ជាមួយ<br><br>គណៈគ្រប់គ្រង | | | | | |
| ២៥ | បានរៀបចំកម្មវិធីប្រជុំដំបូងមួយ ជាមួយនាយកសាលាបណ្ដាញទាំងអស់ | | | | | |
| ២៦ | ធានាបាននូវយន្តការស្ដីពីការប្រើប្រាស់បន្ទប់ពិសោធន៍ប្រកបដោយសុវត្ថិភាព | | | | | |
| ២៧ | មានកាលវិភាគថ្នាក់គ្រូនៅមុខបន្ទប់ពិសោធន៍ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២៨ | មានការគាំទ្រ និងលើកទឹកចិត្តគ្រូ សិស្សសម្រាប់ធ្វើការស្រាវជ្រាវនៅបន្ទប់ពិសោធន៍ | | | | | |
| ២៩ | បន្ទប់ពិសោធន៍មានសេចក្តីណែនាំ ស្តីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធ | | | | | |
| ៣០ | បន្ទប់ពិសោធន៍មានកាលវិភាគសម្រាប់ជួសជុលសម្ភារៈជាទៀងទាត់ | | | | | |
| ៣១ | មានបុគ្គលិកជំនួយផ្នែកបច្ចេកទេសដល់លោកគ្រូ អ្នកគ្រូ | | | | | |
| ៣២ | មានផ្តល់រង្វាន់លើកទឹកចិត្ត ដល់របៀបពិសោធន៍ថ្មីៗ | | | | | |
| | ***ច. កិច្ចសហប្រតិបត្តិការ*** | | | | | |
| ៣៣ | សាលាបឋមសិក្សាបណ្តាញចូលមកប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | | | | | |
| ៣៤ | បានបង្កបរិយាកាស ឱ្យភាគីពាក់ព័ន្ធ អាចប្រើប្រាស់បន្ទប់ពិសោធន៍នៃអគារធនធាន | | | | | |
| ៣៥ | បានរៀបចំបញ្ជីកត់ត្រាពីការប្រើប្រាស់បន្ទប់ពិសោធន៍ របស់សាលាបណ្តាញ | | | | | |
| ៣៦ | ចែករំលែកធនធានសម្ភារៈ និងចំណេះដឹងដល់សាលាបណ្តាញ | | | | | |
| ៣៧ | ត្រួតពិនិត្យជាប្រចាំនៃសម្ភារៈ ក្រោយបញ្ចប់ដំណើរការពិសោធន៍នីមួយៗ | | | | | |
| | ***ឆ.ការបង្រៀននិងរៀននៅបន្ទប់ពិសោធន៍*** | | | | | |
| ៣៨ | បានអនុវត្តម៉ោងពិសោធន៍តាមកាលវិភាគថ្នាក់មុខវិជ្ជាគ្រប់គ្រាន់ | | | | | |
| ៣៩ | បានធ្វើដំណើរការពិសោធន៍តាមសេចក្តីណែនាំរបស់ក្រសួងអប់រំ | | | | | |
| ៤០ | បន្ទប់ពិសោធន៍មានសេចក្តីណែនាំ ស្តីពីនីតិវិធីស្នើសុំសម្ភារៈធ្វើពិសោធ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤១ | បន្ទប់ពិសោធន៍មានសម្ភារៈគ្រប់គ្រាន់សម្រាប់ពិសោធន៍តាមមេរៀននីមួយៗ | | | | | |
| ៤២ | បន្ទប់ពិសោធន៍មានបរិយាកាសសិក្សាល្អ ធ្វើឲ្យសិស្សងាយស្រួលសិក្សា | | | | | |
| ៤៣ | បានប្រើប្រាស់ចំណេះដឹងថ្មី លើការងារពិសោធន៍ | | | | | |
| ៤៤ | មានវិធីសាស្ត្របង្រៀនពិសោធន៍ដោយឡែក ពីការបង្រៀនក្នុងថ្នាក់ | | | | | |
| ៤៥ | បានប្រើប្រាស់អស់លទ្ធភាព របស់បន្ទប់ពិសោធន៍ | | | | | |
| ៤៦ | គោរពតាមនិតិវិធីក្នុងការរក្សាសម្ភារៈបន្ទប់ពិសោធន៍ | | | | | |
| ៤៧ | សិស្សមានឆន្ទៈនិងចង់ស្វែងយល់នៃមេរៀនក្នុងម៉ោងពិសោធន៍ | | | | | |

ផ្នែកទី៣៖តើលោក/ស្រីមានផលលំបាក និងមានបញ្ហាប្រឈមអ្វីខ្លះចំពោះការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញ ?

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

......................................................................................................................

សូមអរគុណ!

# ឧបសម្ព័ន្ធទី៣៖ លិខិតឧទ្ទេសនាមបំណែងចែកគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ១៤៣៤ អយក.ឧទន

## លិខិតឧទ្ទេសនាម

យោង ៖ - លិខិតលេខ៣៣៦២ អយក.វជអ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩។
- បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូដឹកនាំបង្គោល និងគ្រូដឹកនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ឆ្នាំសិក្សា២០១៩-២០២១ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គ្រូដឹកនាំបង្គោល | គ្រូដឹកនាំរង | ប្រធានបទនិក្ខេបបទស្រាវជ្រាវ | និស្សិត |
|---|---|---|---|---|
| ១ | លោក<br>សៀង វាសនា | លោកបណ្ឌិត<br>អាន វ៉ូប្រាវ | ទស្សនៈរបស់បុគ្គលិកអប់រំចំពោះការអនុវត្តកំណែទម្រង់ការគ្រប់គ្រងធនធានមនុស្សនៅមធ្យមសិក្សាទុតិយភូមិ ឆ្លើយតបទៅនឹងគោលនយោបាយអប់រំ ២០១៨-២០២៣ នៅក្នុងរាជធានីភ្នំពេញ | ល.ស គីម ដាវី |
| ២ | លោកបណ្ឌិត<br>ម៉ម ចាន់សៀន | លោកស្រី<br>ប៊ុន សុផានី | ប្រសិទ្ធភាពនៃការចូលរួមរបស់សហគមន៍ទៅលើការពង្រឹងការអនុវត្តការគ្រប់គ្រងសាលារៀនអនុវិទ្យាល័យ(ករណីសិក្សាស្រុកទ្រាំង ខេត្តតាកែវ) | ល. ជី ចាន់ |
| ៣ | ឯកឧត្តមបណ្ឌិត<br>ម៉ុក សារ៉ុម | លោក<br>ម៉ន មុនិន្ទ | ទស្សនៈរបស់គ្រូបង្រៀនលើការអនុវត្តភាពជាអ្នកដឹកនាំរបស់នាយកសាលាកម្រិតវិទ្យាល័យក្នុងខេត្តរតនគិរី | ល. ឈុន សុគន្ធា |
| ៤ | លោកបណ្ឌិត<br>នី វឌ្ឍា | លោក<br>លឹម វ៉ាន់ | ស្ថានភាពនៃការបង្រៀន និងរៀនលើមុខវិជ្ជា ICT នៅមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តព្រៃវែង | ល. ប៉ាវ សេងហួ |

| | | | | |
|---|---|---|---|---|
| ៥ | លោកបណ្ឌិត<br>នី រដ្ឋា | លោក<br>ឱ បុណ្ណា | ផលជះនៃការធ្វើតេស្តសិស្សថ្នាក់ទី៦ ឡើងទី៧ លើមុខវិជ្ជាជាភាសាខ្មែរ និង គណិតវិទ្យារបស់គម្រោងកែលម្អគុណភាពអប់រំហៅថា (SEIP) ករណីសិក្សា ខេត្តព្រះសីហនុ | ល. ឈុក ជន |
| ៦ | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | លោក<br>ថៃ ហេង | យុទ្ធសាស្ត្រនៃការដោះស្រាយបញ្ហាខ្វះគ្រូ និងលើសគ្រូ ក្នុងខេត្តកំពង់ធំ | ល. នេត សីមា |
| ៧ | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | លោក<br>ឡុច ចាន់ថន | យុទ្ធសាស្ត្រជំរុញគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិក្នុងខេត្តកំពង់ស្ពឺឱ្យបំពេញភារកិច្ចប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ | ល. ប៊ិន តុលា |
| ៨ | លោកស្រី<br>នូ ចន្នី | លោកបណ្ឌិត<br>អាន រ៉ូប្រាវ | ទស្សនៈគ្រូឧទ្ទេសលើការដឹកនាំ និង គ្រប់គ្រងការបង្រៀន និងរៀននៅ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ | ល. បែន ដាលី |
| ៩ | ឯកឧត្តម<br>នៀ សុផន | លោកបណ្ឌិត<br>កាង ស៊ុងឆាង | ស្ថានភាពនៃការបែងចែកផែនការក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តមនៅវិទ្យាល័យ ប្រចាំឆ្នាំ២០១៩ ករណីសិក្សាខេត្តកណ្តាល | ល. ផាន់ សារ៉ាវុឌ្ឍ |
| ១០ | លោកបណ្ឌិត<br>ឈាង សង្វាត | លោក<br>ថៃ ហេង | ស្ថានភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មន្ទីរអប់រំយុវជន និងកីឡា ខេត្តរតនគិរី | ល.ព្រិញ ចាន់ហួរ |
| ១១ | ឯកឧត្តមបណ្ឌិត<br>ជ័យ សារិន | លោក<br>ម៉ន មុនិន្ទ | ស្ថានភាពនៃការអនុវត្តប្រព័ន្ធអធិការកិច្ចផ្ទៃក្នុង ក្នុងការធ្វើស្វ័យវាយតម្លៃសាលារៀន «ករណីសិក្សា ស្រុករំដួលខេត្តស្វាយរៀង» | ល. ព្រំ រចនា |
| ១២ | លោកស្រី<br>ខែក សំណាង | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | ការសិក្សាសៀវភៅសិក្សាគោលមុខវិជ្ជាអក្សរសាស្ត្រខ្មែរនៅកម្រិតមធ្យមសិក្សាទុតិយភូមិ«ករណីសិក្សាក្នុងខេត្តព្រៃវែង» | ល. ភ័ណ សុភា |
| ១៣ | លោក<br>ចាប រតនា | លោកបណ្ឌិត<br>ឈាង សង្វាត | ការបំពេញការងាររបស់នាយកសាលាមធ្យមសិក្សាធនធាននិងសាលាបណ្តាញក្នុងខេត្តកំពង់ស្ពឺធៀបនឹងគោលនយោបាយសាលាមធ្យមសិក្សាធនធាន | ល. មុន សុខកែវ |

| | | | | |
|---|---|---|---|---|
| ១៤ | លោកបណ្ឌិត<br>អាន វ៉ូប្រាវ | លោកស្រី<br>នូ ចន្ទី | ទស្សនរបស់គ្រូបង្រៀន និងនាយកសាលាលើការអនុវត្តផែនការសកម្មភាពនៃគោលនយោបាយស្ដីគ្រូបង្រៀននៅមធ្យមសិក្សាទុតិភូមិក្នុងរាជធានីភ្នំពេញ | ល. យ៉ាង ច័ន្ទស្មើ |
| ១៥ | លោកបណ្ឌិត<br>សំអោ អង្គារតន៍ | លោកស្រី<br>សុខ វណ្ណា | ទស្សនៈគ្រូបង្រៀនទៅលើប្រសិទ្ធភាពនៃការបង្រៀននិងរៀនតាមប្រព័ន្ធអេឡិចត្រូនិកនិងការបង្រៀននិងរៀននៅក្នុងថ្នាក់ផ្ទាល់នៅកម្រិតមធ្យមសិក្សា | ល. យឹម រស្មី |
| ១៦ | លោក<br>ម៉ន មុនិន្ទ | លោកបណ្ឌិត<br>នូវ វីរ៉ា | ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ លើការអនុវត្តកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសដើម្បីបញ្ជ្រាបការអប់រំពលរដ្ឋពេញលេញនៅខេត្តឧត្តរមានជ័យ | ល. រស់ សុភាន់ |
| ១៧ | លោក<br>ម៉ៅ សារឿន | ឯកឧត្តមបណ្ឌិត<br>ម៉ុក សារ៉ុម | ស្ថានភាពនៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងការគ្រប់គ្រង និងការបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តរតនគិរី | ល. លាស់ សាឡុន |
| ១៨ | លោក<br>ថៃ ហេង | លោកបណ្ឌិត<br>ម៉ម ចាន់សៀន | ការសិក្សាស្វែងយល់អំពីផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ របស់រាជធានី-ខេត្ត | ល. ស៊ន់ កុសល |
| ១៩ | លោក<br>លឹម វ៉ាន់ | លោកបណ្ឌិត<br>នូវ វីរ៉ា | ការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញករណីសិក្សានៅខេត្តតាកែវ | ល. ស៊ុំ សុខឿន |
| ២០ | លោកបណ្ឌិត<br>នូវ វីរ៉ា | លោក<br>ចាប រតនា | ស្ថានភាពនៃការអនុវត្តកម្មវិធីកញ្ចប់អំណានថ្នាក់ដំបូង ក្នុងខេត្តកំពង់ឆ្នាំង | ល. អ៊ុង សុផល |

**ឯកឧត្តម លោក លោកស្រី** ដូចមានរាយនាមខាងលើ ត្រូវទទួលភារកិច្ចអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
" ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
" ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន " ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ វជអ

## ឧបសម្ព័ន្ធទី៤៖ លិខិតជូនដំណឹងទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ២៤០៩ អយក. វិជអម

ថ្ងៃសុក្រ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

**ជម្រាបមក**

**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨។

**យោង៖** -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-លិខិតលេខ១៤៣៥ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី ប្រធាន** ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ចំនួន៣១នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមរាជធានី-ខេត្តនានាតាមប្រព័ន្ធអនឡាញ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី ប្រធាន** ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម **លោក លោកស្រី ប្រធាន** ទទួលនូវការគោរពអំពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី ខេត្តពាក់ព័ន្ធ

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# ឧបសម្ព័ន្ធទី៥៖ លិខិតឧទ្ទេសនាមគណៈមេប្រយោគសម្រាប់ការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** [illegible] **អយក.** [illegible]

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ ទី៨ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យក់ ប៊ុយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **ណាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **ឌី ខាំបូលី** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ រដេអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh